សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មករា ឆ្នាំ ២០១៧

# លីអាហូណា



## ជាមួយនឹងសុទិដ្ឋិនិយម សេចក្ដីស្រឡាញ់ ព្រមទាំងទស្សនវិស័យ ៖ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ទំព័រ ២២

ឆ្ពោះទៅរកចំណុចសំខាន់នៃការសួរសំណួរ ទំព័រ ១៤

ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា ៖ ចំណេះដឹងចំៗអំពី ព្រះវរបិតា និង ព្រះរាជបុត្រា ទំព័រ ១៦

នៅពេលអ្នកនៅតែឯង ចូរជ្រើសយកការមានចិត្តក្លាហាន ទំព័រ ២៨




បានកត់សម្គាល់ដោយជាងថតរូប ចច អ៊ីតរួដ អែនឌើរសិន ជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលបានថតរូបនេះនៅក្នុង ១៩០៧ ។
វាបង្ហាញពីភាពផ្ទុយគ្នាជាមួយនឹងព្រឹត្តិការណ៍សំខាន់ ដែលបានបង្ហាញអំពីព្រៃដែលនៅក្បែរនោះ ៖ ការនិមិត្តដំបូង ។
នៅក្នុងព្រៃពិសិដ្ឋនោះក្បែរភូមិ ប៉ាម៉ៃរ៉ា រដ្ឋ នូវ យ៉ោក យ៉ូសែប ស្ម៊ីធ អាយុ ១៤ ឆ្នាំ បានអធិស្ឋានដើម្បីដឹងថា
តើត្រូវចូលរួមសាសនាចក្រណាមួយ ហើយបានទទួលចម្លើយដោយមានការយាងមកជួបពីព្រះជាព្រះវរបិតា និង ព្រះរាជបុត្រា ។

រូបថតទទួលបានសិទ្ធិអនុញ្ញាតពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ

# លីអាហូណា ខែ មករា ឆ្នាំ ២០១៧



៤


**២៨ ចូរក្លាហានក្នុងទីបន្ទាល់របស់យើងអំពីព្រះអង្គសង្គ្រោះ**
ដោយអែលឌើរ គ្រីស្ទូហ្វិល ហ្គូលឌិន
*គ្រាដែលលំបាកបំផុតនោះគឺជាគ្រាដែលនឹងមានន័យបំផុតសម្រាប់យើង ។*

**៣៤ កំពុងដែលខំឲ្យបានរបស់ផ្សេងៗ នោះចូរខំឲ្យបានយោបល់ផង**
ដោយអែលឌើរ ហ្គេរី អ៊ី ស្ទីវែនសុន
*យោបល់ពិតប្រាកដនឹងកើតឡើងតាមរយៈការយល់ដឹងអំពីទំនាក់ទំនងរវាងការសិក្សា និង ការអធិស្ឋាន ការតាំងចិត្តបម្រើ និង ការទុកចិត្តលើព្រះអម្ចាស់ ។*


## សារលិខិត


**៤ សារលិខិតគណៈប្រធានទីមួយ: តម្រង់ឲ្យចំទីដៅ**
ដោយប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ

**៧ សារលិខិតបង្រៀនសួរសុខទុក្ខ: គោលបំណងនៃសមាគមសង្គ្រោះ**




**នៅលើក្របមុខ**
ខាងមុខ ៖ រូបថតដោយ ចច ហ្វ្រេ ។ ខាងក្នុងគម្របមុខ ៖ រូបថតដោយ ចច អ៊ីតវូដ អែនឌើរសិន បានទទួលសិទ្ធិអនុញ្ញាតពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ ។

## អត្ថបទពិសេសៗ


**១៦ ការយល់ដឹងអំពីព្រះវរបិតា និងព្រះរាជបុត្រាមកពីព្រះគម្ពីរគោលលទ្ធិ និង សេចក្តីសញ្ញា**
ដោយ ន័រមែន ដបុលយូ ហ្គូនើរ
*ដោយសារការបាត់បង់សេចក្តីពិតបានបើកសម្តែងនៅក្នុងការស្តារឡើងវិញ នោះព្រះគម្ពីរគោលលទ្ធិ និង សេចក្តីសញ្ញាជួយយើងឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីព្រះវរបិតា និង ព្រះរាជបុត្រា ។*

**២២ ហ្គរដុន ប៊ី ហ៊ិងគ្លី ៖ ព្យាការីដែលមានសុទិដ្ឋិនិយម និង ទស្សនវិស័យ**
ដោយ អែនឌ្រូ ឌី អូសិន
*ក្នុងនាមជាប្រធានទី ១៥ នៃសាសនាចក្រ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានដឹកនាំតាមរយៈគំរូដែលពោរពេញដោយភាពសុទិដ្ឋិនិយម សេចក្តីស្រឡាញ់ និង ទស្សនវិស័យសម្រាប់ពេលអនាគត ។*


## ផ្នែកនានា


**៨ សៀវភៅកំណត់ចំណាំសន្និសីទ ខែ តុលា ឆ្នាំ ២០១៦**

**១០ អ្វីដែលយើងជឿ: យើងជឿថាដំណឹងល្អនឹងមានពាសពេញផ្ទៃផែនដី**

**១២ គេហដ្ឋានរបស់យើង ក្រុមគ្រួសាររបស់យើង: កូនចង់រស់នៅជាមួយក្រុមគ្រួសារយើងជារៀងរហូត !**
ដោយ លីអនជីណា អាដាមមែស ឌី យូប្រ៊ី

**១៤ ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ: ការពិចារណាអំពីសំណួរពិភាក្សារបស់យើង**
ដោយ ធិឌ បានិស

**៤០ សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**៨០ លុះត្រាជួបទៀត: រឿងក្តីសម្រាប់ព្យាការីនៅរស់**
ដោយ ប្រធាន ហ៊ូ ប៊ី ប្រោន

| យុវមជ្ឈិមវ័យ | យុវវ័យ | កុមារ |
| --- | --- | --- |

## យុវមជ្ឈិមវ័យ





**៤៤ គោលការណ៍របស់ពួកព្យាការីអំពីភាពស្មោះត្រង់**
ដោយអែលឌើរ ស៊ី ស្កត ហ្គ្រូ
*ការសម្រេចចិត្ត និង ការតាំងចិត្តដែលអ្នកធ្វើក្នុងពេលឥឡូវនេះ អាចជួយអ្នកឲ្យបន្តនៅស្មោះត្រង់នាពេលអនាគត ។*




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើអ្នកលុតជង្គង់អធិស្ឋាននៅកន្លែងណា ?***

## យុវវ័យ


**៥០ បាវចនាម្ហូតធលឆ្នាំ ២០១៧: យ៉ាកុប ១:៥–៦**
ដោយ ស្ទេផាន ដបុលយូ អូវីន និង បូនី អិល អូស្ការសុន

**៥៣ ប័ណ្ណប្រកាស: ចូរសូម**

**៥៤ ការសន្យាទាំងប្រាំអំពីការអធិស្ឋាន**
ដោយ ខាលីសា ក្រាមើរ
*ការអធិស្ឋានគឺវាលើសពីមធ្យោបាយមួយ ដើម្បីទាក់ទងជាមួយព្រះវរបិតាសួគ៌របស់យើង ដែលគង់នៅស្ថានសួគ៌ទៅទៀត ។ នេះគឺជាពរជ័យមួយចំនួន ដែលការអធិស្ឋានផ្ដល់ឲ្យ ។*

**៥៦ សំណួរចំនួនប្រាំដែលត្រូវសួរ នៅពេលទទួលអារម្មណ៍ថាការអធិស្ឋានពុំបានទទួលចម្លើយ**
ដោយ ម៉ាហ្គារ៉េត វីលដិន
*វាអាចជាការពិបាក នៅពេលទទួលអារម្មណ៍ថាការអធិស្ឋានពុំបានទទួលចម្លើយ ប៉ុន្តែមានសំណួរមួយចំនួនអាចជួយអ្នក គិតអំពីរឿងនានាក្នុងរបៀបមួយថ្មី ។*

**៥៨ ចម្រៀងបាវចនាម្ហូតធល: សូមដល់ព្រះ**
ដោយ នីក ឌេ

**៦១ មួយបន្ទាត់ម្ដងៗ: យ៉ាកុប ១:៥–៦**

**៦២ គ្រានៃសេឡេស្ទាល**
ដោយ ហូលី ម៉េហ្គេន ឡូវ៉ា ហាន់ធើរ
*ជាមួយគ្រាទាំងនេះ ស្ថានសួគ៌ហាក់បីដូចជានៅមិនឆ្ងាយឡើយ ។*

**៦៣ ទីកន្លែងរបស់យើង**

**៦៤ ចម្លើយមកពីថ្នាក់ដឹកនាំនៃសាសនាចក្រ: របៀបចែកចាយដំណឹងល្អ**
ដោយអែលឌើរ អិម រ័សុល បាឡឺដ

**៦៥ ចំទៅនឹងគោលដៅ**
*តើមានការលំបាកក្នុងការអភ័យទោសឬ ? តើមានការលំបាកជាមួយនឹងជំងឺធ្លាក់ទឹកចិត្តឬ ?*







## កុមារ





**៦៦ តារាងអានគម្ពីរប្រវត្តិសាសនាចក្រ: ការស្ដារឡើងវិញ**

**៦៩ ចម្លើយមកពីសាវក: តើព្រះវរបិតាសួគ៌ទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់ខ្ញុំជានិច្ចឬ ?**
ដោយអែលឌើរ ដាល្លិន អេក អូក

**៧០ ទំព័ររបស់យើង**

**៧១ ព្រះគម្ពីរនៅលើធ្នើរ**
ដោយអែលឌើរ វ៉លធើរ អែហ្វ ហ្គុងស្សាឡែស្ស
*ដោយរកមើលសៀវភៅល្អៗមកអាន នោះខ្ញុំបានឃើញព្រះគម្ពីរមរមន ហើយវាបានផ្លាស់ប្ដូរជីវិតខ្ញុំ ។*

**៧២ តម្លៃរបស់ មិន ជុន**
ដោយ ឃែលី ហានសាឃើរ
*តើមិន ជុន អាចចូលទៅក្នុងព្រះវិហារយ៉ាងដូចម្ដេច នៅពេលគាត់ប្រឡាក់ខ្លួន និង សើមជោគពេញខ្លួននោះ ?*

**៧៤ សូមកុំភ្លេចអធិស្ឋានឲ្យអ៊ីរីក**
ដោយ ជូលី កូនេសាល ហោង
*ខារីកើតទុក្ខ ដែលបងប្រុសរបស់នាងពុំចង់ទៅព្រះវិហារតទៅទៀត ប៉ុន្តែក្រោយមកនាងបានរៀនមេរៀនសំខាន់មួយអំពីការអធិស្ឋាន ។*

**៧៦ រឿងអំពីព្រះយេស៊ូវ: ព្រះយេស៊ូវស្រឡាញ់ខ្ញុំ**
ដោយ គីម វិប រៀដ

**៧៩ ទំព័រផាត់ពណ៌: ខ្ញុំជាបុត្ររបស់ព្រះមាតាបិតាសួគ៌**

**លេខ ១ វ៉ុលទី ៤១ ចុះខែ មករា ឆ្នាំ ២០១៧**
**លីអាហូណា 14441 258**
ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម. រ័សុល បាឡឺដ, រ៉ូប៊ឺត ឌី ហែល, ជែហ្វ្រី អ័រ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវ៉ែនសុន, ឌេល ជី រេនឡាន់

**និពន្ធនាយក ៖** យ៉ូសែប ដបុលយូ. ស៊ីតាទី
**ជំនួយការនិពន្ធនាយក ៖** រ៉េនដល ឃេ បិនណ្ណិត, ខារ៉ូ អេហ្វ ម៉ាកខន់ឃី
**អ្នកប្រឹក្សា ៖** ប្រេន ខេ អាស្តុន, ជីន ប៊ី ប៊ីងហាំ, ឡឺហ្វ្រង់ ឬ ខឺធីស ជុញ្ញ័រ, គ្រីស្តូហ្វែល ហ្គូលឌិន, ដូហ្គ្លាស ឌី ហូលមែស, អ៊ើរិក ដ៊ុបយូរ កូពីស្កេ, ឡែរី អរ ឡររិន, ខារ៉ូលី អិម ស្ទេហ្វិន

**នាយកគ្រប់គ្រង ៖** ភីធើរ អេហ្វ អេវ៉ាន់ស៍
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយប៊ិហ្គ
**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់
**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រដាម ស៊ី អូស្តុន
**ជំនួយការ ការគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ាយអិន ខារ
**ជំនួយការបោះពុម្ព ៖** មេហ្គេន ស៊ីត
**និពន្ធ និងកែសម្រួលដោយ ៖** ប៉េតថានី បាថូឡូម៉ូ, ប្រ៊ីតថានី ប៊ីតធី, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវ៉ែត, ម៉ាធ្យូ ឌី ហ្វ្លីតុន, ឡារី ហ្វូឡើរ, ហ្គារ៉េត អេច ហ្គាហ្វ, ឡារ៉ែន ផតទើរ ហ្គាន, ឆាលឡុត ឡាកាបាល់, ម៉ៃឃល អរ ម៉ូរីស, អ៊ើរិក ប៊ី ម៉ុដក សាលី ចនសុន អូដេឃឹក, យ៉ូស្វេ ជេ ភីគី, ចាន ភីនបូរ៉ាហ្វ, រិឆាត អិម រ៉មនី, ម៉ីនឌី អាន សេលូ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថែដ អ័រ ភីធើរសុន
**រចនាប្លង់ដោយ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, ស៊ី ឃីមប៊ល បុត, ថូម៉ាស ឆាល, ដេវីឌ ហ្គ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រីន, ស្កត អិម ម៉ូយ, ម៉ាក ដប៊ុលយូ រ៉ូប៊ីសុន, រ៉ាជែល ស្មីធ, ប្រាត ធៀរ, ឃេ នីកូល វ៉ែកឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នែបេឃើ អាននី
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ហ្គេន អាឌៀ, ខន្នី បិរទួប ប្រ៊ីច, ជូលី ប៊ឺដេត, ខេទី ដានខាន, ប្រែអិន ដ័បុលយូ ជីជី, ជីន្នី ជេ និលសុន, ហ្គែល ធេត រ៉ាហ្វឺធី
**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស
**នាយកចែកចាយ ៖** ត្រយ ខេ វេលីនហ្គា

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬសាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និង សំណួរនានា** តាមអ៊ិនធើណែតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាសែល, ម៉ុងហ្គោលី, នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។

( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2017 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

ព័ត៌មានអំពីកម្មសិទ្ធិបញ្ញា ៖ លុះត្រាមានការបញ្ជាក់ បុគ្គលម្នាក់ៗអាចថតចម្លងឯកសារចេញពី*លីអាហូណា*នេះសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬ ពុំមែនដើម្បីធ្វើអាជីវកម្ម ( រួមទាំងការហៅបម្រើក្នុងសាសនាចក្រ ) ។ សិទ្ធិនេះអាចត្រូវបានលុបចោលវិញគ្រប់ពេល ។ រូបភាពពុំអាចថតចម្លងបានឡើយ ប្រសិនបើឃើញមានការដាក់បម្រាមបង្ហាញនៅក្នុងជួរបន្ទាត់នៃការដកស្រង់នៃរូបភាពនោះ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., FL 13, Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

For Readers in the United States and Canada:
January 2017 Vol. 41 No. 1. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $10.00 per year; Canada, $12.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# យោបល់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ពីរ ។*



**« ចូរក្លាហានក្នុងទីបន្ទាល់របស់យើងអំពីព្រះអង្គសង្គ្រោះ »** ទំព័រ ២៨ ៖ អែលឌើរ ហ្គូលឌិន ពិភាក្សាអំពីរបៀបដែលយើងម្នាក់ៗនឹងជួបនូវការលំបាក ប៉ុន្តែជាគ្រាដ៏មានន័យនៅក្នុងជីវិតរបស់យើង ។ អ្នកអាចសម្ដែងស្ថានភាពមួយចំនួន ដែលសមាជិកគ្រួសារជួបប្រទះនឹងការសម្រេចចិត្តដ៏លំបាក ។ ឧទាហរណ៍ អ្នកអាចហាត់សមបដិសេធមិត្តរួមថ្នាក់ ដែលសូមចម្លងកិច្ចការសាលារបស់អ្នក ឬ សូមឲ្យមិត្តភក្តិរបស់អ្នកប្រើពាក្យសម្ដីពីរោះពិសា ។ សូមនិយាយអំពីរបៀបដែលអ្នកអាចរៀបចំខ្លួន ដោយការបង្កើនទីបន្ទាល់រឹងមាំអំពីព្រះអង្គសង្គ្រោះ មុនពេលស្ថានភាពបែបនោះកើតមានឡើង ។

**« តើព្រះវរបិតាសួគ៌ទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់ខ្ញុំជានិច្ចឬ ? »** ទំព័រ ៦៩ ៖ តើអ្នកឃើញថា ការអធិស្ឋានរបស់អ្នកឆ្លើយតបយ៉ាងដូចម្ដេច ? អ្នកអាចចែកចាយបទពិសោធន៍ជាក់លាក់ នៅពេលព្រះអម្ចាស់ឆ្លើយតបការអធិស្ឋានរបស់អ្នក ទោះបីចម្លើយទាំងនោះបានឆ្លើយតបតាមការរំពឹងទុក ឬ មិនតាមការរំពឹងទុកក្ដី ។ សូមគិតពីការលើកទឹកចិត្តគ្នាទៅវិញទៅមក ឲ្យកត់ត្រាក្នុងទិនានុប្បវត្តិអំពីរបៀបជាក់លាក់នានាដែលព្រះអម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់អ្នក ហើយប្រទានពរដល់អ្នក ។

## មានធនធានជាច្រើនទៀតនៅលើអ៊ិនធើណែត

*លីអាហូណា* និង ធនធានផ្សេងៗទៀតរបស់សាសនាចក្រ មានជាច្រើនភាសានៅលើគេហទំព័រ **languages.lds.org** ។ ការថតជាសំឡេងរបស់អត្ថបទ *លីអាហូណា* មានជាភាសាអង់គ្លេស ព័រទុយហ្គាល់ និង អេស្ប៉ាញនៅគេហទំព័រ **liahona.lds.org** ។ អ្នកអាចមើលគេហទំព័រ **facebook.com/liahona.magazine** ផងដែរ ដើម្បីមើល និង ចែកចាយសារលិខិតបំផុសគំនិតនានា ( មានជាភាសា អង់គ្លេស ព័រទុយហ្គាល់ និង អេស្ប៉ាញ ) ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយគឺ តំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

***ការគោរពប្រតិបត្តិ***, *៤៤, ៦១*
***ការណ៍អាសគ្រាម***, *៤៤*
***ការយាងមកជាលើកទីពីរ***, *១០*
***ការសិក្សាព្រះគម្ពីរ***, *៣៤, ៤៣, ៦៦, ៧១*
***ការស្ដារឡើងវិញ***, *១៦, ៦៦*
***ការអធិស្ឋាន***, *៣៤, ៤២, ៥០, ៥៣, ៥៤, ៥៦, ៥៨, ៦១, ៧១, ៧៤*
***ការអភ័យទោស***, *៥៤, ៦៥*
***កិច្ចការផ្សព្វផ្សាយសាសនា***, *១០, ៣៤, ៦៣, ៦៤, ៧១*
***ក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច***, *១២, ៤១, ៤៤, ៦៣, ៧៩*
***ក្រុមព្រះ***, *១៦*
***គោលលទ្ធិ និង សេចក្ដីសញ្ញា***, *១៦, ៦៦*
***ដំងឺធ្លាក់ទឹកចិត្ត***, *៦៥*
***តម្លៃរបស់បុគ្គលម្នាក់ៗ***, *៧២*
***ទីបន្ទាល់***, *២២, ២៨, ៤៤, ៦៤*
***ប្រវត្តិសាសនាចក្រ***, *១០, ១៦, ២៨, ៣៤, ៦៦*
***ពង្សប្រវត្តិ***, *៤១, ៦៣*
***ព្យាការី***, *២២, ៨០*
***ព្រះគម្ពីរមរមន***, *៧១*
***ព្រះបញ្ញត្តិ***, *៤, ២៨, ៧៦*
***ព្រះយេស៊ូវគ្រីស្ទ***, *៤, ១៦, ២៨, ៣៤, ៧០, ៧៦*
***ព្រះវិញ្ញាណបរិសុទ្ធ***, *៤២, ៥៤, ៦២, ៦៤, ៧៤*
***ព្រះវិហារបរិសុទ្ធ***, *១២, ២២, ៤៤, ៦២, ៦៣, ៧០*
***ភាពជាស្ត្រី***, *៤០*
***ភាពសុខសាន្ត***, *៥៤, ៦២*
***យ៉ូសែប ស្ម៊ីធ***, *១០, ១៦, ២៨, ៣៤, ៦៦, ៧១, ៨០*
***សមាគមសង្គ្រោះ***, *៧*
***សិទ្ធិជ្រើសរើស***, *៤៤, ៧៤*
***សេចក្ដីជំនឿ***, *១២, ២២, ៣៤, ៤៤, ៥០, ៥៣, ៥៨, ៦១, ៧២, ៨០*
***សេចក្ដីស្រឡាញ់***, *៤, ២២, ៧៦*
***សេចក្ដីសញ្ញា***, *៤៤*
***សំណួរ***, *១៤, ៥៦, ៥៨*
***អាទិភាព***, *៤៣, ៤៤*



ដោយប្រធាន ឌៀថើរ អេស្វ
អុជដូហ្វ
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

# តម្រង់
## ឲ្យចំទីដៅ

ថ្មីៗនេះ ខ្ញុំបានមើលមនុស្សមួយក្រុមហាត់សមសិល្បវិជ្ជានៃការបាញ់ព្រួញ ។ ដោយគ្រាន់តែមើល វាធ្វើឲ្យខ្ញុំដឹងយ៉ាងច្បាស់ថា ប្រសិនបើអ្នកពិតជាចង់ពូកែខាងការកាន់ធ្នូ និង បាញ់ព្រួញ វាត្រូវការពេលវេលា និង ការហាត់សម ។

ខ្ញុំគិតថា អ្នកពុំអាចបង្កើនកេរ្តិ៍ឈ្មោះដើម្បីក្លាយជាអ្នកបាញ់ព្រួញដ៏មានស្នាដៃ ដោយការបាញ់ព្រួញទៅលើជញ្ជាំងទទេស្អាត បន្ទាប់មកគូររង្វង់ជុំវិញព្រួញនោះថា វាជាទីដៅដែលយើងត្រូវបាញ់នោះឡើយ។ អ្នកត្រូវតែរៀនពីសិល្បវិជ្ជានៃការស្វែងរកទីដៅ ហើយបាញ់ឲ្យចំចំណុចកណ្ដាលនៃផ្ទាំងសីបនោះ ។

### ការលោបពណ៌ទីដៅនៃផ្ទាំងសីប

ការបាញ់ព្រួញជាមុន ហើយគូរទីដៅជាក្រោយអាចទំនងជាចម្លែកបន្តិច ប៉ុន្តែជួនកាលខ្លួនយើងផ្ទាល់បង្ហាញពីឥរិយាបថនេះនៅក្នុងដំណើរជីវិតយើង ។

ក្នុងនាមជាសមាជិកសាសនាចក្រ ជួនកាលយើងមានទំនោរភ្ជាប់ខ្លួនយើងទៅនឹងកម្មវិធី ការចេញផ្សាយ និង គោលលទ្ធិនានានៃដំណឹងល្អ ដែលទំនងជាគួរឲ្យចាប់អារម្មណ៍ សំខាន់ ឬ គួរជាទីរីករាយដល់យើង ។ យើងត្រូវបានល្បួងឲ្យគូរទីដៅនៅជុំវិញសកម្មភាពទាំងនោះ ដោយធ្វើឲ្យយើងជឿថា យើងកំពុងតម្រង់ចំទីដៅនៃដំណឹងល្អ ។

រឿងនេះងាយស្រួលធ្វើ ។

ចាប់តាំងពីសម័យបុរាណមក យើងបានទទួលការទូន្មាន និង ការបំផុសគំនិតដ៏អស្ចារ្យពីព្យាការីរបស់ព្រះ ។ យើងក៏ទទួលការណែនាំ និង ការបញ្ជាក់ពីឯកសារបោះពុម្ព សៀវភៅក្បួនខ្នាត និង សៀវភៅសិក្សាជាច្រើនរបស់សាសនាចក្រផងដែរ ។ យើងអាចជ្រើសរើសបានយ៉ាងងាយនូវប្រធានបទដំណឹងល្អដែលយើងពេញចិត្ត គូររង្វង់ជុំវិញវា ហើយសន្មតថាយើងបានរកឃើញចំណុចសំខាន់បំផុតនៃដំណឹងល្អហើយ ។

### ព្រះអង្គសង្គ្រោះគូសបញ្ជាក់យ៉ាងច្បាស់

នេះពុំគ្រាន់តែជាបញ្ហាកើតឡើងនៅជំនាន់របស់យើងនេះទេ ។ កាលពីបុរាណមេដឹកនាំសាសនាបានចំណាយពេលយ៉ាងច្រើនរៀបចំបទបញ្ញត្តិរាប់រយជាក្រុមជាឋានុក្រម ហើយជជែកវែកញែកគ្នាថាតើបទញ្ញត្តិណាមួយជាបទបញ្ញត្តិសំខាន់បំផុត ។

ថ្ងៃមួយអ្នកប្រាជ្ញខាងសាសនាមួយក្រុមមានបំណងជជែករកខុសត្រូវជាមួយព្រះអង្គសង្គ្រោះ ។ ពួកគេបានសូមឲ្យទ្រង់ផ្ដល់យោបល់លើបញ្ហាដែលមានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលយល់ស្រប ។

ពួកគេបានសួរទ្រង់ថា « លោកគ្រូក្នុងបណ្ដាក្រឹត្យវិន័យ តើបញ្ញត្តិណាដែលយ៉ាងសំខាន់បំផុត ?

យើងទាំងអស់គ្នាបានដឹងពីចម្លើយរបស់ព្រះយេស៊ូវ ៖ « ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្តអស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង ។

នេះជាបញ្ញត្តិយ៉ាងសំខាន់ទីមួយ ។

ហើយបញ្ញត្តិទីពីរក៏បែបដូចគ្នាគឺថា ត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង ។

« បណ្ដាក្រឹត្យវិន័យ និងអស់ទាំងទំនាយហោរាទាំងប៉ុន្មាន ក៏សម្រេចនៅបទបញ្ញត្តិទាំងពីរប្រការនេះឯង » ។[១]

សូមកត់សម្គាល់ប្រយោគចុងក្រោយ ៖ « បណ្ដាក្រឹត្យវិន័យ និង *អស់ទាំង*ទំនាយហោរាទាំងប៉ុន្មានក៏សម្រេចនៅបទបញ្ញត្តិទាំងពីរប្រការនេះឯង » ។

ព្រះអង្គសង្គ្រោះពុំគ្រាន់តែបានបង្ហាញផ្ទាំងសីបដល់យើងឡើយ ប៉ុន្តែទ្រង់ក៏បានគូសបង្ហាញពីចំណុចកណ្ដាលនៃផ្ទាំងសីបផងដែរ ។

### ការបាញ់ឲ្យចំផ្ទាំងសីប

ក្នុងនាមជាសមាជិកសាសនាចក្រ យើងចុះសេចក្ដីសញ្ញាថា លើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។ ការបានយល់ដឹងពីផ្នែកខ្លះនៃសេចក្ដីសញ្ញានោះគឺជាការយល់ដឹងថា យើងនឹងព្យាយាមរៀនអំពីព្រះ ស្រឡាញ់ទ្រង់ បង្កើនសេចក្ដីជំនឿរបស់យើងលើទ្រង់ គោរពទ្រង់ ដើរលើមាគ៌ាទ្រង់ ហើយឈរយ៉ាងខ្ជាប់ខ្ជួនធ្វើជាសាក្សីដល់ទ្រង់ ។

កាលណាយើងរៀនអំពីព្រះ ហើយទទួលអារម្មណ៍នៃក្ដីស្រឡាញ់របស់ទ្រង់កាន់តែច្រើន នោះយើងកាន់តែដឹងថា ការបូជាដ៏គ្មានកំណត់របស់ព្រះយេស៊ូវគ្រីស្ទគឺជាអំណោយទានមកពីព្រះ ។ ហើយសេចក្ដីស្រឡាញ់របស់ព្រះបំផុសគំនិតឲ្យយើង



ប្រើផ្លូវនៃការប្រែចិត្តដ៏ពិត ដែលនឹងនាំឲ្យទទួលបាននូវអព្ភូតហេតុនៃការអភ័យទោស ។ ដំណើរការនេះអនុញ្ញាតឲ្យយើងមានសេចក្ដីស្រឡាញ់ និង សេចក្ដីអាណិតអាសូរកាន់តែខ្លាំងដល់មនុស្សនៅជុំវិញយើង ។ យើងនឹងរៀនមើលមនុស្សលើសពីសំបកខ្លួនខាងក្រៅរបស់ពួកគេ ។ យើងនឹងចៀសផុតពីការល្បួងឲ្យចោទប្រកាន់ ឬ វិនិច្ឆ័យមនុស្សដទៃដោយសារតែអំពើបាប ភាពមិនល្អឥតខ្ចោះ កំហុស គោលគំនិតខាងនយោបាយ ការប្រែចិត្តជឿខាងសាសនា សញ្ជាតិ ឬ ពណ៌សម្បុររបស់ពួកគេ ។

យើងនឹងចាត់ទុកមនុស្សគ្រប់គ្នាដែលយើងជួបថាជាបុត្ររបស់ព្រះវរបិតាសួគ៌—ជាបងប្អូនប្រុសស្រីរបស់យើង ។

យើងនឹងឈោងទៅជួយមនុស្សដទៃដោយការយល់ចិត្ត និង សេចក្ដីស្រឡាញ់—ទោះបីមនុស្សខ្លះអាចមិនងាយស្រឡាញ់ក្ដី ។ យើងនឹងទួញយំជាមួយនឹងអ្នកណាដែលទួញយំ ហើយកម្សាន្តទុក្ខដល់អស់អ្នកណាដែលកំពុងត្រូវការការកម្សាន្តទុក្ខ ។[២]

ហើយយើងនឹងដឹងថា យើងពុំចាំបាច់បារម្ភអំពីទីដៅត្រឹមត្រូវរបស់ដំណឹងល្អឡើយ ។

បទបញ្ញត្តិធំពីរនោះហើយដែលជាទីដៅ ។ បណ្ដាក្រឹត្យវិន័យ និង អស់ទាំងទំនាយហោរាទាំងប៉ុន្មានក៏សម្រេចនៅបទបញ្ញត្តិទាំងពីរប្រការនេះឯង ។[៣] នៅពេលយើងទទួលយកបទបញ្ញត្តិទាំងនេះ នោះរឿងល្អៗផ្សេងទៀតនឹងត្រូវបានយល់ទៅតាមភាពសំខាន់របស់វា ។

ប្រសិនបើយើងផ្ដោតចិត្ត គំនិត និង កិច្ចការសំខាន់របស់យើងលើការបង្កើនសេចក្ដីស្រឡាញ់ចំពោះព្រះដ៏មានមហិទ្ធិឫទ្ធិ ហើយចែកចាយក្ដីស្រឡាញ់របស់យើងចំពោះមនុស្សដទៃ នោះយើងអាចដឹងថា យើងរកឃើញទីដៅត្រឹមត្រូវ ហើយកំពុងតម្រង់ចំចំណុចកណ្ដាលនៃផ្ទាំងស៊ីប—គឺការប្រែក្លាយជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ ។ ■

**កំណត់ចំណាំ**

១. ម៉ាថាយ ២២:៣៦–៤០ ។
២. សូមមើល ម៉ូសាយ ១៨:៩ ។
៣. សូមមើល ម៉ាថាយ ២២:៤០ ។

**ការបង្រៀនចេញពីសារលិខិតនេះ**

ពីមុនចែកចាយសារលិខិតនេះ អ្នកអាចច្រៀងបទ « ក្ដីស្នេហ៍ព្រះអង្គ » ( *ទំនុកតម្កើង* លេខ ៥៩ ) ។ បន្ទាប់មកសូមគិតពីការលើកទឹកចិត្ត ដល់អស់អ្នកដែលអ្នកសួរសុខទុក្ខឲ្យគិតអំពី « ទីដៅ » នានានៅក្នុងជីវិតផ្ទាល់របស់ពួកគេ ។ អ្នកអាចពិភាក្សាពីវិធីនានា ដើម្បីប្រាកដថាបទបញ្ញត្តិធំពីរ—« ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯង » និង « ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » ( សូមមើល ម៉ាថាយ ២២:៣៧, ៣៩ )—កំពុងដឹកនាំទង្វើរបស់ពួកគេជានិច្ច ។ អ្នកក៏អាចចែកចាយវិធីជាក់លាក់នានា ដែលអ្នកបានផ្ដោតចិត្តទុកដាក់លើព្រះគ្រីស្ទនៅក្នុងជីវិតរបស់អ្នកផ្ទាល់ ហើយចែកចាយទីបន្ទាល់ពីរបៀបដែលវិធីទាំងនោះបានផ្ដល់ពរដល់អ្នក ។

រូបថត © SERG MYSHKOVSKY/GETTY IMAGES



## ស្នាមញញឹមអាចធ្វើឲ្យមានការផ្លាស់ប្តូរ

ប្រធាន អុជដូហ្វ បង្ហាញអំពីគោលដៅពីរ ដែលយើងគប្បីមានក្នុងសកម្មភាពរបស់យើង ៖ ស្រឡាញ់ព្រះ និង ស្រឡាញ់មនុស្សនៅជុំវិញយើង ។ ប៉ុន្តែជួនកាលវាពុំងាយស្រួលឡើយ ដើម្បីស្រឡាញ់អ្នកដទៃនោះ ។ ពេញមួយជីវិតរបស់អ្នកអាចមានគ្រានានា ដែលអ្នកមានការលំបាកដើម្បីប្រាស្រ័យទាក់ទងជាមួយមនុស្សដទៃ—ប្រហែលជាមាននរណាម្នាក់ធ្វើឲ្យអ្នកឈឺចាប់ ឬ អ្នកមានគ្រាលំបាកក្នុងការទាក់ទង ឬ ចុះសម្រុងជាមួយនរណាម្នាក់ ។ នៅក្នុងគ្រាទាំងនេះ សូមព្យាយាមនឹកចាំពីសេចក្តីស្រឡាញ់ដែលអ្នកធ្លាប់មានពីមិត្តភក្តិ គ្រួសាររបស់អ្នក ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ សូមចងចាំពីអំណរដែលអ្នកបានទទួលនៅក្នុងស្ថានភាពទាំងនោះ ហើយព្យាយាមស្រមៃមើលថា តើមានសភាពបែបណា ប្រសិនបើមនុស្សគ្រប់គ្នាមានឱកាសទទួលក្តីស្រឡាញ់បែបនេះនោះ ។ សូមចងចាំថាមនុស្សគ្រប់គ្នាគឺជាបុត្រី ឬ បុត្រារបស់ព្រះ ហើយសមនឹងទទួលបាននូវសេចក្តីស្រឡាញ់របស់ទ្រង់ *និង* របស់អ្នក ។

សូមគិតអំពីមនុស្សមួយចំនួននៅក្នុងជីវិតអ្នក ដែលអ្នកពិបាកចុះសម្រុងនឹងពួកគេ ។ ហើយបញ្ចូលឈ្មោះរបស់ពួកគេនៅក្នុងការអធិស្ឋានរបស់អ្នក ហើយទូលសូមឲ្យព្រះវរបិតាសួគ៌បើកដួងចិត្តរបស់អ្នកចំពោះពួកគេ ។ មិនយូរប៉ុន្មាន អ្នកនឹងចាប់ផ្តើមចាត់ទុកពួកគេដូចជាទ្រង់ចាត់ទុកពួកគេដែរ ៖ ថាជាបុត្ររបស់ព្រះដែលសមនឹងទទួលសេចក្តីស្រឡាញ់ ។

បន្ទាប់ពីអ្នកបានអធិស្ឋាន សូមធ្វើអំពើល្អៗសម្រាប់ពួកគេ ! ប្រហែលអ្នកអាចអញ្ជើញពួកគេឲ្យចូលរួមសកម្មភាពម៉្ងូតធល ឬ ដើរលេងជាមួយមិត្តភក្តិ ។ ជួយផ្តល់យោបល់លើកិច្ចការសាលា ។ អាចនិយាយ « សួស្តី » ហើយញញឹមដាក់ពួកគេ ។ កិច្ចការតូចតាចនានាអាចធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងធំ . . . ទាំងនៅក្នុងជីវិតអ្នក និង ជីវិតរបស់ពួកគេ !



## ចំណុចកណ្តាលនៃផ្ទាំងសីប !

ប្រធាន អុជដូហ្វ មានប្រសាសន៍ថាដំណឹងល្អគឺដូចជាការហាត់សមបាញ់ឲ្យចំទីដៅ ។ យើងត្រូវផ្តោតចិត្តទុកដាក់លើកិច្ចការសំខាន់ៗបំផុត ។ បទបញ្ញត្តិសំខាន់ៗបំផុតនោះគឺត្រូវស្រឡាញ់ព្រះ និង ស្រឡាញ់មនុស្សដទៃ ។ ប្រសិនបើយើងផ្តោតចិត្តទុកដាក់លើរឿងទាំងពីរនេះ នោះយើងអាចបាញ់ចំចំណុចកណ្តាលនៃផ្ទាំងសីបបានគ្រប់ពេលវេលា !

សូមគូសរូបព្រួញនៅក្នុងផ្ទាំងសីបដែលជួយយើងបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះ និង មនុស្សដទៃទៀត ។ សូមគូសសញ្ញា X ពីលើផ្ទាំងសីបដែលមិនមែនជាកិច្ចការល្អត្រូវធ្វើ ។




រចនារូបភាពដោយ ឆាលី ម៉ាក់ស៊ី

សារលិខិតបង្រៀនសួរសុខទុក្ខ

# គោលបំណងនៃសមាគមសង្គ្រោះ

*សូមសិក្សាអត្ថបទនេះប្រកបដោយការអធិស្ឋាន និងស្វែងរកការបំផុសគំនិតដើម្បីដឹងពីអ្វីដែលត្រូវចែកចាយ ។*



*សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ*

ស៊ិស្ទើរ លីនដា ខេ បើតុន ប្រធានសមាគមសង្គ្រោះទូទៅ មានប្រសាសន៍ថា គោលបំណងនៃសមាគមសង្គ្រោះគឺដើម្បី « រៀបចំស្ត្រីសម្រាប់ពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច » ។[1] តាមរយៈសេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះនោះហើយ ដែលយើងរួមចំណែកនៅក្នុង « ផ្នែកដ៏សំខាន់នៅក្នុងកិច្ចការ » របស់យើង ។[2]

ខារ៉ូល អិម ស្ទហ្វិន ទីប្រឹក្សាទីមួយក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅមានប្រសាសន៍ថា សមាគមសង្គ្រោះ « គឺជាកិច្ចការខាងសាច់ឈាម និង ខាងវិញ្ញាណ ។ « នោះគឺជាកិច្ចការដែលស្ត្រីនានាបានធ្វើនៅក្នុងជំនាន់របស់ព្រះអង្គសង្គ្រោះ ហើយជាកិច្ចការដែលយើងបន្តធ្វើ » ។[3]

នៅពេលយើងមើលទៅស្ត្រីសាសន៍សាម៉ារីនៅអណ្ដូងទឹក ដែលបានទុកក្អមទឹកចោល ហើយបានរត់ទៅប្រាប់មនុស្សដទៃថា ព្រះយេស៊ូវគឺជាព្យាការី ( សូមមើល យ៉ូហាន ៤:៦–៤២ ) ឬ នាងភីបេ ដែលបម្រើមនុស្សដទៃយ៉ាងរីករាយពេញមួយជីវិតរបស់នាង ( សូមមើល រ៉ូម ១៦:១–២ ) នោះយើងឃើញពីគំរូរបស់ស្ត្រីនៅក្នុងជំនាន់របស់ព្រះអង្គសង្គ្រោះដែលមានភាពសកម្មក្នុងការមកឯព្រះគ្រីស្ទ ។ ទ្រង់គឺជាអង្គដែលបើកផ្លូវរបស់យើងទៅកាន់ជីវិតអស់កល្បជានិច្ច ( សូមមើល យ៉ូហាន ៣:១៦ ) ។

នៅពេលយើងមើលពីបងប្អូនស្រីត្រួសត្រាយរបស់យើងនៅទីក្រុង ណៅវូ រដ្ឋអិលលីណោយ ដែលបានជួបជុំគ្នានៅក្នុងផ្ទះរបស់ សារ៉ា ឃីមបឹល កាលពីឆ្នាំ ១៨៤២ ដើម្បីបង្កើតអង្គការផ្ទាល់របស់ពួកគាត់ នោះយើងឃើញពីផែនការរបស់ព្រះ ក្នុងការនាំឲ្យសមាគមសង្គ្រោះមានរូបរាងឡើង ហើយធ្វើតាមអ្នកកាន់បព្វជិតភាព ។ បន្ទាប់ពី អ៊ីឡៃស្សា អរ ស្នូ បានសរសេរច្បាប់នោះហើយ ព្យាការី យ៉ូសែប ស្ម៊ីធ បានពិនិត្យច្បាប់នោះឡើងវិញ ។ លោកបានដឹងថា សាសនាចក្រ នឹងមិនអាចបានរៀបចំឡើងបានពេញលេញឡើយ លុះត្រាក្រុមស្ត្រីត្រូវបានបង្កើតឡើង ។ លោកបានមានប្រសាសន៍ថា ព្រះអម្ចាស់បានទទួលយកការបូជារបស់ពួកគេ ប៉ុន្តែមានអ្វីៗជាច្រើនដែលកាន់តែប្រសើរ ។ លោកមានប្រសាសន៍ថា « ខ្ញុំនឹងរៀបចំស្ត្រីនៅក្រោមបព្វជិតភាព ទៅតាមគន្លងនៃបព្វជិតភាព » ។[4]

« សមាគមសង្គ្រោះមិនត្រឹមតែជាក្រុមមួយផ្សេងទៀតរបស់ស្ត្រី ដែលព្យាយាមធ្វើកិច្ចការល្អៗនៅក្នុងពិភពលោកនេះឡើយ ។ វាខុសពីនោះ ។ វាគឺជា ‹ ក្រុមមួយដ៏ប្រសើរ › ដោយសារក្រុមនេះត្រូវបានបង្កើតឡើងក្រោមសិទ្ធិអំណាចបព្វជិតភាព ។ អង្គការនេះគឺជាជំហានដ៏ចាំបាច់នៅក្នុងការបើកបង្ហាញកិច្ចការរបស់ព្រះនៅលើផែនដីនេះ » ។[5]

**ខគម្ពីរ និង ព័ត៌មានបន្ថែម**
គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:២–៣, ១០; ៨៨:៧៣,គេហទំព័រ reliefsociety.lds.org

កំណត់ចំណាំ
១. លីនដា ខេ បើតុន នៅក្នុង Sarah Jane Weaver « Relief Society Celebrates Birthday and More March 17 » *Church News* ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៥ news.lds.org ។
២. លីនដា ខេ បើតុន នៅក្នុង Weaver « Relief Society Celebrates Birthday » ។
៣. ខារ៉ូល អិម ស្ទហ្វិន នៅក្នុង Weaver « Relief Society Celebrates Birthday » ។
៤. យ៉ូសែប ស្ម៊ីធ នៅក្នុង *Daughters in My Kingdom: The History and Work of Relief Society* ( ឆ្នាំ ២០១១ ) ទំព័រ ១១–១២ ។
៥. *Daughters in My Kingdom* ទំព័រ ១៦ ។

សូមពិចារណាអំពីសំណួរនេះ

តើសមាគមសង្គ្រោះជួយស្ត្រីបំពេញតួនាទីរបស់ព្រះវរបិតាសួគ៌ដែលមានសម្រាប់ពួកគេ ហើយដឹកនាំពួកគេឆ្ពោះទៅរកជីវិតដ៏នៅអស់កល្បជានិច្ចបានដោយរបៀបណា ?

# សៀវភៅកំណត់ចំណាំសន្និសីទខែ តុលា ឆ្នាំ ២០១៦

*« អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ . . . ទោះជាដោយសំឡេងរបស់យើងផ្ទាល់ ឬ ក៏ដោយសំឡេងនៃពួកអ្នកបម្រើរបស់យើងក្តីគឺដូចតែគ្នា » ( គ. និង ស. ១:៣៨ ) ។*

*នៅពេលអ្នកមើលសន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០១៦ ឡើងវិញនោះអ្នកអាចប្រើប្រាស់ទំព័រទាំងនេះ ( និង សៀវភៅកំណត់ចំណាំសន្និសីទនៅច្បាប់ចេញផ្សាយនាពេលខាងមុខទៀត ) ដើម្បីជួយអ្នកសិក្សា ហើយ អនុវត្តការបង្រៀនថ្មីៗរបស់ព្យាការី និង សាវកដែលរស់នៅ ព្រមទាំងថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ ។*



**ការដកស្រង់គោលលទ្ធិសំខាន់ៗ**

## ការប្រែចិត្តគឺជាអំណោយរបស់ព្រះចំពោះយើង

« ពាក្យមួយដែលយើងស្តាប់ឮញឹកញាប់នាសព្វថ្ងៃនេះ គឺថាសេចក្តីស្រឡាញ់របស់ព្រះគឺ ‹ គ្មានលក្ខខណ្ឌ › ។ ក្នុងន័យមួយថា ការពិតអ្នកពិពណ៌នាថា *គ្មានលក្ខខណ្ឌ* គឺពុំមាននៅក្នុងគម្ពីរទេ ។ . . .

ព្រះនឹងស្រឡាញ់យើងជានិច្ច ប៉ុន្តែទ្រង់មិនអាចសង្គ្រោះយើងនៅក្នុងអំពើបាបរបស់យើងបានទេ ។ សូមចងចាំពាក្យរបស់អាមូលេកថ្លែងទៅកាន់ស៊ីអែសរ៉ុមថា ព្រះអង្គសង្គ្រោះនឹងមិនសង្គ្រោះរាស្ត្ររបស់ទ្រង់ *ក្នុង* អំពើបាបរបស់ពួកគេទេ ប៉ុន្តែ *ពី* អំពើបាបរបស់ពួកគេវិញ យើងមិនស្អាតស្អំដោយសារអំពើបាប ដោយមូលហេតុថា ‹ គ្មានអ្វីដែលមិនស្អាតអាចទទួលគ្រងនគរស្ថានសួគ៌ › [ អាលម៉ា ១១:៣៧ ] ឬអាស្រ័យនៅក្នុងវត្តមានរបស់ព្រះបានឡើយ ។ . . .

ចេញមកពីព្រះគម្ពីរមរមន យើងរៀនថាព្រះរាជបំណងនៃការរងទុក្ខរបស់ព្រះគ្រីស្ទ — ជាការបើកបង្ហាញសេចក្តីស្រឡាញ់ដ៏ធំធេងរបស់ទ្រង់គឺ — ‹ ដើម្បីនាំមកនូវចិត្តក្តួលមេត្តាដែលមានអំណាចលើសេចក្តីយុត្តិធម៌ ដើម្បីនឹងនាំមកនូវមធ្យោបាយទាំងឡាយដល់មនុស្ស ឲ្យគេមានសេចក្តីជំនឿចំពោះការប្រែចិត្ត › [ អាលម៉ា ៣៤:១៥ ] ។ . . .

ការប្រែចិត្តគឺជាអំណោយរបស់ទ្រង់ចំពោះយើង បានទិញដោយតម្លៃដ៏ថ្លៃបំផុត » ។

អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « នៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំ » ***Liahona,*** ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ៤៨ ។

**ការសន្យារបស់ព្យាការី**



### ផែនការនៃសេចក្តីសង្គ្រោះ

« ផ្នែកសំខាន់នៃផែនការ [ នៃសេចក្តីសង្គ្រោះ ] គឺព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ ។ បើគ្មានការពលិកម្មធួនរបស់ទ្រង់ទេ នោះមនុស្សទាំងអស់នឹងត្រូវវង្វេង ។ ទោះជាយ៉ាងណា វាពុំគ្រប់គ្រាន់ទេ បើគ្រាន់តែជឿទៅលើទ្រង់ និងបេសកកម្មរបស់ទ្រង់នោះ ។ យើងចាំបាច់ត្រូវធ្វើការ ហើយរៀន ស្រាវជ្រាវ និងអធិស្ឋាន ប្រែចិត្ត ហើយកែលម្អ ។ យើងចាំបាច់ត្រូវស្គាល់ក្រឹត្យវិន័យរបស់ព្រះ ហើយរស់នៅតាមក្រឹត្យវិន័យទាំងនោះ ។ យើងចាំបាច់ត្រូវទទួលនូវពិធីបរិសុទ្ធសង្គ្រោះរបស់ទ្រង់ ។ បើគ្រាន់តែធ្វើដូច្នេះ នោះយើងនឹងបានទទួលសុភមង្គលដ៏ពិត ដ៏អស់កល្បជានិច្ច ។

« យើងមានពរដែល *មាន* សេចក្តីពិត ។ យើងមានកាតព្វកិច្ចដើម្បី *ចែកចាយ* សេចក្តីពិត ។ ចូរយើង *រស់នៅតាម* សេចក្តីពិតដើម្បីយើងអាចទទួលបាននូវអ្វីៗទាំងអស់ដែលព្រះវរបិតាមានសម្រាប់យើង ។ ទ្រង់ពុំធ្វើអ្វីក្រៅពីដើម្បីជាប្រយោជន៍របស់យើងនោះទេ ។ ទ្រង់បានប្រាប់យើងថា ‹ នេះហើយជាកិច្ចការរបស់យើង និង សិរីល្អរបស់យើង — គឺដើម្បីនាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស › [ ម៉ូសេ ១:៣៩ ] ។

« ខ្ញុំសូមថ្លែងទីបន្ទាល់អំពីអំណោយដ៏មហិមាដែលជាផែនការរបស់ព្រះវរបិតាសម្រាប់យើង ដោយអស់ពីជម្រៅនៃព្រលឹងរបស់ខ្ញុំ និងដោយរាបសាបំផុត ។ វាគឺជាផ្លូវមួយដ៏ឥតខ្ចោះទៅកាន់ភាពសុខសាន្ត និងសុភមង្គល ទាំងនៅទីនេះ និងនៅក្នុងបរលោកនាយ » ។

ប្រធាន ថូម៉ាស អេស ម៉នសុន « ផ្លូវដ៏ឥតខ្ចោះឆ្ពោះទៅកាន់សុភមង្គល » ***Liahona,*** ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ៨០–៨១ ។



# ដង្វាយធួនដ៏ឥតខ្ចោះនៃព្រះគ្រីស្ទ

« ព្រះអង្គសង្គ្រោះ ជាអង្គព្យាបាលដ៏កំពូលមានព្រះចេស្ដាផ្លាស់ប្ដូរដួងចិត្តរបស់យើង ហើយផ្ដល់នូវការសង្គ្រោះដ៏និរន្ដរដល់យើង ចេញពីទុក្ខសោកដែលបណ្ដាលមកពីអំពើបាបរបស់យើងផ្ទាល់ ។ . . .

« . . . [ ទ្រង់ ] អាចលួងលោមចិត្ត និង ពង្រឹងដល់យើង នៅពេលយើងជួបការឈឺចាប់ ដោយសារតែទង្វើដ៏អសុចរិតរបស់អ្នកដទៃ ។ . . .

« . . . [ ទ្រង់ ] អាចលួងលោមចិត្ត និងគាំទ្រយើងនៅពេលយើងជួប ‹ ភាពពិតនៃជីវិតរមែងស្លាប់ › ដោយការឈឺចាប់ ដូចជាភាពអន្ដរាយ, ជំងឺសសៃប្រសាទ, ជំងឺ, ការឈឺរ៉ាំរ៉ៃ, និង សេចក្ដីស្លាប់ ។ . . .

ព្រះអង្គសង្គ្រោះ [ មានបន្ទូលថា ] ៖ . . .

« ‹ . . . បើសិនជាអ្នករាល់គ្នាមករកយើង នោះអ្នករាល់គ្នានឹងមានជីវិតដ៏នៅអស់កល្បជានិច្ច ។ មើលចុះ ដៃនៃសេចក្ដីមេត្តាករុណារបស់យើងសន្ធឹងទៅរកអ្នក ហើយអស់អ្នកណាដែលមក . . . នោះយើងនឹងទទួល › [ នីហ្វៃទី៣ ៩:១៤ ] » ។

ខារ៉ូល អិម ស្ទីហ្វិនស៍ ទីប្រឹក្សាទីមួយក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ « អង្គព្យាបាលដ៏កំពូល » ***Liahona,*** ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ១០, ១១, ១២ ។



ព្រះចេស្ដាដើម្បីផ្លាស់ប្ដូរ ដោយម៉ៃខល ធី. ម៉ម

« អ្វីដែលប្រឆាំងនឹងព្រះគ្រីស្ទ ឬ គោលលទ្ធិទ្រង់នឹងបង្អាក់អំណររបស់យើង » ។

ប្រធាន រ័សុល អិម ណិលសុន ប្រធាន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « អំណរ និង ការរស់រានខាងវិញ្ញាណ » ***Liahona,*** ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ៨៤ ។

## ចូរមកតាមទ្រង់

អ្នកឡើងនិយាយមួយចំនួនបានលើកទឹកចិត្តយើង ឲ្យអភិវឌ្ឍលក្ខណៈដូចជាព្រះគ្រីស្ទ ហើយចងចាំព្រះអង្គសង្គ្រោះនៅពេលយើងថ្វាយបង្គំនៅថ្ងៃឈប់សម្រាក ។ សូមប្រើប្រាស់ច្បាប់ចេញផ្សាយខែ វិច្ឆិកា ឆ្នាំ ២០១៦ ឬ មើលគេហទំព័រ conference.lds.org ដើម្បីអានប្រសាសន៍របស់ពួកលោក ។

- តើខ្ញុំអាចអនុវត្តសេចក្ដីស្រឡាញ់ និងការបម្រើជាគ្រិស្ដសាសនិកយ៉ាងដូចម្ដេច ? — សូមមើល រ៉ូប៊ើត ឌី ហេល « ‹ ចូរមកតាមខ្ញុំចុះ › តាមរយៈការអនុវត្តសេចក្ដីស្រឡាញ់ និងការបម្រើជាគ្រិស្ដសាសនិក » ទំព័រ ២២ ។
- តើខ្ញុំអាចក្លាយជាគ្រូបង្រៀនតាមផ្ទះកាន់តែប្រសើរឡើងដោយរបៀបណា ? — សូមមើល ជែហ្វ្រី អ័រ ហូឡិន « សារទូតនៃសាសនាចក្រ » ទំព័រ ៦១ ។
- តើខ្ញុំអាចអភិវឌ្ឍការថ្វាយបង្គំដោយស្មោះត្រង់អស់ពីចិត្តនៅថ្ងៃឈប់សម្រាកយ៉ាងដូចម្ដេច ? — សូមមើល ឌីន អិម ដេវីស « ពរជ័យនៃការថ្វាយបង្គំ » ទំព័រ ៩៣ ។
- តើយើងអាចធ្វើឲ្យការទទួលទានសាក្រាម៉ង់កាន់តែប្រកបដោយអត្ថន័យយ៉ាងដូចម្ដេច ? — សូមមើល ភីទើរ អែហ្វ ម៉ើរស្ស « ពិធីសាក្រាម៉ង់អាចជួយពួកយើងឲ្យបានបរិសុទ្ធ » ទំព័រ ៨៥ ។

ដើម្បីអាន ទស្សនា ឬ ស្ដាប់សុន្ទរកថាសន្និសីទទូទៅ សូមចូលទៅកាន់គេហទំព័រ **conference.lds.org** ។

# យើងជឿថាដំណឹងល្អនឹងមានពាសពេញផ្ទៃផែនដី

មានសមាជិកតែប្រាំមួយនាក់គត់ កាលសាសនាចក្រនេះបានបង្កើតឡើងនៅក្នុងឆ្នាំ ១៨៣០ នៅក្នុងទីក្រុងតូចមួយនៅរដ្ឋ នូវយ៉ោក ស.រ.អា. ។ ចាប់តាំងពីនោះមក សាសនាចក្របានកើនសមាជិកជាង ១៥.៥ លាននាក់ ដែលមានវួដ និង សាខានៅក្នុងបណ្ដាប្រទេសជាង ១៥០ ។ វឌ្ឍនភាពនេះបានបំពេញការព្យាករក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលថាសាសនាចក្រនេះនឹងត្រូវបន្តរីកចម្រើនរហូតដល់បានពេញផែនដីទាំងមូល ( សូមមើល ដានីយ៉ែល ២:៣១–៤៥ ) ។ សាសនាចក្រនេះ—ដែលជានគរព្រះនៅលើផែនដី—ត្រូវបានពិពណ៌នាថាជាថ្ម « ដាប់ផ្ដាច់ចេញពីភ្នំឥតមានដៃអ្នកណាធ្វើឡើយ » ( ដានីយ៉ែល ២:៤៥ ) បង្ហាញថាវាជាកិច្ចការរបស់ព្រះមិនមែនជាកិច្ចការរបស់មនុស្សឡើយ ។

ទោះបីជាឥទ្ធិពលរបស់សាសនាចក្រមានពាសពេញផ្ទៃផែនដីក្ដី សមាជិកសាសនាចក្រនឹងនៅតែមានតិចតួចនៅឡើយ ។ នីហ្វៃបានឃើញជាមុនអំពីរឿងនេះ ហើយបានសរសេរពីជំនាន់របស់យើងថា « ខ្ញុំបានឃើញសាសនាចក្រនៃកូនចៀមនៃព្រះ ហើយសមាជិកនៃសាសនាចក្រមានចំនួនតិចណាស់ » ពីព្រោះមកពីសេចក្ដីទុច្ចរិត ( នីហ្វៃទី១ ១៤:១២ ) ។ នៅគ្រានៃការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទខិតកាន់តែជិត នោះពិភពលោកនឹងប្រែកាន់តែទុច្ចរិត ហើយ « មនុស្សនឹងកាន់តែចាប់អារម្មណ៍តិចទៅៗក្នុងការធ្វើជាពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។[1]

ប៉ុន្តែនីហ្វៃក៏បានឃើញជាមុនផងដែរ « ថាសាសនាចក្រនៃកូនចៀម ដែលជាពួកបរិសុទ្ធរបស់ព្រះក៏មាននៅពាសពេញលើផ្ទៃផែនដីដែរ » ( នីហ្វៃទី១ ១៤:១២ ) ។ វួដ និង សាខាអាចមាននៅទូទាំងពិភពលោក សន្និសីទទូទៅត្រូវបានបកប្រែជាង ៩០ ភាសា ហើយមានអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងជិត ៧៥,000 នាក់ ដែលកំពុងចែកចាយដំណឹងល្អនៅក្នុងបេសកកម្មចំនួន ៤១៨ ។ ដំណឹងល្អក៏កំពុងត្រូវបានចែកចាយទូទាំងពិភពលោកតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និង គេហទំព័រដូចជា Mormon.org និង LDS.org ។

កិច្ចខិតខំទាំងនេះមានសារៈសំខាន់ និង ពង្រីកឲ្យច្រើនឡើង ប៉ុន្តែជារឿយៗពុំសូវទទួលបានការចាប់អារម្មណ៍ឡើយ ។ « កិច្ចការរបស់ព្រះអម្ចាស់គឺជាកិច្ចការដ៏ធំមហិមា និង អស្ចារ្យ ប៉ុន្តែកិច្ចការនេះបន្តឆ្ពោះទៅមុខ ជាពិសេសគ្មានការចាប់អារម្មណ៍ពីថ្នាក់ដឹកនាំនយោបាយរបស់មនុស្សជាតិ វប្បធម៌ និង ថ្នាក់ដឹកនាំផ្នែកអប់រំឡើយ ។ កិច្ចការនេះរីកចម្រើនឡើងពីក្នុងចិត្តរបស់មនុស្សម្នាក់ៗទៅមនុស្សម្នាក់ទៀត និង ពីគ្រួសារមួយទៅគ្រួសារមួយទៀត ដោយស្ងាត់ៗ និង សន្សឹមៗ ហើយសារលិខិតដ៏ពិសិដ្ឋនេះប្រទានពរដល់មនុស្សនៅគ្រប់ទីកន្លែង » ។[2]

ថ្មដែលបានព្យាករតាំងពីយូរយារមកហើយនោះពិតជាកំពុងរមៀលចេញទៅ ហើយនៅពេលយើងធ្វើផ្នែករបស់យើង នោះដំណឹងល្អនឹងបន្តផ្សព្វផ្សាយ ហើយមានពាសពេញផ្ទៃផែនដីទាំងមូល ( សូមមើល ដានីយ៉ែល ២:៣១–៤៥ ) ។ ■

ដើម្បីរៀនបន្ថែមទៀតអំពីជោគវាសនារបស់សាសនាចក្រនេះ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥ ហ្គរដុន ប៊ី ហ៊ិងគ្លី « Stone Cut Out of the Mountain » ( សន្និសីទទូទៅខែ តុលា ឆ្នាំ ២០០៧ ) អិល វិតនី ក្លេតុន « The Time Shall Come » ( សន្និសីទទូទៅខែ តុលា ឆ្នាំ ២០១១ ) ។

**កំណត់ចំណាំ**

១. រ័សុល អិម ណិលសុន « Stand as True Millennials » *Liahona* ខែ តុលា ឆ្នាំ ២០១៦ ទំព័រ ៥០ ។

២. អិល វិតនី ក្លេតុន « The Time Shall Come » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ១៣ ។



**ជោគវាសនានៃសាសនាចក្រនេះ**

« នៅយប់នេះ អ្នកឃើញមានបព្វជិតភាពតែបន្តិចទេ ប៉ុន្តែសាសនាចក្រនេះនឹងមានពេញនៅអាមេរិកខាងជើង និង ខាងត្បូង—វានឹងមានពេញផែនដីទាំងមូល » ។

ព្យាការីយ៉ូសែប ស្ម៊ីធ ( ឆ្នាំ ១៨០៥–៤៤ ) នៅក្នុងការប្រជុំបព្វជិតភាពក្នុងឆ្នាំ ១៨៣៤ នៅក្នុង ***Teachings of Presidents of the Church: Joseph Smith*** ( ឆ្នាំ ២០០៧ ) ទំព័រ ១៣៧ ។

**តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជួយឲ្យដំណឹងល្អ ត្រូវបានផ្សព្វផ្សាយឆ្ពោះទៅមុខនោះ ?**



*ការគោរពបទបញ្ញត្តិ និង ការពង្រឹងទីបន្ទាល់របស់យើង ផ្ដល់ជាគ្រឹះដល់យើង ដើម្បីជួយផ្សព្វផ្សាយដំណឹងល្អ ។*



*ការបំពេញការហៅបម្រើរបស់យើង ជួយពង្រឹងសាសនាចក្រនៅក្នុងតំបន់ក្នុងមូលដ្ឋានរបស់យើង ។*



*យើងអាចជួយផ្សព្វផ្សាយដំណឹងល្អ តាមរយៈ ការនិយាយយ៉ាងសាមញ្ញៗ អំពីដំណឹងល្អជាមួយមនុស្សទូទៅ ។*



*ការបង្រៀនដំណឹងល្អដល់គ្រួសាររបស់យើង ពង្រឹងពួកគេឲ្យរស់នៅដោយស្មោះត្រង់នៅក្នុងពិភពលោកដែលបង្រៀនផ្ទុយពីនោះ ។*



*នៅក្នុងព្រះវិហារបរិសុទ្ធ យើងអាចធ្វើពិធីបរិសុទ្ធសម្រាប់មនុស្សដែលបានស្លាប់ទៅដោយពុំបានទទួលដំណឹងល្អនៅក្នុងជីវិតនេះ ។*

រចនារូបភាពដោយ ជេ បើត ចិបសុន

# កូនចង់រស់នៅជាមួយក្រុមគ្រួសារយើងជារៀងរហូត !

ដោយ លីអនហ៊ីណា អាដាមមែស ឌែ អ៊ូប្រី

*សេចក្ដីជំនឿរបស់ក្មេងអាយុប្រាំមួយឆ្នាំ បានជួយខ្ញុំឲ្យមានសេចក្ដីជំនឿជាថ្មីម្ដងទៀត ។*

កាលខ្ញុំអាយុ ២២ ឆ្នាំជីវិតរបស់ខ្ញុំបានជួបនឹងបញ្ហាដែលពុំបានព្រៀងទុក ៖ គឺម្ដាយរបស់ខ្ញុំបានទទួលមរណភាព ។ គាត់ និង ឪពុកខ្ញុំជាមនុស្សដែលមានសេចក្ដីជំនឿខ្លាំងណាស់ ហើយពួកគាត់បានចិញ្ចឹមខ្ញុំនៅក្នុងដំណឹងល្អ ។ បន្ទាប់ពីមរណភាពរបស់គាត់ទៅ ឪពុករបស់ខ្ញុំបានប្ដូរទៅនៅសហរដ្ឋអាមេរិកដែលឆ្ងាយពីប្រទេសរបស់យើង ។ វេលាចេះតែកន្លងទៅ ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍ឯកាដោយសារខ្ញុំជាកូនទោលរបស់ឪពុកម្ដាយខ្ញុំ ។ ខ្ញុំគ្មានម្ដាយនៅជាមួយខ្ញុំនៅលើផែនដីនេះទៀតឡើយ ហើយឪពុកខ្ញុំបានរស់នៅសែនឆ្ងាយ ខ្ញុំអាចជួបគាត់បានតែបីសប្ដាហ៍ប៉ុណ្ណោះក្នុងមួយឆ្នាំ ។

ដោយសារតែអារម្មណ៍នោះហើយ ទើបខ្ញុំបានចាប់ផ្ដើមស្វែងរកការលួងលោមចិត្តកាន់តែច្រើនឡើងពី « មិត្តភក្ដិ » របស់ខ្ញុំដែលនៅមហាវិទ្យាល័យ និង ពីការិយាល័យដែលខ្ញុំធ្វើការ ។ យូរៗទៅ ខ្ញុំបានចាប់ផ្ដើមមើលឃើញពីសុភមង្គលក្លែងក្លាយនៅខាងសាច់ឈាម ។ ខ្ញុំបានឈប់ទៅព្រះវិហារ ហើយបន្តិចម្ដងៗខ្ញុំបានអសកម្មទាំងស្រុង ។ ក្រោយមកខ្ញុំបានរៀបការជាមួយយុវជនដ៏អស្ចារ្យម្នាក់ ទោះបីជាគាត់មានគោលការណ៍ដ៏ល្អៗជាច្រើនក្ដី តែគាត់មិនបានស្គាល់ដំណឹងល្អឡើយ ។ យើងមានកូនបីនាក់ ៖ លេអា អ៊ីសាក និង អ៊ីម៉ាអែល ។

ក្នុងខែតុលាមួយ ឪពុករបស់ខ្ញុំបានមកសួរសុខទុក្ខ និង មកមើលកូនតូចដែលទើបកើត ។ អំឡុងពេលមកសួរសុខទុក្ខនោះ កូនស្រីលេអាអាយុប្រាំមួយឆ្នាំរបស់ខ្ញុំ បានសួរជីតារបស់នាងថា ហេតុអ្វីគាត់មិនដែលនាំភរិយារបស់គាត់មកជាមួយគាត់ ។ ក្រោយមកឪពុករបស់ខ្ញុំបានពន្យល់នាងថា ជីដូននាងមានកន្លែងដ៏ពិសេសមួយនៅជិតនឹងព្រះវរបិតាសួគ៌ហើយ ។ មិនយូរប៉ុន្មានបន្ទាប់ពីឪពុកខ្ញុំបានត្រឡប់ទៅវិញ លេអា បានទទូចប្រាប់ខ្ញុំថា « ម៉ាក់ កូនចង់ជួបលោកយាយ ។ កូនដឹងថាគាត់នៅឯស្ថានសួគ៌ ប៉ុន្តែកូនក៏ចង់ឲ្យពួកយើងនៅទីនោះជាមួយគ្នានៅថ្ងៃណាមួយដែរ—ទាំងលោកតា និង លោកយាយ លោកប៉ាអ៊ីសាក អ៊ីម៉ាអែល ទាំងអ្នកម៉ាក់ និង ខ្ញុំផងដែរ ។ កូនចង់រស់នៅជាមួយក្រុមគ្រួសារយើងជារៀងរហូត ។ កូនចង់ឲ្យពួកយើងនៅតែធ្វើជាគ្រួសារនៅទីនោះ ដូចដែលយើងមាននៅលើផែនដីនេះ ដូច្នេះយើងអាចលេងជាមួយលោកយាយ ! »

ខ្ញុំមិនដឹងថាត្រូវនិយាយអ្វីនោះទេ ។ ខ្ញុំបានយកដៃស្ទាបមុខដ៏គួរឲ្យស្រឡាញ់ និងបរិសុទ្ធរបស់នាង ហើយដើរចេញទៅបន្ទប់ដេករបស់ខ្ញុំ ។ ខ្ញុំបានលុតជង្គង់ចុះ ហើយយំយ៉ាងខ្លាំង ។ ខ្ញុំបានទូលសូមការអភ័យទោសពីព្រះវរបិតាសួគ៌ ។ ខ្ញុំបានដឹងថាខ្ញុំបានដើរចេញពីផ្លូវដែលនឹងធ្វើឲ្យពួកយើងរស់នៅជាមួយគ្នាជាគ្រួសារអស់កល្បជានិច្ច ។ ខ្ញុំពុំបានបំពេញការទទួលខុសត្រូវរបស់ខ្ញុំ ដើម្បីនាំពួកគេដើរលើផ្លូវត្រូវ ហើយខ្ញុំពុំបាននិយាយជាមួយស្វាមីខ្ញុំអំពីដំណឹងល្អឡើយ ។



**ចងទុកនៅស្ថានសួគ៌**

« នៅក្នុងការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលទៅកាន់ពេត្រុស ជាប្រធានសាវករបស់ទ្រង់ អំពីអំណាចនៃការផ្សារភ្ជាប់ក្រុមគ្រួសារ ទ្រង់បានមានបន្ទូលថា ‹ បើអ្នករាល់គ្នាចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ហើយបើស្រាយអ្វីៗនៅផែនដី នោះក៏នឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ › ( ម៉ាថាយ ១៦:១៩ ) ។

មានតែនៅក្នុងនគរសេឡេស្ទាលប៉ុណ្ណោះ ទើបយើងអាចរស់នៅជាក្រុមគ្រួសារជានិរន្តរ៍បាន ។ នៅទីនោះ យើងអាចនៅជាក្រុមគ្រួសារក្នុងវត្តមាននៃព្រះវរបិតាសួគ៌ និង ព្រះអង្គសង្គ្រោះរបស់យើងបាន » ។

ប្រធាន ហិនរី ប៊ី. អាវរិង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ « **Families Can Be Together Forever** » *Liahona* ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៤ ។

រចនារូបភាពដោយ ឃែលី ម៉ាកម៉ូរីស



នៅពេលខ្ញុំក្រោកឈរឡើងវិញ នោះខ្ញុំបានទាក់ទងទៅថ្នាក់ដឹកនាំសាសនាចក្រ ហើយគាត់បានឲ្យខ្ញុំទាក់ទងជាមួយអែលឌើរនៅក្នុងវួដរបស់ខ្ញុំ ។ នាយប់បន្ទាប់មកពួកគេបានមក ហើយបង្រៀនស្វាមីរបស់ខ្ញុំ ។ ចាប់តាំងពីយប់នោះមកជីវិតរបស់យើងបានផ្លាស់ប្ដូរជារៀងរហូត ។ ឥឡូវនេះយើងចូលរួមព្រះវិហារជាគ្រួសាររៀងរាល់ថ្ងៃអាទិត្យ ។ ខ្ញុំមានការហៅបម្រើដែលអនុញ្ញាតឲ្យខ្ញុំជួយបងប្អូនស្រីដែលមិនសូវសកម្ម ។ យើងក៏កំពុងរៀបចំខ្លួនចូលព្រះវិហារបរិសុទ្ធផងដែរ ។

ជួនកាលព្រះវិញ្ញាណនៃព្រះដឹកនាំយើងតាមរយៈអស់អ្នកដែលយើងរំពឹងតិចតួចលើពួកគាត់ ។ លើកនេះវាបានកើតឡើងតាមរយៈកូនស្រីអាយុប្រាំមួយឆ្នាំរបស់ខ្ញុំ ។ ឥឡូវនេះ ខ្ញុំដឹងថាតាមរយៈការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ នោះខ្ញុំអាចរស់នៅជាមួយក្រុមគ្រួសាររបស់ខ្ញុំជារៀងរហូត ។ ■

*អ្នកនិពន្ធរស់នៅ សាន់តូ ដូមីងហ្គោ សាធារណរដ្ឋ ដូមីនីក ។*

# ការពិចារណា អំពីសំណួរពិភាក្សារបស់យើង

**ដោយ ធិឱ បានិស**
នាយកដ្ឋានបព្វជិតភាព និង គ្រួសាររបស់សាសនាចក្រ

សូមស្រមៃថា អ្នកកំពុងអង្គុយបរិភោគអាហារថ្ងៃត្រង់ជាមួយមិត្តភក្តិមួយចំនួន ហើយពិភាក្សាគ្នាអំពីខ្សែភាពយន្តដែលអ្នកបានមើលជាមួយគ្នា ។ ក្រោយមកមិត្តភក្តិម្នាក់និយាយថា « តើមាននរណាអាចប្រាប់ខ្ញុំបានទេថា តើឈុតឆាកដែលសំខាន់បំផុតនៅក្នុងខ្សែភាពយន្តនោះគឺនៅត្រង់ណា ? »

អ្នកប្រហែលជាមានការងឿងឆ្ងល់ចំពោះសំណួរនោះបន្តិច អ្នកគិតមួយសន្ទុះ ហើយនិយាយថា ឈុតឆាកចុងក្រោយគេប្រហែលជាឈុតសំខាន់ខ្លាំងបំផុត ។ មិត្តភក្តិរបស់អ្នកនិយាយថា « នោះគឺជាយោបល់ល្អ ។ ប៉ុន្តែឈុតនោះពុំមែនជាអ្វីដែលខ្ញុំគិតនោះទេ ។ តើមាននរណាគិតថាឈុតណាទៀត ? តោះយើងស្ដាប់អ្នកដែលមិនទាន់បានចែកចាយនៅឡើយ » ។

យើងពុំនិយាយគ្នាបែបនេះឡើយក្នុងចំណោមមិត្តភក្តិរបស់យើង ប៉ុន្តែដោយហេតុផលមួយចំនួនអារម្មណ៍បែបនេះក៏កើតមានឡើងជារឿយៗនៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យផងដែរ ។ ក្នុងនាមជាគ្រូបង្រៀនជូនកាលយើងនិយាយអ្វីមួយក្នុងរបៀបដែលចម្លែក និង បង្ខាំងមិនឲ្យមានការសន្ទនាជំនួសឲ្យការពិភាក្សាអំពីសេចក្ដីពិតនៃដំណឹងល្អដោយងាយៗ និង ដោយអារម្មណ៍ល្អ ។ យើងសង្ឃឹមថា សមាជិកក្នុងថ្នាក់ទទួលអារម្មណ៍ថា ពួកគេស្ថិតនៅក្នុងចំណោមមិត្តភក្តិរបស់ខ្លួន ហើយពួកគេមានអារម្មណ៍ល្អ ក្នុងការចែកចាយគំនិតរបស់ពួកគេទាក់ទងនឹងគោលការណ៍ដែលពួកគេកំពុងរៀន ។ ការចែកចាយបែបនោះអាចយាងព្រះវិញ្ញាណ ហើយធ្វើឲ្យមនុស្សគ្រប់គ្នាមានបទពិសោធន៍កាន់តែល្អ ។

តើយើងអាចប្រាកដថា សំណួរដែលយើងសួរនាំឲ្យមានការពិភាក្សាកាន់តែប្រកបដោយភាពងាយស្រួល និង មានអត្ថន័យយ៉ាងដូចម្ដេច ? មានចំណុចជាច្រើនដែលគ្រូបង្រៀនត្រូវធ្វើ និង មិនត្រូវធ្វើ ដែលមានប្រយោជន៍យ៉ាងខ្លាំង ៖ សូមកុំសួរសំណួរណាដែលមានចម្លើយច្បាស់ៗពេក ។ សូមសួរសំណួរដែលមានចម្លើយច្រើនជាងមួយ ។ សូមកុំសួរសំណួរដែលជារឿងផ្ទាល់ខ្លួនខ្លាំងពេក ។



*សំណួរដែលសំខាន់បំផុតនោះអាចជាសំណួរដែលគ្រូបង្រៀន សួរខ្លួនឯងពីមុនពួកគាត់ទៅបង្រៀន ។*

វាក៏អាចមានប្រយោជន៍ ដោយសួរខ្លួនយើងនូវសំណួរនេះពីមុនយើងចាប់ផ្ដើមរៀបចំសំណួរនៅក្នុងថ្នាក់រៀន ៖ *ហេតុអ្វីខ្ញុំសួរសំណួរនេះ ?*

**ហេតុអ្វីអ្នកសួរសំណួរនេះ ?**

ហេតុផលដែលបង្កប់នៅក្នុងសំណួររបស់យើងធ្វើឲ្យមានការផ្លាស់ប្ដូរដ៏ធំ ។ ឧទាហរណ៍ តើជួនកាលយើងសួរសំណួរ ដោយសារតែយើងមានអ្វីចង់ប្រាប់ ប៉ុន្តែយើងចង់ឲ្យសមាជិកក្នុងថ្នាក់ឆ្លើយវាជំនួសយើង ឬ ? ពិតណាស់ យើងពុំចង់និយាយតែម្នាក់ឯងនោះទេ ប៉ុន្តែយើងចង់ឲ្យចំណុចពិសេសណាមួយកើតឡើង ដូច្នេះជួនកាលយើងសួរសំណួរ ដែលយើងដឹងថានឹងបំផុសឲ្យមានចម្លើយដែលយើងចង់ឮ ។ ផ្នត់គំនិតនេះនាំទៅរកសំណួរដែលពិតជាមានចម្លើយបង្កប់ ដូចជាសំណួរសួរថា « តើការចៀសវាងពីការណ៍អាសគ្រាមជួយអ្នកឲ្យរក្សាគំនិតបានបរិសុទ្ធយ៉ាងដូចម្ដេច ? » ឬ « តើការអធិស្ឋានប្រចាំថ្ងៃសំខាន់ដែរឬទេ ?

មានកាលៈទេសមួយចំនួនដែលវាសមរម្យយ៉ាងខ្លាំងដើម្បីសួរសំណួរ ដែលមានបំណងបំផុសឲ្យមានចម្លើយជាក់លាក់ ។ សំណួរទាំងនោះអាចគូសបញ្ជាក់ពីចំណុចមួយ ឬ ជួយគ្រូបង្រៀនបង្រៀនកាន់តែប្រសើរឡើង ។ ប៉ុន្តែសំណួរបែបនេះពុំទំនងជាជំរុញ ឲ្យមានការពិភាក្សាប្រកបដោយអត្ថន័យ ។

ម្យ៉ាងវិញទៀត ប្រសិនបើយើងសួរសំណួរ ដោយសារយើងពិតជាចង់ដឹងអំពីអ្វីដែលមាននៅក្នុងគំនិត និង ចិត្ត ព្រមទាំងជីវិតរបស់សមាជិកក្នុងថ្នាក់យើង នោះវានឹងបង្ហាញឡើងនៅក្នុងសំណួរដែលយើងសួរនោះឯង ។

សំណួរដែលអញ្ជើញសិស្សក្នុងថ្នាក់ឲ្យមានការសន្ទនាដោយស្មោះត្រង់ ដែលជំរុញឲ្យមានការរៀនសូត្រខាងវិញ្ញាណ រួមមានសំណួរដូចជា « នៅពេលអ្នកអានខគម្ពីរនេះហើយ តើមានអ្វីដែលទាក់ទាញអារម្មណ៍អ្នកដែរឬទេ ? » ឬ « តើអ្នកចាប់អារម្មណ៍អ្វីខ្លះអំពីការអធិស្ឋានរបស់អេណុស ? » ឬ « តើមានបទពិសោធន៍អ្វីខ្លះដែលបានបង្រៀនអ្នកឲ្យទុកចិត្តលើការសន្យារបស់ព្រះអម្ចាស់ ? » ឬ សំណួរភាគច្រើនដែលចាប់ផ្ដើមដោយពាក្យ « តើអ្នកគិតថា . . . ? »

សូមពិចារណាពីឧទាហរណ៍ទាំងនេះ ៖

- ព្រះវិញ្ញាណបានសួរនីហ្វៃ « តើអ្នកប្រាថ្នាអ្វីទៀត ? » ( នីហ្វៃទី១ ១១:១០ ) ។
- ព្រះអង្គសង្គ្រោះបានសួរសិស្សរបស់ទ្រង់ថា « ចុះឯអ្នករាល់គ្នាវិញ តើថាខ្ញុំជាអ្នកណា ? » ( ម៉ាថាយ ១៦:១៥ ) ។
- ហើយទ្រង់មានបន្ទូលទៅ ម៉ាថា ថា « ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត. . . នាងជឿសេចក្ដីនេះឬទេ ? » ( យ៉ូហាន១១:២៥, ២៦ ) ។

សំណួរនីមួយៗនៃសំណួរទាំងនេះបានអញ្ជើញឲ្យមនុស្សគ្រប់គ្នាចែកចាយ ពីអ្វីដែលមាននៅក្នុងចិត្តរបស់ពួកគាត់ ។ ហើយនៅក្នុងករណីនីមួយៗ អ្វីដែលបានកើតឡើងនោះគឺជាបទពិសោធន៍ខាងវិញ្ញាណប្រកបដោយឥទ្ធិពល ។

**សំណួរគឺជាការបង្ហាញនៃសេចក្ដីស្រឡាញ់**

ទោះជឿឬមិនជឿ ការសួរសំណួរដែលជំរុញឲ្យមានការពិភាក្សាកើតឡើងដោយឯកឯងចំពោះមនុស្សស្ទើរតែគ្រប់គ្នា—ទោះបីមនុស្សដែលគិតថាខ្លួនពួកគេមិនមែនជាគ្រូបង្រៀនល្អក្ដី ។ យើងសួរសំណួរនោះដោយពុំបានព្រាងទុកគ្រប់ពេល ដែលយើងមានការសន្ទនាប្រកបដោយអត្ថន័យជាមួយមិត្តភក្ដិ និង គ្រួសារ—ឬ ពេលនិយាយគ្នាអំពីខ្សែភាពយន្តដែលចូលចិត្តនៅពេលបរិភោគអាហារថ្ងៃត្រង់ ។ ប៉ុន្តែនៅពេលយើងឈរនៅពីមុខសិស្ស យើងភ្លេចអស់នូវអ្វីៗដែលកើតឡើងដោយសាមញ្ញនោះ ។

ដូច្នេះប្រហែលជាផ្នែកសំខាន់ក្នុងការសួរសំណួរឲ្យមានការពិភាក្សាល្អនោះគឺគិតចំពោះខ្លួនយើងថា « តើខ្ញុំនឹងសួរសំណួរនេះយ៉ាងដូចម្ដេច ប្រសិនបើយើងមិននៅក្នុងថ្នាក់វិញនោះ—គឺប្រសិនបើយើងអង្គុយនៅក្នុងផ្ទះ និយាយអំពីដំណឹងល្អជាក្រុមជាមួយមិត្តភក្ដិវិញនោះ ? តើខ្ញុំអាចអញ្ជើញពួកគេឲ្យចែកចាយការយល់ដឹង និង អារម្មណ៍របស់ពួកគេយ៉ាងដូចម្ដេច ? » ការបង្រៀនគឺ *ពិតជា* មិនដូចជាការជជែកគ្នាធម្មតាជាមួយមិត្តភក្ដិឡើយ ប៉ុន្តែវាមានចំណុចរួមមួយដូចគ្នា ៖ វាគប្បីត្រូវបានជំរុញដោយការចាប់អារម្មណ៍ដោយស្មោះសរ និង មានក្ដីស្រឡាញ់ស្មោះត្រង់ ។

ដូច្នេះសូមកុំបារម្ភ ប្រសិនបើអ្នកពុំទាន់មានជំនាញក្នុងការបង្កើនការសួរសំណួរឲ្យបានល្អនោះ ។ អ្វីដែលអ្នកអាចធ្វើបាននោះ គឺស្រឡាញ់មនុស្សទាំងអស់ដែលអ្នកបង្រៀន ព្រះវិញ្ញាណនឹងដឹកនាំអ្នក ហើយអ្នកនឹងចេះកាន់តែច្រើន ហើយដឹងកាន់តែច្រើនពីអ្វីដែលត្រូវនិយាយ ។ ប៉ុល បានប្រកាសថា « សេចក្ដីស្រឡាញ់មិនដែលផុតឡើយ » (កូរិនថូសទី១ ១៣:៨) ហើយរឿងនោះវាពិត សូម្បីតែអ្វីមួយដែលសាមញ្ញដូចជាគ្រូបង្រៀនសួរសំណួរនៅក្នុងថ្នាក់រៀន ។ ■

អ្នកអាចរៀនអំពីសំណួរប្រាំមួយយ៉ាងនៅក្នុង « សួរសំណួរដែលបំផុសគំនិត » *ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ* ( ឆ្នាំ ២០១៦ ) ទំព័រ ៣១–៣២ ដែលមាននៅគេហទំព័រ **teaching.lds.org** ។

រចនារូបភាពដោយ [illegible]



## ការយល់ដឹងអំពី

# ព្រះវរបិតា និងព្រះរាជបុត្រា

## មកពីព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា

*ព្រះគម្ពីរនៃវិវរណៈនេះបើកសម្ដែងសេចក្ដីពិតដែលបានបាត់បង់អំពីក្រុមព្រះ និង របៀបដែលយើងអាចរស់នៅជាមួយព្រះអង្គសង្គ្រោះ និង ព្រះវរបិតាសួគ៌ម្ដងទៀត ។*

**ដោយ នំរមែន ដបុលយូ ហ្គាតនើរ**
ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន

ការស្តារឡើងវិញនៃដំណឹងល្អ បានប្រទានចំណេះដឹងដ៏ច្រើនឥតគណនាដល់ពិភពលោកនេះ អំពីនិស្ស័យរបស់ក្រុមព្រះ និង ព្រះរាជបំណងរបស់ពួកទ្រង់ ។ ជាមួយនឹងចំណេះដឹងនេះ សេចក្ដីជំនឿរបស់យើងលើទ្រង់រីកចម្រើន ហើយបំណងប្រាថ្នារបស់យើងដើម្បីគោរពតាមបទបញ្ញត្តិទ្រង់ក៏កើនឡើង ។

ជាពិសេស ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញាជួយយើងរៀនអំពីព្រះយេស៊ូវគ្រីស្ទ ដោយសារគម្ពីរនេះបង្រៀនសេចក្ដីពិតដ៏មានឥទ្ធិពលទាក់ទងនឹង « ទេវភាពរបស់ទ្រង់ ឫទ្ធានុភាពរបស់ទ្រង់ ភាពល្អឥតខ្ចោះរបស់ទ្រង់ សេចក្ដីស្រឡាញ់របស់ទ្រង់ និងព្រះចេស្ដាដ៏ប្រកបដោយសេចក្ដីប្រោសលោះរបស់ទ្រង់ » ( បុព្វកថាព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា ) ។ ព្រះគម្ពីរនៃវិវរណៈទំនើបនេះរួមមាននូវការអញ្ជើញរបស់ព្រះអម្ចាស់ថា « ចូររៀនអំពីយើង ហើយស្ដាប់តាមព្រះបន្ទូលទាំងឡាយរបស់យើងចុះ » ( គ. និង ស. ១៩:២៣ ) ។ ព្រះគម្ពីរនេះអាចធ្វើឲ្យយើងយល់ដឹងកាន់តែជ្រាលជ្រៅអំពីទ្រង់ ទំនាក់ទំនងរបស់យើងជាមួយទ្រង់ អ្វីដែលទ្រង់បានធ្វើសម្រាប់សេចក្ដីប្រោសលោះរបស់យើង និង អ្វីដែលទ្រង់មានព្រះទ័យរំពឹងចង់បានពីពួកយើង ។

ការរចនាផ្ទៃខាងក្រោយ ដោយ ដេវីដ អេ ខ្លូស្ស៊ី © ISTOCK/THINKSTOCK

**នៅក្នុងព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាយើងអាចស្ដាប់ឮសំឡេងរបស់ព្រះយេស៊ូវគ្រីស្ទ ។**

ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា ពុំមែនជាគម្ពីរបុរាណនោះទេ ប៉ុន្តែគម្ពីរនេះមានវិវរណៈដែលបានប្រទានដល់ព្យាការីយ៉ូសែប ស្ម៊ីធ និង អ្នកស្នងតំណែងរបស់លោកនៅក្នុងសម័យទំនើបរបស់យើងនេះ ។ សំឡេងដ៏ទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទគឺកំពុងបានស្ដាប់ឮថាតំណាងឲ្យព្រះវរបិតា ។[១] សំឡេងដំបូងរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទបានកត់ត្រានៅក្នុងគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ច្រើនជាងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ព្រះគម្ពីរមរមន និង មុក្ដាដ៏មានតម្លៃមហិមាដែលរួមបញ្ចូលគ្នា ។[២]

**គ. និង ស. ១៨:៣៣–៣៥** « យើងគឺព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់របស់អ្នក និង ជាព្រះរបស់អ្នកបានមានបន្ទូលថាដូច្នោះ ។ ព្រះបន្ទូលទាំងនេះ ពុំមែនជាពាក្យនៃមនុស្សលោក . . . ប៉ុន្តែជាព្រះបន្ទូលរបស់យើង . . . ដ្បិតជាសំឡេងរបស់យើងនេះហើយ ដែលមានបន្ទូលមកកាន់អ្នក » ។



JOSEPH SMITH JR. RECEIVING REVELATION ដោយ ដាណៃយ៉ែល អេ ល្វីស

*យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈជាច្រើនពីព្រះអង្គសង្គ្រោះ ។*



ព្រះអម្ចាស់បង្ហាញព្រះកាយទ្រង់នៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ ដោយ ដេល ផាសុន

*យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានឃើញព្រះយេស៊ូវគ្រីស្ទនៅក្នុងព្រះវិហារបរិសុទ្ធ ខឺតឡង់ ។*

**ព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាមានដំណើររឿងអំពីអស់អ្នកដែលបានឃើញព្រះ ។**

ជាលទ្ធផលមកពីការនិមិត្តដំបូងនៅក្នុងឆ្នាំ ១៨២០ ក្មេងប្រុសយ៉ូសែប ស្ម៊ីធ បានទទួលចំណេះដឹងមុនគេអំពីអំពីព្រះវរបិតា និង ព្រះរាជបុត្រាដែលមានព្រះជន្មរស់ ។ ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញាកត់ត្រាគំរូបន្ថែមទៀត នៅពេលព្យាការី និង មនុស្សដទៃទៀតបានឃើញព្រះវរបិតា និង ព្រះរាជបុត្រានៅក្នុងការនិមិត្ត ឬ ជួបដោយផ្ទាល់ ។ ដំណើររឿងទាំងនេះដើរតួជាសាក្សីសម័យទំនើបសម្រាប់ពួកយើងថា ពួកទ្រង់មានព្រះជន្មរស់ ហើយថាពួកទ្រង់បានដឹកនាំការស្ដារឡើងវិញនៃដំណឹងល្អ ។

**គ. និង ស. ៧៦:១៩–២៣** បានឃើញព្រះវរបិតា និង ព្រះរាជបុត្រានៅក្នុងការនិមិត្តខែ កុម្ភៈ ឆ្នាំ ១៨៣២ ។

**គ. និង ស. ១៣៧:១–៣** បានឃើញព្រះវរបិតា និង ព្រះរាជបុត្រានៅក្នុងការនិមិត្តខែ មករា ឆ្នាំ ១៨៣៦ ។

**គ. និង ស. ១១០:២–៤** ព្រះយេហូវ៉ាដ៏មហិមាគឺព្រះយេស៊ូវគ្រីស្ទ បានបង្ហាញព្រះកាយនៅក្នុងខែ មេសា ឆ្នាំ ១៨៣៦ ។

**ព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាជួយយើងរៀនអំពីព្រះជាព្រះវរបិតា**

ព្យាការីយ៉ូសែប ស្ម៊ីធបានបង្រៀនដូចនេះ ៖ « នៅពេលយើងយល់ពីលក្ខណៈរបស់ព្រះ ហើយស្គាល់ពីរបៀបមករកទ្រង់ នោះទ្រង់ចាប់ផ្ដើមបើកបង្ហាញស្ថានសួគ៌ដល់យើង . . . នៅពេលយើងត្រៀមខ្លួនរួចជាស្រេចមកកាន់ទ្រង់ នោះទ្រង់ត្រៀមជាស្រេចយាងមកកាន់យើង » ។[៣] ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញាជួយយើងឲ្យខិតកាន់តែជិតព្រះវរបិតាសួគ៌ តាមរយៈការបង្រៀនអំពីនិស្ស័យ លក្ខណៈ និង ព្រះរាជបំណងរបស់ទ្រង់ ។

- **គ. និង ស. ២០:១២, ១៧–១៨** ព្រះជាព្រះវរបិតាគង់នៅជានិរន្ដរ៍ និងជាព្រះដដែលឥតប្រែប្រួល ។
- **គ. និង ស. ៧៦:២០, ២៣** ព្រះវរបិតា និង ព្រះរាជបុត្រាគឺជាតួអង្គផ្សេង និងដាច់ដោយឡែកពីគ្នា ។
- **គ. និង ស. ៩៣:៣–៥** ព្រះវរបិតា និង ព្រះរាជបុត្រាគឺតែមួយ ។
- **គ. និង ស. ១៣០:២២** ព្រះវរបិតា និង ព្រះរាជបុត្រាមានរូបកាយជាសាច់ និងឆ្អឹង ។
- **គ. និង ស. ១៣៨:៣–៤** ព្រះវរបិតាសួគ៌មានព្រះទ័យស្រឡាញ់កូនចៅរបស់ទ្រង់ដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់ ដើម្បីសង្គ្រោះមនុស្សលោក ។

ប្រភពគំនូរ ខ្ញុំឃើញកូនមនុស្សឈរនៅខាងស្ដាំព្រះ ដោយ វ៉លធើ រេន



*អំឡុងពេលត្រូវគេចោលដុំថ្មរហូតដល់ស្លាប់ នោះស្ទេផានបានឃើញព្រះវរបិតា និងព្រះរាជបុត្រា ។*

ប្រភពផ្ទាំងគំនូរ ម៉ូសេបានឃើញព្រះយេហូវ៉ា ដោយ យ៉ូសែប ប្រ៊ីកឃី



*ព្រះយេហូវ៉ា ( ព្រះយេស៊ូវគ្រីស្ទ ) បានមានព្រះបន្ទូលទៅកាន់ម៉ូសេដោយផ្ទាល់ ។*

**ព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាជួយយើងរៀនអំពីព្រះយេស៊ូវគ្រីស្ទ**

ព្រះយេស៊ូវគ្រីស្ទ គឺជាកូនច្បងនៃកូនចៅខាងវិញ្ញាណទាំងអស់របស់ព្រះវរបិតាសួគ៌ ។ នៅក្នុងជីវិតមុនឆាកជីវិតនេះ ព្រះយេស៊ូវបានទទួលគ្រប់ទាំងចំណេះដឹង ហើយមានព្រះចេស្ដា ព្រមទាំងតំណាងឲ្យព្រះវរបិតា ដោយធ្វើជាអង្គបង្កបង្កើតពិភពលោកជាច្រើន ។ តាមរយៈព្រះចេស្ដានៃភាពជាព្រះរបស់ទ្រង់ ព្រះអម្ចាស់យេស៊ូវគ្រីស្ទគឺជាប្រភពនៃពន្លឺ និងជីវិតសម្រាប់ការបង្កបង្កើតទាំងអស់របស់ទ្រង់ ។ ព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាបញ្ជាក់យ៉ាងច្បាស់អំពីតួនាទីជាច្រើនរបស់ទ្រង់នៅក្នុងផែនការរបស់ព្រះវរបិតា ។

- **គ. និង ស. ៩៣:២១** ព្រះយេស៊ូវគ្រីស្ទ គឺជាកូនច្បងនៃកូនចៅខាងវិញ្ញាណទាំងអស់របស់ព្រះ ។
- **គ. និង ស. ៣៨:១–៣** ព្រះយេស៊ូវគ្រីស្ទបានទទួលគ្រប់ទាំងចំណេះដឹង ហើយមានព្រះចេស្ដាពីមុនពិភពលោកនេះបានបង្កើត ។
- **គ. និង ស. ៧៦:២៤** ព្រះយេស៊ូវគ្រីស្ទបានតំណាងឲ្យព្រះវរបិតាដោយធ្វើជាអង្គបង្កបង្កើតនៃពិភពលោកជាច្រើន ។
- **គ. និង ស. ៨៨:៦–១៣** ព្រះយេស៊ូវគ្រីស្ទគឺជាប្រភពនៃពន្លឺ និងជីវិតសម្រាប់ការបង្កបង្កើតទាំងអស់របស់ទ្រង់ ។
- **គ. និង ស. ៤៥:១១; ១៣៦:២១, ២២** ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះយេហូវ៉ាដ៏មហិមានៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។
- **គ. និង ស. ៤៣:៣៤** ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះនៃពិភពលោក ។
- **គ. និង ស. ១៨:១១–១៣; ២០:២១–២៥** ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ត្រូវគេឆ្កាង សុគត ហើយបានមានព្រះជន្មរស់ឡើងវិញម្ដងទៀត ។
- **គ. និង ស. ២៩:១០–១២** ព្រះយេស៊ូវគ្រីស្ទបានសន្យាថាយាងមកកាន់ផែនដីដោយព្រះចេស្ដា និង សិរីល្អ ។



*តាមរយៈវិវរណៈសម័យទំនើបនេះ យើងអាចរៀនពីរបៀបប្រែក្លាយដូចជាព្រះវរបិតា និង ព្រះរាជបុត្រា ។*

**ព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាជួយយើងរៀនអំពីអ្វីដែលព្រះវរបិតា និងព្រះរាជបុត្រាទ្រង់មានព្រះទ័យរំពឹងចង់បានពីពួកយើង**

ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញាបានពន្យល់យ៉ាងច្បាស់ជាងគម្ពីរដទៃផ្សេងទៀត អំពីជីវិតអស់កល្បជានិច្ច ៖ ត្រឡប់ទៅរស់នៅជាមួយព្រះវរបិតា និង ព្រះរាជបុត្រា ទទួលអ្វីៗទាំងអស់ដែលព្រះវរបិតាមាន ហើយប្រែក្លាយដូចជាពួកទ្រង់ ។ ព្រះគម្ពីរនេះក៏ប្រាប់ពួកយើងអំពីរបៀបដែលព្រះយេស៊ូវគ្រីស្ទ អាចធ្វើបានតាមរយៈដង្វាយធួនរបស់ទ្រង់ និង អ្វីដែលពួកយើងចាំបាច់ត្រូវធ្វើដើម្បីបំពេញតម្រូវការដែលទ្រង់បានកំណត់ ។ ក្រៅពីនោះទៀត យើងរៀននៅក្នុងគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញាអំពីអត្ថន័យនៃការធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ដូចជាពួកយើងដែរ ដំបូងឡើយព្រះយេស៊ូវគ្រីស្ទគ្មានភាពពេញលេញទេព ប៉ុន្តែដោយបានទទួលព្រះគុណថែមលើព្រះគុណ រហូតដល់ទ្រង់មានគ្រប់អស់ទាំងព្រះចេស្ដា និង សិរីល្អទាំងអស់ ។

**គ. និង ស. ១:៣២; ១៩:១៦–១៩; ៥៨:៤២–៤៣; ៩៥:១–២** ព្រះអង្គសង្គ្រោះប្រទានការអភ័យទោសដល់អស់អ្នកដែលប្រែចិត្ត ។

**គ. និង ស. ២០:៣៧, ៤១, ៧២–៧៤** សូមមើលផងដែរ **៣៣:១១** ក្រុមព្រះអញ្ជើញអស់អ្នកដែលជឿឲ្យទទួលបុណ្យជ្រមុជទឹក ហើយទទួលព្រះវិញ្ញាណបរិសុទ្ធ ។

**គ. និង ស. ៨៤:១៩–២១** តាមរយៈពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាពមិលគីស្សាដែក នោះអំណាចនៃព្រះត្រូវបានបង្ហាញ ។

**គ. និង ស. ៩៣:១២–១៤, ១៦–១៧** ព្រះយេស៊ូវគ្រីស្ទបានទទួលព្រះគុណថែមលើព្រះគុណរហូតដល់ទ្រង់ទទួលបានភាពពេញលេញ ។

**គ. និង ស. ២០:៣០–៣១** ព្រះអង្គសង្គ្រោះបានប្រទានព្រះគុណដល់អស់អ្នកដែលស្រឡាញ់ទ្រង់ ហើយបម្រើទ្រង់ ។

**គ. និង ស. ៣៥:២; ៥០:៤០–៤៣** យើងអាចក្លាយជាតែមួយជាមួយនឹងព្រះវរបិតា និងព្រះរាជបុត្រា ។

**គ. និង ស. ៩៣:១៩–២០** យើងអាចទទួលសិរីល្អ និង ភាពពោរពេញរបស់ព្រះវរបិតា ។

**ព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាផ្ដល់គំរូសម្រាប់ការទទួលបានចំណេះដឹងខាងវិញ្ញាណ**

ក្រៅពីការបង្រៀន និង ការថ្លែងទីបន្ទាល់អំពីព្រះវរបិតា និង ព្រះរាជបុត្រា ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញាផ្ដល់គំរូដើម្បីទទួលបានចំណេះដឹងខាងវិញ្ញាណ អំពីអ្វីៗទាំងអស់របស់សមាជិកក្រុមព្រះ តាមរយៈជំនួយពីព្រះវិញ្ញាណបរិសុទ្ធ ៖ សិក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ សូមការយល់ដឹងពីព្រះវរបិតា ហើយអនុវត្តសេចក្ដីជំនឿលើព្រះគ្រីស្ទ តាមរយៈការគោរពតាមបទបញ្ញត្តិរបស់ទ្រង់ ។

ពន្លឺ និង សេចក្ដីពិតត្រូវបានសន្យាដល់អស់អ្នកដែលរស់នៅតាមអស់ទាំងព្រះបន្ទូលរបស់ព្រះអម្ចាស់ ។ វាសំខាន់ដើម្បីរៀនលម្អិតអំពីនិស្ស័យរបស់ក្រុមព្រះ និង ព្រះរាជបំណងរបស់ពួកទ្រង់ ។ ចំណេះដឹងនេះនាំឲ្យមនុស្សធ្វើការស្រាវជ្រាវ ដោយព្យាយាមរកការយល់ដឹងខាងវិញ្ញាណ និង ជំនឿស៊ប់លើសេចក្ដីពិត ។ ចំណេះដឹងនេះបញ្ជាក់ដល់យើងថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទស្គាល់ពួកយើងម្នាក់ៗ ថាពួកទ្រង់ស្រឡាញ់យើង ហើយថា ពួកទ្រង់មានព្រះទ័យចង់ប្រទានជីវិតអស់កល្បជានិច្ចដល់ពួកយើង ។

- **គ. និង ស. ៦:៥; ៧៦:៥–១០, ១១៤–១១៨** ព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើងទូលសូមចំណេះដឹង ហើយសន្យាថាចែកចាយវា ។
- **គ. និង ស. ៨៤:៤៣–៤៨** ព្រះវរបិតាបង្រៀនយើងនៅពេលយើងស្ដាប់តាមព្រះបន្ទូលទ្រង់ដោយឧស្សាហ៍ព្យាយាម ។
- **គ. និង ស. ៨៨:១១៨** ស្វែងរកការរៀនសូត្រដោយការសិក្សា និងដោយសេចក្ដីជំនឿ ។



*ការសិក្សា និង ការអធិស្ឋានអាចបើកទ្វារនៃចំណេះដឹងខាងវិញ្ញាណ ។*



រូបភាពដកស្រង់មកពី ការផ្សព្វផ្សាយរបស់យ៉ូសែប ស្ម៊ីធ ដោយ សែម ឡូលែរ

*យ៉ូសែប ស្ម៊ីធ បានបើកសម្ដែងបុគ្គលិកលក្ខណៈ និង ព្រះរាជបំណងរបស់ព្រះវរបិតា និង ព្រះរាជបុត្រា ។*

**សេចក្ដីបញ្ចប់**

ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញាជួយយើងឲ្យខិតកាន់តែជិតព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ តាមរយៈការបើកសម្ដែងបុគ្គលិកលក្ខណៈ និង ព្រះរាជបំណងរបស់ពួកទ្រង់ ។ ព្យាការីយ៉ូសែប ស្ម៊ីធ បានសង្ខេបពីមូលហេតុដែលយើងអាចទុកចិត្ត និង ពឹងផ្អែកលើព្រះដូចនេះ ៖ « ព្រះរាជបំណងនៃព្រះរបស់យើងធំណាស់ន៎ សេចក្ដីស្រឡាញ់របស់ទ្រង់មានទំហំធំធេងដែលមិនអាចវាស់បាន ព្រះប្រាជ្ញារបស់ទ្រង់គ្មានទីបញ្ចប់ ហើយព្រះចេស្ដារបស់ទ្រង់គ្មានដែនកំណត់ ហេតុដូច្នោះហើយពួកបរិសុទ្ធមានហេតុ ដើម្បីសប្បាយ ហើយអររីករាយដោយដឹងថា ‹ ព្រះនេះទ្រង់ជាព្រះនៃយើងខ្ញុំនៅអស់កល្បជានិច្ច › ( ទំនុកដំកើង ៤៨:១៤ ) » ។[៤] ■

**កំណត់ចំណាំ**

១. ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ( ឆ្នាំ ១៨៧៦–១៩៧២ ) បានពន្យល់ដូចនេះ ៖ « វិវរណៈទាំងអស់តាំងពីការធ្លាក់មកបានសម្រេចតាមរយៈព្រះយេស៊ូវគ្រីស្ទដែលជាព្រះយេហូវ៉ានៃព្រះគម្ពីរសញ្ញាចាស់ ។ នៅក្នុងគ្រប់ខគម្ពីរទាំងអស់ កន្លែងដែលនិយាយអំពីព្រះ និង ការបង្ហាញព្រះកាយរបស់ព្រះគឺសំដៅលើព្រះយេហូវ៉ា ។ . . . ព្រះវរបិតាមិនធ្លាប់ទាក់ទងនឹងមនុស្សលោកដោយអង្គទ្រង់ផ្ទាល់នោះទេតាំងពីការធ្លាក់មក ហើយទ្រង់មិនដែលបានបង្ហាញព្រះកាយឡើយ លើកលែងតែដើម្បីបង្ហាញ និងថ្លែងទីបន្ទាល់អំពីព្រះរាជបុត្រា » ( *Doctrines of Salvation* ចងក្រងដោយ Bruce R. McConkie វ៉ុលទី ៣ [ ១៩៥៤–៥៦ ] ១:២៧ ) ។

២. សូមមើល Gordon B. Holbrook « The Voice of Jesus Christ in the Doctrine and Covenants » *Ensign* ខែ កញ្ញា ឆ្នាំ ២០១៣ ទំព័រ ៤០, ៤៥ ( កំណត់ចំណាំ ២ ) ។

៣. *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ ២០០៧ ) ទំព័រ ៤០–៤១ ។

៤. *Teachings: Joseph Smith* ទំព័រ ៣៩ ។

ហ្គរដុន ប៊ី ហ៊ិងគ្លី ៖

# ព្យាការីដែលមានសុទិដ្ឋិនិយម្ និង ទស្សនវិស័យ

*នៅពេលអ្នកសិក្សាសៀវភៅ* Teachings of Presidents of the Church: Gordon B. Hinckley *នៅក្នុងថ្នាក់បព្វជិតភាព និង សមាគមសង្គ្រោះឆ្នាំនេះ អ្នកនឹងរៀនអំពីព្យាការីដែលមានសុទិដ្ឋិនិយម សេចក្ដីស្រឡាញ់ និង ការដឹងជាមុនដែលគ្មានដែនកំណត់ ។*



*ហ្គរដុន ប៊ី ហុិងគ្លី កើតនៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩១០ លោកជាកូនរបស់ ប្រាយអុិន ស្ទ្រីងហាំ ហុិងគ្លី និង អេដា ប៊ីតនើរ ហុិងគ្លី ។ លោករៀបអាពាហ៍ពិពាហ៍ជាមួយ ម៉ាជូរី ផេយ នៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៣៧ ហើយពួកលោកមានកូនប្រាំនាក់ ។ លោកបានបម្រើជាប្រធានទី ១៥ នៃសាសនាចក្រ ចាប់ពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៥ ដល់ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៨ ។*

**ដោយ អែនគ្រូ ឌី អូលសិន**
នាយកដ្ឋានផ្នែកសេវាកម្មបោះពុម្ពសាសនាចក្រ



ប្រធាន ហ្គរដុន ប៊ី ហុិងគ្លី បានកត់ត្រានៅក្នុងសៀវភៅទិនានុប្បវត្តិរបស់លោកកាលលោកអាយុ ៨២ ឆ្នាំថា « ខ្ញុំត្រូវដាំដើមឈើមួយចំនួននៅរាល់រដូវផ្ការីក ។ ខ្ញុំគិតថា យ៉ាងហោចណាស់ខ្ញុំបានធ្វើបែបនេះអស់ ៥០ ឆ្នាំមកហើយ ។ . . . ដើមឈើមានភាពអស្ចារ្យណាស់ ។ វាចាប់ផ្ដើមពីតូច ហើយដុះឡើងតាមរដូវកាល ។ វាផ្ដល់ម្លប់ដែលជាទីជម្រកជ្រកពីកម្ដៅព្រះអាទិត្យ ។ វាផ្ដល់ផ្លែដែលមានឱជារសឆ្ងាញ់ ។ វាមានដំណើររស្មីសំយោគដ៏អស្ចារ្យ ។ . . . ដើមឈើគឺជាការបង្កបង្កើតដ៏អស្ចារ្យមួយរបស់ព្រះដ៏មានមហិទ្ធិឫទ្ធិ » ។[១]

ប្រធាន ហុិងគ្លី បានបន្តដាំដើមឈើរហូតដល់លោកមានអាយុ ៩០ ឆ្នាំ ។ សេចក្ដីស្រឡាញ់ក្នុងការដាំដើមឈើរបស់លោកបានឆ្លុះបញ្ចាំងអំពីការបម្រើរបស់លោក ក្នុងនាមជាសាវក និង ជាប្រធាននៃសាសនាចក្រតាមរបៀបជាច្រើន ។ នៅពេលលោកបានដាំដើមឈើ វាគឺជាការបង្ហាញពីសុទិដ្ឋិនិយម ជាបុគ្គលិកលក្ខណៈមួយ ដែលផ្សារភ្ជាប់នឹងការបង្រៀនរបស់លោក និង ការប្រាស្រ័យទាក់ទងជាមួយមនុស្សដទៃផងដែរ ។ លោកបានថែទាំដើមឈើនីមួយៗ ដូចជាលោកបានមើលថែទាំមនុស្សម្នាក់ៗដែរ ។ ហើយលោកបានសម្លឹងឆ្ពោះមើលទៅពេលអនាគតដោយមើលឃើញថាតើដើមឈើនោះនឹងក្លាយជាដើមឈើបែបណា—គឺដូចជាលោកបានឃើញសក្ដានុពលអស់កល្បជានិច្ចរបស់បុគ្គលម្នាក់ៗ និង កិច្ចការនាពេលអនាគតដ៏ធំមហាសាលរបស់ព្រះផងដែរ ។

### « យើងមានហេតុផលជាច្រើនដើម្បីមានភាពសុទិដ្ឋិនិយម »

« ខ្ញុំជាមនុស្សសុទិដ្ឋិនិយម ! » ប្រធាន ហុិងគ្លី តែងតែបានថ្លែងបែបនេះ ។ « ខ្ញុំសូមអង្វរឲ្យយើងឈប់ស្វែងរកភាពងងឹត ហើយរីករាយទាំងស្រុងនឹងពន្លឺវិញ » ។[២] សុទិដ្ឋិនិយមរបស់លោកមានច្រើនជាងទស្សនៈវិជ្ជមានរបស់លោក ដោយសារលោកបានបណ្ដុះឲ្យមានគំនិតនោះ ។ ប្រភពដ៏សំខាន់បំផុតនៃសុទិដ្ឋិនិយមរបស់លោក—ជាប្រភពដែលធ្វើឲ្យសុទិដ្ឋិនិយមនោះមានអំណាច—គឺជាសេចក្ដីជំនឿរបស់លោកលើព្រះ និង ទីបន្ទាល់របស់លោកអំពីផែនការនៃព្រះសម្រាប់សុភមង្គល និង សេចក្ដីសង្គ្រោះរបស់កូនចៅទ្រង់ ។

ភស្តុតាងមួយនៃសុទិដ្ឋិនិយមរបស់ប្រធាន ហុិងគ្លីគឺជាសេចក្ដីជំនឿដ៏រឹងមាំរបស់លោកដែលថា « អ្វីៗនឹងដំណើរការល្អ » ។[៣] អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា ឃ្លានោះ « ប្រហែលជាការអះអាងច្រើនបំផុតរបស់ប្រធាន ហុិងគ្លី ចំពោះក្រុមគ្រួសារ មិត្តភក្ដិ និង អ្នកធ្វើការជាមួយលោក ។ លោកមានប្រសាសន៍ថា ‹ ចូរបន្តព្យាយាម › ។ ចូរជឿចុះ ។ ‹ ចូររីករាយឡើង ។ ចូរកុំបាក់ទឹកចិត្ត ។ អ្វីៗនឹងដំណើរការល្អ › » ។[៤]



រូបដើមឈើ© ISTOCK/THINKSTOCK

ប៉ុន្តែសារលិខិតនេះពុំមែនសម្រាប់តែមនុស្សដទៃនោះឡើយ ។ ប្រធាន ហ៊ិងគ្លី បានមានប្រសាសន៍ប្រាប់ដល់ក្រុមជំនុំមួយថា « ខ្ញុំនិយាយពាក្យទាំងនោះប្រាប់ខ្លួនខ្ញុំរៀងរាល់ព្រឹក ។ ប្រសិនបើ អ្នកធ្វើអស់ពីសមត្ថភាព នោះអ្វីគ្រប់យ៉ាងនឹងដំណើរការទៅបានយ៉ាងល្អ ។ សូមទុកចិត្តលើព្រះ ហើយបន្តឆ្ពោះទៅមុខដោយសេចក្តីជំនឿ និង ទំនុកចិត្តក្នុងពេលអនាគត ។ ព្រះអម្ចាស់នឹងមិនបោះបង់យើងចោលឡើយ » ។[៥]

សុទិដ្ឋិនិយមរបស់ប្រធាន ហ៊ិងគ្លី បានគាំទ្រលោកឲ្យហែលឆ្លងកាត់ការសាកល្បង អារម្មណ៍នៃភាពបរាជ័យ និង អារម្មណ៍នៃសម្ពាធដ៏ស្មុគស្មាញ ។ ហើយលោកបានក្រោកឈរឡើង ដោយជំនឿស៊ប់របស់លោកថា « អ្វីៗនឹងដំណើរការល្អ » ទោះបីជានៅពេលដែលលោកជួបឧបសគ្គ និង ការខកចិត្ត ការខូចចិត្ត និង ភាពឯកោយ៉ាងណាក្តី ។



នៅក្នុងសុទិដ្ឋិនិយមរបស់លោក ប្រធាន ហ៊ិងគ្លីពុំបានកាត់បន្ថយបញ្ហាឡើយ ។ លោកបានពន្យល់ថា « ខ្ញុំបានឃើញពីភាពដ៏ធំធេងនៃផែនដីនេះ ។ . . . ខ្ញុំធ្លាប់រស់នៅក្នុងតំបន់ដែលមានសង្គ្រាម ហើយភាពស្អប់ខ្ពើមបានឆេះងំនៅក្នុងដួងចិត្តមនុស្សទាំងនោះ ។ ខ្ញុំអាចឃើញពីភាពក្រតោកយ៉ាកដែលកើតមានឡើងនៅក្នុងប្រទេសជាច្រើន ។ . . . ខ្ញុំបានមើលឃើញពីក្តីបារម្ភនៃការមិនគោរពសីលធម៌សង្គមរបស់យើង ។

« ប៉ុន្តែខ្ញុំជាមនុស្សមានសុទិដ្ឋិនិយម ។ ខ្ញុំមានសេចក្តីជំនឿមួយដ៏សាមញ្ញ និង មុតមាំថា ភាពត្រឹមត្រូវនឹងមានជ័យជម្នះ ហើយថាសេចក្តីពិតនឹងមានភាពជោគជ័យ » ។[៦]

អំឡុងពេលសម្ភាសន៍ជាមួយអ្នកយកព័ត៌មានកាសែត *New York Times* នៅក្នុងទីក្រុង ណៅវូ រដ្ឋ អិលលីណោយ ស.រ.អា. ប្រធាន ហ៊ិងគ្លី បានទទួលស្គាល់ការរីករាលដាលនៃសោកនាដកម្ម និង បញ្ហានានា ហើយក្រោយមកលោកបានប្រើសេចក្តីស្រឡាញ់របស់លោកចំពោះប្រវត្តិសាសនាចក្រ បង្រៀនអំពីសុទិដ្ឋិនិយម ៖

« យើងមានហេតុផលជាច្រើនដើម្បីមានភាពសុទិដ្ឋិនិយម » ។ . . . ចូរមើលទៅទីក្រុង ណៅវូ ។ ចូរមើលទៅអ្វីដែលពួកគេបានសាងសង់នៅទីនេះ ក្នុងរយៈពេលប្រាំពីរឆ្នាំ ហើយក្រោយមកបានចាកចេញទៅបាត់ ។ ប៉ុន្តែតើពួកគេបានធ្វើអ្វីខ្លះ ? តើពួកគេទម្រេតខ្លួន ហើយដេកស្លាប់ឬ ? ទេ ! ពួកគេបានចេញទៅធ្វើការ ។ ពួកគេបានប្តូរទីលំនៅឆ្លងកាត់ទ្វីបនេះបានពាក់កណ្តាលផ្លូវ និង បានប្រែក្លាយដីវាលខ្សាច់នេះ ហើយធ្វើវាឲ្យរីកស្រស់បំព្រងឡើងដូចជាផ្កាកុលាប ។ ផ្អែកលើមូលដ្ឋាននោះ សាសនាចក្រនេះបានរីកចម្រើនឡើងក្លាយជាអង្គការមួយដ៏ធំទូទាំងពិភពលោក ដែលជះឥទ្ធិពលល្អដល់មនុស្សជាង ១៤០ ប្រទេស ។ ទុទិដ្ឋិនិយម ឬ ភាពសង្ស័យពុំអាចហើយពុំធ្វើឲ្យអ្នកស្ថាបនាអ្វីបានឡើយ ។ អ្នកត្រូវមើលទៅមុខដោយសុទិដ្ឋិនិយម ធ្វើការដោយសេចក្តីជំនឿ ហើយលទ្ធផលនឹងកើតមានឡើង » ។[៧]

សុទិដ្ឋិនិយមរបស់ប្រធាន ហ៊ិងគ្លី ក៏ជះឥទ្ធិពលដល់ស្មារតីនៃចិត្តគំនិតរបស់លោកផងដែរ—នោះគឺភាពរីករាយ ភាពកំប្លុកកំប្លែង ដែលបង្កើតភាពស្និទ្ធស្នាលជាមួយមនុស្សដទៃ ។ មានគ្រាមួយលោកបានស្នាក់នៅជាមួយប្រធានស្តេក គ្រួសារនោះរស់នៅក្នុងសាលារៀនមួយ ដែលពួកគេបានកែច្នៃវាឲ្យទៅជាផ្ទះ ។ នាយប់នោះ ប្រធាន ហ៊ិងគ្លីយកថ្នាក់រៀនធ្វើជាបន្ទប់ដេក ។ នៅអំឡុងពេលប្រជុំសន្និសីទស្តេកនាថ្ងៃបន្ទាប់ លោកបានមានប្រសាសន៍បែបកំប្លែងថា « កាលពីមុនខ្ញុំធ្លាប់ដេកនៅក្នុងថ្នាក់ពេលកំពុងរៀនជាច្រើនដង—ពុំមែនដេកលើគ្រែឡើយ » ។[៨]

**« កង្វល់របស់យើងត្រូវតែគិតលើបុគ្គលម្នាក់ៗជានិច្ច »**

នៅក្នុងសុន្ទរកថាសន្និសីទទូទៅលើកដំបូងរបស់លោកក្នុងនាមជាប្រធានសាសនាចក្រ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានមានប្រសាសន៍យ៉ាងច្រើនអំពីការរីកចម្រើនរបស់សាសនាចក្រ ។ លោកបានមានប្រសាសន៍ថា « យើងកំពុងក្លាយជាសង្គមមួយដ៏ធំនៅទូទាំងពិភពលោក » ។ បន្ទាប់មកលោកបែរទៅគូសបញ្ជាក់អំពីគោលការណ៍ដ៏សំខាន់នេះ ៖ « ចំណាប់អារម្មណ៍ និង កង្វល់របស់យើងត្រូវគិតលើបុគ្គលម្នាក់ៗជានិច្ច ។ . . .

« . . . យើងនិយាយអំពីចំនួនមនុស្ស ប៉ុន្តែកិច្ចខិតខំរបស់យើងត្រូវតែបូជាចំពោះការរីកចម្រើនរបស់បុគ្គលម្នាក់ៗ » ។[៩]

អំឡុងពេលបម្រើជាសមាជិកនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ប្រធាន ហ៊ិងគ្លីបានធ្វើដំណើរទៅតំបន់ឆ្ងាយបំផុតនៃពិភពលោក រួមទាំងតំបន់មានសង្គ្រាមដើម្បីបម្រើបុគ្គលម្នាក់ៗ ។ គ្មានក្រុមមនុស្សណាដែលនៅឆ្ងាយពេក ឬ តូចតាចពេកដែលធ្វើឲ្យលោកមិនខ្វល់ខ្វាយនោះឡើយ ។ លោកបានបន្តលំនាំនេះនៅពេលលោកធ្វើជាប្រធានសាសនាចក្រ ដោយធ្វើដំណើរជាងរាប់រយលានគីឡូម៉ែត្រ ទៅកាន់ប្រទេសជាង ៦០ ជួនកាលជួបមនុស្សទាំងក្រុមៗ ជួនកាលជួបមនុស្សតែពីរបីនាក់ប៉ុណ្ណោះ ។

ក្នុងឆ្នាំ ១៩៩៦ ប្រធាន និង ស៊ីស្ទើរ ហ៊ិងគ្លីបានធ្វើដំណើររយៈពេល ១៨ ថ្ងៃ ទៅកាន់ប្រទេសប្រាំបីនៅក្នុងតំបន់អាស៊ី និង ប៉ាស៊ីហ្វិក ។ ដោយចាប់ផ្តើមពីប្រទេសជប៉ុន ហើយបន្តទៅមុខយ៉ាងស្វាហាប់ ពួកលោកបានជួបមនុស្សរាប់ពាន់នាក់ដែលមកពេញបន្ទប់ ។ ប្រធាន ហ៊ិងគ្លី បានកត់ត្រាអំឡុងពេលនៅប្រទេសកូរ៉េថា « នេះជាបទពិសោធន៍ដ៏រំជួលចិត្តអ្វីម្ល៉េះសម្រាប់ខ្ញុំ ។ « ខ្ញុំបានឃើញអ្វីៗជាច្រើនដែលខ្ញុំមិនហ៊ានគិតដល់ កាលខ្ញុំមកប្រទេសនេះដំបូងក្នុងឆ្នាំ ១៩៦០ » ។[១០] នៅក្នុងការធ្វើដំណើរនោះលោកក៏បានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធហុងកុងផងដែរ ។

កាលវិភាគការធ្វើដំណើរចុងបញ្ចប់គឺនៅប្រទេសហ្វីលីពីន ។ បន្ទាប់ពីនិយាយទៅកាន់មនុស្ស ៣៥០០០ នាក់នៅក្នុងទីក្រុង ម៉ានីល មកប្រធាន ហ៊ិងគ្លី បានកត់ត្រាថា « ខ្ញុំបានឈរ ហើយគ្រវីដៃដាក់ពួកគេដោយអារម្មណ៍ក្តុកក្តួលក្នុងចិត្ត

ផ្ទៃខាងក្រោយ © ISTOCK/THINKSTOCK ខាងឆ្វេង ៖ ថតរូបដោយ ប៊ែរភត រូបេថត ខាងស្តាំ ៖ ថតរូបនៅប្រទេស ចិន ដោយ ជើរី អាក់ន *DESERET NEWS* ខាងស្តាំខាងក្រោម ៖ រូបថតទទួលបានសិទ្ធិអនុញ្ញាតពីផ្នែកបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ និង បណ្ណសារ

យ៉ាងខ្លាំង ។ យើងបានចាកចេញមកទាំងទឹកភ្នែក » ។ នៅព្រឹកព្រលឹមនាថ្ងៃនោះ លោកបានត្រឡប់ទៅកន្លែងមួយដែលលោកបានធ្វើការអធិស្ឋានឧទ្ទិសឆ្លងកាលពីឆ្នាំ ១៩៦១ ដើម្បីចាប់ផ្ដើមកិច្ចការផ្សព្វផ្សាយសាសនានៅក្នុងប្រទេសហ្វីលីពីន ។ លោកបាននៅចាំថា « យើងអាចរកបានសមាជិកជនជាតិហ្វីលីពីនបានតែម្នាក់គត់ ។ ចាប់ពីសមាជិកម្នាក់រហូតដល់ សាសនាចក្របានកើនសមាជិកជាង ៣០០,០០០ នាក់ » ។[១១]

នៅពេលប្រធាន និង ស៊ីស្ទើរ ហ៊ិងគ្លីចាប់ផ្ដើមធ្វើដំណើរត្រឡប់ទៅសហរដ្ឋវិញ ពួកលោកបានដឹងថា យន្តហោះត្រូវចាក់សាំងនៅលើកោះសាយផាន ។ ប្រធាន ហ៊ិងគ្លីបានសួរ ថាតើមានអ្នកផ្សព្វផ្សាយសាសនាមួយចំនួននៅលើកោះសាយផាននោះឬទេ ហើយគេបានប្រាប់លោកថាមានតិចតួច ។ ទោះបីជានៅគ្រាចុងក្រោយនៃការធ្វើដំណើរដ៏នឿយហត់ក្ដី លោកចង់ជួបអ្នកផ្សព្វផ្សាយសាសនាទាំងនោះ ៖ « បើអាច ខ្ញុំសូមឲ្យយើងអាចនាំពាក្យទៅប្រាប់ពួកគេថា យើងចង់ចុះនៅកោះសាយផាន ម៉ោង ៧ យប់ ហើយចង់ទៅខាងក្រៅព្រលានយន្តហោះដើម្បីស្វាគមន៍ពួកគេ » ។

ប៉ុន្មានម៉ោងក្រោយមកនៅសាយផាន មានអ្នកផ្សព្វផ្សាយសាសនា ១០ នាក់ និង សមាជិកសាសនាចក្រប្រហែលជា ៦០ នាក់បាននៅទីនោះ ដើម្បីស្វាគមន៍ដល់ប្រធាន និង ស៊ីស្ទើរ ហ៊ិងគ្លី ។ ប្រធាន ហ៊ិងគ្លី បានកត់ត្រាថា « ពួកគេបានឱបពួកយើង ។ ពួកគេមានអំណរគុណដែលបានជួបពួកយើង ហើយពួកយើងមានអំណរគុណដែលបានជួបពួកគេ ។ យើងបានចំណាយពេលនៅជាមួយពួកគេបានតែបន្តិចប៉ុណ្ណោះ ខណៈដែលយន្តហោះគ្រាន់តែឈប់ចាក់សាំង ។ យើងបានបន្សល់ទុកពរជ័យរបស់យើងជាមួយពួកគេ ហើយបានត្រឡប់ទៅយន្តហោះវិញ » ។[១២]

ឧទាហរណ៍សាមញ្ញមួយទៀតអំពីការខ្វល់ខ្វាយរបស់ប្រធាន ហ៊ិងគ្លីចំពោះបុគ្គលម្នាក់ៗនោះ បានកើតឡើងអំឡុងកីឡាអូឡាំពិករដូវរងាឆ្នាំ ២០០២ ដែលបានប្រារព្ធឡើងនៅក្នុងទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ។ លោកបានជួបជាមួយប្រធានាធិបតី ឯកអគ្គរាជទូត និង ឥស្សរជនដទៃផ្សេងទៀតជាច្រើន ស្ទើរតែរៀងរាល់ថ្ងៃ ។ មួយថ្ងៃ ពីមុនការប្រជុំជាមួយប្រធានាធិបតីប្រទេសអាល្លឺម៉ង់បន្តិច លោកបានជួបក្មេងស្រីអាយុ ១៣ ឆ្នាំ នាថ្ងៃខួបកំណើតរបស់នាង ។ លោកបានកត់ត្រាថា « [ នាង ] បានរងទុក្ខដោយជំងឺកង្វះឈាមក្រហមដែលបណ្ដាលមកពីបញ្ហាខួរឆ្អឹង ជាជំងឺមួយធ្ងន់ធ្ងរណាស់ ។ យើងមានការសួរសុខទុក្ខមួយដ៏រីករាយ ។ . . . ខ្ញុំបានប្រាប់នាងថា យើងនឹងអធិស្ឋានសម្រាប់នាង » ។[១៣]

ប្រធាន ហ៊ិងគ្លីមានក្ដីស្រឡាញ់ដ៏អស្ចារ្យចំពោះកុមារ និង យុវវ័យសាសនាចក្រ ហើយពួកគេទាំងនោះក៏មានអារម្មណ៍បែបនោះចំពោះលោកផងដែរ ។ បន្ទាប់ពីស្ដាប់លោកថ្លែងនៅក្នុងប្រទេសប្រេស៊ីលមក យុវនារីម្នាក់បានបង្ហាញអារម្មណ៍នាងដូចនេះ ៖ « ខ្ញុំមានអារម្មណ៍ពីព្រះវិញ្ញាណនៃព្រះយ៉ាងខ្លាំង ។ នៅពេលប្រធាន ហ៊ិងគ្លីបញ្ចប់សុន្ទរកថារបស់លោក ដែលលោកបានមានប្រសាសន៍មកកាន់ពួកយើងថា ‹ ប្អូនៗអាចចាកចេញពីនេះ ទៅផ្ទះ ហើយភ្លេចអ្វីៗទាំងអស់ ដែលខ្ញុំបាននិយាយនាថ្ងៃនេះបាន ប៉ុន្តែសូមកុំភ្លេចថា ខ្ញុំស្រឡាញ់ប្អូនៗ › ។ ខ្ញុំនឹងមិនភ្លេចប្រសាសន៍ទាំងនោះឡើយ » ។[១៤]

ភរិយាប្រធាន ហ៊ិងគ្លី ម៉ាជ្ជរី គឺជាដៃគូ និង ជាអ្នកមានឥទ្ធិពលចំពោះការខ្វល់ខ្វាយរបស់លោកដល់បុគ្គលម្នាក់ៗ ។ លោកបានកត់ត្រាដូចនេះ ៖ « មនុស្សគ្រប់គ្នាដែលគាត់ស្គាល់ ហាក់ដូចជាស្រឡាញ់គាត់ ដោយសារគាត់មានចំណាប់អារម្មណ៍ស្មោះត្រង់លើមនុស្ស ។ គាត់យកចិត្តទុកដាក់ជាមួយបញ្ហា និង សេចក្ដីត្រូវការរបស់ពួកគេ ។ ខ្ញុំមានសំណាងអ្វីម្ល៉េះ ដែលមានគាត់ជាដៃគូ » ។[១៥]

បន្ទាប់ពីកូនទាំងប្រាំនាក់របស់ពួកលោកបានធំអស់ហើយ ប្រធាន និង ស៊ិស្ទើរ ហ៊ិងគ្លី ធ្វើដំណើរទៅណាមកណាជាមួយគ្នាជានិច្ច ហើយស៊ីស្ទើរ ហ៊ិងគ្លី







*រូបភាពខាងលើពីឆ្វេងទៅស្ដាំ ៖ ប្រធាន ហ៊ិងគ្លី ជួបជាមួយសមាជិក, ប្រធាន ហ៊ិងគ្លី និង ភរិយាលោក ម៉ាជ្ជរី នៅទីក្រុង ហុងកុង ប្រទេសចិន, សញ្ជឹងគិតអំឡុងពេលសន្និសីទទូទៅ ។*

បានផ្ដល់សេចក្ដីស្រឡាញ់ដល់មនុស្សជុំវិញពិភពលោក ។ នៅពេលស៊ីស្ទើរ ហ៊ិងគ្លីបានជួបអ្នកផ្សព្វផ្សាយសាសនា នោះគាត់តែងតែទូរសព្ទទៅឪពុកម្ដាយរបស់អ្នកផ្សព្វផ្សាយសាសនាទាំងនោះនៅពេលស៊ីស្ទើរ ហ៊ិងគ្លីទៅដល់ផ្ទះវិញ ដើម្បីធ្វើឲ្យពួកគេភ្ញាក់ផ្អើល ។ ស៊ីស្ទើរ ហ៊ិងគ្លី ក៏ពូកែខាងការទាក់ទងជាមួយទស្សនិកជនជាក្រុមធំៗផងដែរ ។ ប្រធាន ហ៊ិងគ្លី បានកត់ត្រាបន្ទាប់ពីសន្និសីទប្រចាំតំបន់មួយថា « [ ម៉ាជី ]ចេះនិយាយអ្វីដែលគាប់ចិត្ត និង ជួយដល់មនុស្ស ។ « ពួកយើងទាំងអស់គ្នាបង្រៀន ប៉ុន្តែគាត់បែរជាពិភាក្សាជាមួយពួកគេដោយសាមញ្ញៗទៅវិញ » ។[១៦]

នៅពិធីបុណ្យសពរបស់ប្រធាន ហ៊ិងគ្លី ប្រធាន ហិនរី ប៊ី អាវរិង ជាទីប្រឹក្សារបស់លោក បានសង្ខេបពីស្នាដៃមួយចំនួនរបស់ប្រធាន ហ៊ិងគ្លី ។ ក្រោយមកលោកបានសង្កេតឃើញថា នៅក្នុងគ្រប់ស្នាដៃទាំងអស់មានអ្វីមួយដែលដូចគ្នា ៖

« ពួកលោកផ្ដល់ឱកាសដល់បុគ្គលម្នាក់ៗជានិច្ច ។ ហើយលោកតែងតែគិតគូរដល់អស់អ្នកដែលមានឱកាសតិចតួច ជាមនុស្សសាមញ្ញដែលពុះពារដោះស្រាយបញ្ហាលំបាកក្នុងជីវិតប្រចាំថ្ងៃ និង ឧបសគ្គក្នុងការរស់នៅតាមដំណឹងល្អនៃ

ព្រះយេស៊ូវគ្រីស្ទ ។ លោកបានយកដៃគោះទ្រូងខ្ញុំជាច្រើនលើកច្រើនគ្រា នៅពេលខ្ញុំផ្ដល់យោបល់ ហើយលោកមានប្រសាសន៍ថា ‹ ហាល តើលោកចងចាំពីមនុស្សដែលកំពុងជួបការលំបាកឬទេ ? › »[១៧]

**ទស្សនវិស័យសម្រាប់ពេលអនាគត**

ភ្ជាប់ជាមួយនឹងសុទិដ្ឋិនិយមរបស់ប្រធាន ហ៊ិងគ្លី និង ការផ្ដោតចិត្តទុកដាក់របស់លោកជាមួយបុគ្គលម្នាក់ៗ គឺជាទស្សនវិស័យនៃការព្យាកររបស់លោកសម្រាប់ពេលអនាគត ។ គួរឲ្យសរសើរបំផុតនោះគឺថាទស្សនវិស័យទាក់ទងនឹងព្រះវិហារបរិសុទ្ធ ។ ប្រធាន ហ៊ិងគ្លី បានគូសបញ្ជាក់អំពីពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធថាជា « ពរជ័យអស្ចារ្យបំផុត ដែលសាសនាចក្រផ្ដល់ឲ្យ » ។[១៨]







*រូបភាពខាងលើពីឆ្វេងទៅស្ដាំ ៖ ប្រធាន ហ៊ិងគ្លី នៅព្រះវិហារបរិសុទ្ធ បូស្តុន រដ្ឋ ម៉ាស្សាឈូសេត, នៅចន្លោះឈុតថតជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន, ជាមួយសមាជិកនៅប្រទេស ហ្គាណា ។*

កាលលោកក្លាយជាប្រធានសាសនាចក្រនៅក្នុងឆ្នាំ ១៩៩៥ មានព្រះវិហារបរិសុទ្ធចំនួន ៤៧ កំពុងដំណើរការនៅទូទាំងពិភពលោក ។ ក្រោមការដឹកនាំរបស់លោក សាសនាចក្របានបង្កើនចំនួនព្រះវិហារបរិសុទ្ធទ្វេដងក្នុងរយៈពេលប្រាំឆ្នាំដ៏ខ្លីប៉ុណ្ណោះ ។ ទស្សនវិស័យរបស់លោកទាក់ទងនឹងព្រះវិហារបរិសុទ្ធមានភាពរឹងប៉ឹង ហើយ ទូលំទូលាយ ប៉ុន្តែគោលបំណងទាំងស្រុងនោះគឺផ្ដល់ពរដល់បុគ្គលគ្រប់រូបម្ដងម្នាក់ៗ ។

ការបំផុសគំនិតសម្រាប់យុគសម័យថ្មីនៃការសាងសង់ព្រះវិហារបរិសុទ្ធនេះកើតឡើងនៅក្នុងឆ្នាំ ១៩៩៧ នៅពេលប្រធាន ហ៊ិងគ្លី បានទៅទីក្រុង កូឡូនៀ វ៉ារែស ម៉ិកស៊ិក ដើម្បីប្រារព្ធខួបទី ១០០ ឆ្នាំ ដែលសាសនាចក្រមានសាលារៀនផ្ទាល់ខ្លួន ។ បន្ទាប់មក អំឡុងពេលជិះឡានតាមផ្លូវដ៏ហុយដ៏យូរនោះមកលោកបានសញ្ជឹងគិត ។ ដុន អេច ស្ដាហេលី លេខារបស់លោកបានរំឭកថា « វាមានសភាពស្ងប់ស្ងាត់ ។ ហើយក្រោយមក តាមខ្ញុំយល់ វិវរណៈបានចាប់ផ្ដើមកើតមានឡើង ។ លោកបានគិតអំពីព្រះវិហារបរិសុទ្ធដែលតូចជាងកាលពីបុរាណ ប៉ុន្តែលើកនេះពុំដូចលោកគិតកាលពីមុនឡើយ » ។[១៩]

ក្រោយមកប្រធាន ហ៊ិងគ្លី បានពិពណ៌នាអំពីដំណើរការដូចនេះ ៖« ខ្ញុំបានចាប់ផ្ដើមសួរខ្លួនខ្ញុំ អំពីអ្វីដែលអាចធ្វើបាន ដើម្បីឲ្យមនុស្សទាំងនេះអាចទទួលបានព្រះវិហារបរិសុទ្ធ ។ . . . នៅពេលខ្ញុំសញ្ជឹងគិតអំពីរឿងនេះ មានគំនិតមួយផុសក្នុងចិត្តខ្ញុំថា . . . យើងអាចសាងសង់ធាតុចាំបាច់ទាំងអស់របស់ព្រះវិហារបរិសុទ្ធនៅក្នុងអគារតូចៗបាន ។ . . . ខ្ញុំបានធ្វើគំនូរគម្រោងព្រាងមួយ ។ . . . រូបភាពទាំងស្រុងបានផុសឡើងក្នុងគំនិតខ្ញុំយ៉ាងច្បាស់ ។ ខ្ញុំជឿដោយអស់ពីចិត្តខ្ញុំថា វាគឺជាការបំផុសគំនិត ថាវាជាវិវរណៈមកពីព្រះអម្ចាស់ ។ ខ្ញុំបានត្រឡប់មកផ្ទះវិញ ហើយនិយាយរឿងនោះជាមួយទីប្រឹក្សារបស់ខ្ញុំ ហើយពួកលោកបានអនុម័ត ។ ក្រោយមកខ្ញុំបានបង្ហាញរឿងនោះដល់ពួកដប់ពីរនាក់ ហើយពួកលោកបានអនុម័ត » ។[២០]

បួនខែក្រោយមក នៅក្នុងសន្និសីទទូទៅប្រធាន ហ៊ិងគ្លី បានធ្វើការប្រកាសជាប្រវត្តិសាស្ត្រថា សាសនាចក្រនឹងចាប់ផ្ដើមសាងសង់ព្រះវិហារបរិសុទ្ធតូចៗជាងមុន នៅក្នុងតំបន់នានា ដែលគ្មានសមាជិកគ្រប់គ្រាន់ដើម្បីមានព្រះវិហារបរិសុទ្ធដែលធំៗ ។ លោកបានមានប្រសាសន៍ថា « យើងបានសម្រេចចិត្ត . . . នាំយកព្រះវិហារបរិសុទ្ធទៅកាន់មនុស្សទាំងនោះ ហើយផ្ដល់ឱកាសគ្រប់គ្រាន់ដល់ពួកគេ នូវពរជ័យដ៏មានតម្លៃបំផុត ដែលកើតមកពីការថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធ » ។[២១]

នៅក្នុងសន្និសីទទូទៅបន្ទាប់មក ប្រធាន ហ៊ិងគ្លី បានធ្វើការប្រកាសជាប្រវត្តិសាស្ត្រមួយទៀតថា មានគម្រោងបន្តសាងសង់ព្រះវិហារបរិសុទ្ធឲ្យដំណើរការឲ្យបានចំនួន ១០០ នៅចុងឆ្នាំ ២០០០ ។ លោកបានថ្លែងថា « យើងកំពុងបន្តសាងសង់នៅលើមាត្រដ្ឋានមួយ ដែលយើងពុំធ្លាប់ឃើញពីមុន » ។[២២] នៅពេលលោកបានប្រាប់ពីការរីកចម្រើននៃការសាងសង់ព្រះវិហារបរិសុទ្ធនៅក្នុងខែ មេសា ឆ្នាំ ១៩៩៩ លោកបានប្រើឃ្លាដែលយើងធ្លាប់ស្គាល់ដូចនេះ ៖ « នេះគឺជាកិច្ចការដ៏អស្ចារ្យ ទោះបីជាមានបញ្ហា ការលំបាកជាច្រើនក្ដី អ្វីៗនឹងដំណើរការល្អ ហើយខ្ញុំមានទំនុកចិត្តថា យើងនឹងសម្រេចបានគោលដៅរបស់យើង » ។[២៣]

នៅក្នុងខែ តុលា ឆ្នាំ ២០០០ ប្រធាន ហ៊ិងគ្លី បានធ្វើដំណើរទៅទីក្រុង បូស្តុន រដ្ឋ ម៉ាស្សាឈូសេត ស.រ.អា. ដើម្បីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទី ១០០ របស់សាសនាចក្រ—ជាព្រះវិហារបរិសុទ្ធមួយនៃព្រះវិហារបរិសុទ្ធទាំង ២១ ដែលលោកបានឧទ្ទិសឆ្លងនាឆ្នាំនោះនៅលើទ្វីបទាំងបួន ។ នៅពេលលោកទទួលមរណភាព ព្រះវិហារបរិសុទ្ធចំនួន ១២៤ បានសាងសង់ចប់សព្វគ្រប់ ហើយមានព្រះវិហារបរិសុទ្ធចំនួន ១៣ ត្រូវបានប្រកាស ឬ កំពុងសាងសង់ ។

ទស្សនវិស័យរបស់ប្រធាន ហ៊ិងគ្លី ចំពោះអនាគតបានបំផុសលោក ឲ្យស្វែងរកការបំផុសគំនិតអំពីរបៀបផ្សេងៗ ដើម្បីប្រទានពរដល់កូនចៅរបស់ព្រះ ។ លោកមានក្ដីឈឺចាប់ចំពោះការរងទុក្ខ និង ភាពក្រីក្រដែលលោកបានមើលឃើញ ដូច្នោះលោកបានដឹកនាំការពង្រីកជំនួយឧបត្ថម្ភ នៃកិច្ចការមនុស្សធម៌របស់សាសនាចក្រជាពិសេសចំពោះអ្នកដែលមិនមែនជាសមាជិកសាសនាចក្រ ។ លោកក៏បាន



ខាងឆ្វេងខាងលើ ៖ រូបថតទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ និង បណ្ណសារ ។

ផ្តួចផ្តើមមូលនិធិអប់រំជាបន្តបន្ទាប់ ដើម្បីជួយសមាជិកសាសនាចក្រក្នុងប្រទេសដែលមានភាពក្រីក្រយ៉ាងខ្លាំង ។ តាមរយៈមូលនិធិនេះ ពួកគេអាចទទួលបានប្រាក់កម្ចី បង់ថ្លៃអប់រំដែលពួកគេត្រូវការ ដើម្បីទទួលបានការងារប្រសើរជាងមុន ដែលនឹងជួយពួកគេកាត់ផ្តាច់ចំណងនៃភាពក្រីក្រ ហើយមានភាពខ្លួនទីពឹងខ្លួន ។ គិតដល់ត្រឹមឆ្នាំ ២០១៦ មានមនុស្សជាង ៨០,០០០ នាក់បានទទួលឱកាសអប់រំ និងការបំពាក់បំប៉ន តាមរយៈប្រាក់កម្ចីពីមូលនិធិនេះ ។

គំរូផ្សេងទៀតជាច្រើនអំពីទស្សនវិស័យនៃការព្យាកររបស់ប្រធាន ហ៊ិងគ្លី មានដូចជា « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » និង ការសាងសង់មជ្ឈមណ្ឌលសន្និសីទ ត្រូវបានដាក់បញ្ចូលទៅក្នុង *Teachings of Presidents of the Church: Gordon B. Hinckley* ។



**« ទីបន្ទាល់របស់ខ្ញុំ »**

ពីរបីថ្ងៃពីមុនឈានដល់អាយុ ៩១ ឆ្នាំ ប្រធាន ហ៊ិងគ្លី បានកត់ត្រាដូចនេះ ៖ « ខ្ញុំមិនចាំបាច់ដាំដើមឈើទៀតឡើយ ប៉ុន្តែខ្ញុំនឹងដាំវា ។ នេះគឺជាចរិតលក្ខណៈរបស់ខ្ញុំ » ។[២៤] មិនថាលោកមានអាយុចាស់ប៉ុណ្ណាឡើយ ទោះកាលនៅជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេង ឬ ជាព្យាការីអាយុ ៩៧ ឆ្នាំក្តី លោកមានចរិតលក្ខណៈស្រដៀងគ្នា ដើម្បីដាំគ្រាប់ពូជដំណឹងល្អ ហើយវាបានលូតលាស់ឡើងនៅក្នុងចិត្តមនុស្សទូទាំងពិភពលោក ។ លោកបានបម្រើជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់អស់រយៈពេល ២០ ឆ្នាំ ។ ក្រោយមកលោកបានបម្រើជាទីប្រឹក្សាក្នុងគណៈប្រធានទីមួយអស់រយៈពេល ១៤ ឆ្នាំ ។ នៅពេលលោកក្លាយជាប្រធានសាសនាចក្រនៅអាយុ ៨៤ឆ្នាំ នោះលោកបានដឹកនាំសាសនាចក្រឲ្យរីកចម្រើនយ៉ាងខ្លាំងអស់រយៈពេលជិត ១៣ ឆ្នាំ ។

នៅក្នុងការបម្រើដ៏សំខាន់បំផុតក្នុងជីវិតរបស់ប្រធាន ហ៊ិងគ្លី គឺជាទីបន្ទាល់របស់លោកអំពីព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អដែលបានស្តារឡើងវិញតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។ នៅក្នុងសុន្ទរកថាសន្និសីទទូទៅមួយដែលមានចំណងជើងថា « ទីបន្ទាល់របស់ខ្ញុំ » លោកបានបង្ហាញពីទីបន្ទាល់ដូចតទៅនេះ ដោយនិយាយផ្នែកខ្លះនៃទីបន្ទាល់នោះទាំងយំថា ៖

« ក្រៅពីរឿងគ្រប់យ៉ាងទាំងអស់ដែលខ្ញុំមានអារម្មណ៍ថ្លែងអំណរគុណនាព្រឹកនេះ នោះមានរឿងមួយដែលខ្ញុំមានអំណរគុណខ្លាំងបំផុត ។ នោះគឺជាទីបន្ទាល់ដែលខ្ញុំមានអំពីព្រះយេស៊ូវគ្រីស្ទ ។ . . .

« *ទ្រង់គឺជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់ខ្ញុំ* ។ តាមរយៈការប្រទានជីវិតរបស់ទ្រង់ដោយការឈឺចាប់ និងការរងទុក្ខដែលមិនអាចថ្លែងបាននោះ ទ្រង់បានលូកព្រះហស្តចុះមកលើកខ្ញុំឡើង និង ដល់យើងម្នាក់ៗ និង ដល់បុត្រាបុត្រីទាំងឡាយរបស់ព្រះចេញពីអន្លង់ដ៏ជ្រៅនៃភាពងងឹតដ៏អស់កល្បបន្ទាប់ពីសេចក្តីស្លាប់ទៅ ។ . . .

« *ទ្រង់គឺជាព្រះ និង ជាស្តេចរបស់ខ្ញុំ* ។ ចេញពីភាពដ៏អស់កល្បទៅភាពដ៏អស់កល្ប នោះទ្រង់នឹងសោយរាជ្យ ហើយគ្រប់គ្រងជាស្តេចលើអស់ទាំងស្តេច ហើយព្រះលើអស់ទាំងព្រះ ។ ការគ្រប់គ្រងរបស់ទ្រង់គ្មានទីបញ្ចប់ឡើយ ។ សិរីល្អរបស់ទ្រង់គ្មានភាពងងឹតឡើយ ។ . . .

« ដោយអំណរគុណ និង ដោយសេចក្តីស្រឡាញ់ដ៏លើសលុប នោះខ្ញុំសូមថ្លែងទីបន្ទាល់អំពីកិច្ចការទាំងនេះនៅក្នុងព្រះនាមដ៏ពិសិដ្ឋរបស់ទ្រង់ » ។[២៥] ■

**កំណត់ចំណាំ**


១. ទិនានុប្បវត្តិ របស់ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៣ ។
២. ហ្គរដុន ប៊ី ហ៊ិងគ្លី *Standing for Something: Ten Neglected Virtues That Will Heal Our Hearts and Homes* ( ឆ្នាំ ២០០០ ) ទំព័រ ១០១ ។
៣. *Teachings of Presidents of the Church: Gordon B. Hinckley* ( ឆ្នាំ ២០១៦ ) ទំព័រ ៧០ ។
៤. ជែហ្វ្រី អ័រ ហូឡិន « President Gordon B. Hinckley: Stalwart and Brave He Stands » *Ensign* ខែ មិថុនា ឆ្នាំ ១៩៩៥ ទំព័រ ៤ ។
៥. *Teachings: Gordon B. Hinckley* ទំព័រ ៣៣៩ ។
៦. នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩៦៩ ទំព័រ ១១៣ ។
៧. *Teachings of Gordon B. Hinckley* ( ឆ្នាំ ១៩៩៧ ) ទំព័រ ៤១២ ។
៨. ទិនានុប្បវត្តិ ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៣ ។
៩. Teachings: Gordon B. Hinckley ទំព័រ ២៩៨–៩៩ ។
១០. ទិនានុប្បវត្តិ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦ ។
១១. ទិនានុប្បវត្តិ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦ ។
១២. ទិនានុប្បវត្តិ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៩៦ ។
១៣. ទិនានុប្បវត្តិ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០២ ។
១៤. នៅក្នុង « The Prophet Spoke to Youth » *In Memoriam: President Gordon B. Hinckley* ឆ្នាំ ១៩១០–២០០៨ ( អត្ថបទបន្ថែមលើ *Ensign* ខែ មីនា ឆ្នាំ ២០០៨ ) ទំព័រ ១៥ ។
១៥. ទិនានុប្បវត្តិ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៤ ។
១៦. ទិនានុប្បវត្តិ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៩៥ ។
១៧. ហិនរី ប៊ី អាររិង នៅក្នុង *Teachings: Gordon B. Hinckley* ទំព័រ ២០២ ។
១៨. នៅក្នុង *Teachings: Gordon B. Hinckley* ទំព័រ ៣១៣ ។
១៩. ដុន អេច ស្តាហេលី ឯកសារសម្ភាសន៍ផ្ទាល់មាត់ ( ឆ្នាំ ២០១២ ) ទំព័រ ៨៥ Church History Library ។
២០. ទិនានុប្បវត្តិ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៩៩ ។ ឯកសារនេះគឺជាសេចក្តីសង្ខេបនៃសុន្ទរកថារបស់លោក នៅវគ្គដំបូងនៃការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធកូឡូនៀ ជូរ៉េស មិកស៊ិក ។ ប្រធាន ហ៊ិងគ្លី បានពិចារណាអំពីព្រះវិហារបរិសុទ្ធតូចៗអស់ពេលជាង ២០ ឆ្នាំ ( សូមមើល Teachings: Gordon B. Hinckley ទំព័រ ៣៣ ៣០៩–១០ ) ។
២១. ហ្គរដុន ប៊ី. ហ៊ីងគ្លី « Some Thoughts on Temples, Retention of Converts, and Missionary Service » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ទំព័រ ៥០ ។
២២. *Teachings: Gordon B. Hinckley* ទំព័រ ៣១០ ។
២៣. ហ្គរដុន ប៊ី ហ៊ីងគ្លី « The Work Moves Forward » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៩ ទំព័រ ៤ ។
២៤. ទិនានុប្បវត្តិ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០១ ។
២៥. *Teachings: Gordon B. Hinckley* ទំព័រ ៣២១-២៣ ។





**ដោយអែលឌើរ គ្រីស្តូហ្វិល ហ្គូលឌិន**
ក្នុងពួកចិតសិបនាក់

# ចូរក្លាហាន

## ក្នុងទីបន្ទាល់របស់យើងអំពីព្រះអង្គសង្គ្រោះ

*យើងម្នាក់ៗនឹងត្រូវបានហៅឲ្យធ្វើកិច្ចការក្នុងគ្រាលំបាក ហើយដែលនឹងលុតដំពូកយើង ។ គ្រាទាំងនេះនឹងកំណត់អំពីខ្លួនយើង និង អ្វីដែលយើងនឹងប្រែក្លាយ ។*

ជាយូរឆ្នាំមកហើយ កាលខ្ញុំនៅក្មេង ខ្ញុំត្រូវបានបង្ខំឲ្យ—ឬហៅម៉្យាងទៀតថា « កេណ្ឌទ័ព » —ធ្វើជាទាហាននៅអាហ្វ្រិកភាគខាងត្បូង ។ ខ្ញុំត្រូវបានចាត់ឲ្យចូលក្រុមជាមួយទាហាន ដែលជាមនុស្សល្អ ប៉ុន្តែនិយាយ និង មានឫកពាបាតផ្សារ ហើយជួនកាលរឿងនេះវាបង្ហាញឡើងដោយបុរសដែលបម្រើក្នុងជួរកងទ័ព ។

ខ្ញុំបានឃើញថា វាមិនងាយស្រួលឡើយដើម្បីរស់នៅតាមបទដ្ឋានដំណឹងល្អ ក្នុងស្ថានភាពបែបនេះ ។ ប៉ុន្តែតាំងពីគ្រាចាប់ផ្តើមការបម្រើជាកងទ័ពមក ខ្ញុំរីករាយឈរយ៉ាងរឹងប៉ឹងចំពោះជំនឿរបស់ខ្ញុំ ។ ខ្ញុំបានប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់ថា ខ្ញុំនឹងមិនពាក់ព័ន្ធក្នុងសកម្មភាពដែលខ្ញុំដឹងថាខុសឆ្គងឡើយ ។ ខ្ញុំសប្បាយចិត្តនឹងនិយាយថា បុរសៗដែលនៅក្នុងក្រុមរបស់ខ្ញុំ—មានមួយចំនួនដែលមិនពេញចិត្តនឹងខ្ញុំនៅគ្រាដំបូងនោះ—បែរជាមានការគោរពចំពោះបទដ្ឋានរបស់ខ្ញុំវិញ ។

មានគ្រាមួយនោះ នៅបន្ទាយបំពាក់បំប៉នទាហាន ក្រុមរបស់យើងបានឈរនៅជុំវិញភ្នក់ភ្លើងជំរំនៅក្នុងរាត្រីដ៏ស្រស់ស្អាត នារាត្រីដ៏ងងឹត ដែលមានមេឃស្រឡះ ជារាត្រីដែលពេញដោយពន្លឺផ្កាយ ។ បុរសមួយចំនួននៅក្នុងក្រុមរបស់ខ្ញុំ ផឹកស្រាបៀរ ប៉ុន្តែខ្ញុំផឹកទឹកក្រូច ។ ការពិភាក្សាបានប្រកបដោយក្តីរីករាយ គ្មានការនិយាយមិនសមរម្យឡើយ ។

អំឡុងពេលទស្សនកិច្ចរបស់យើង បុរសពីរបីនាក់មកពីអង្គភាពផ្សេងបានដើរចូលមកក្រុមដ៏រីករាយរបស់យើង ។ បុរសម្នាក់ក្នុងចំណោមនោះបានងាកមើលខ្ញុំ ដោយឃើញខ្ញុំកាន់ទឹកក្រូច បានសើចចំអកឲ្យខ្ញុំ ដែលពុំព្រមចូលរួមផឹកស្រាបៀរជាមួយបុរសទាំងនោះ ។ ពីមុនខ្ញុំឆ្លើយតប ខ្ញុំមានចិត្តរំភើប ដោយសារមានមិត្តភក្តិខ្ញុំម្នាក់បានស្តីបន្ទោសឲ្យបុរសម្នាក់នោះ ។

គាត់បាននិយាយថា « យើងសូមឲ្យលោកចេញទៅឥឡូវនេះ ។ យើងនឹងមិនឲ្យនរណាម្នាក់និយាយបែបនេះដាក់គ្រីសឡើយ ! ប្រាកដណាស់គាត់ជាមនុស្សតែម្នាក់គត់ក្នុងចំណោមពួកយើងដែលរស់នៅដូចជាពួកគ្រិស្តសាសនិកពិតប្រាកដ » ។

រចនារូបភាពដោយ ដេន បើរ

បន្ទាប់ពីមិត្តរបស់ខ្ញុំនិយាយដូច្នោះហើយ បុរសនោះបានដើរចេញទៅវិញដោយក្តីខ្មាសអៀន ។ នៅគ្រានោះ ទោះបីមានការខ្មាសអៀនបន្តិចដោយការសរសើរដែលខ្ញុំពុំបានរំពឹងទុក ខ្ញុំមានអំណរគុណក្នុងចិត្ត ដែលខ្ញុំបានជ្រើសរើសធ្វើតាមការទូន្មានរបស់ប៉ុលឲ្យធ្វើជា « គំរូដល់ពួកអ្នកជឿ » ( ធីម៉ូថេទី ១ ៤:១២ ) ។

អ្នកទាំងអស់គ្នាក៏ប្រឈមមុខនឹងការជ្រើសរើសនានា ជាពិសេសក្នុងគ្រានេះនៃជីវិតរបស់អ្នក នៅពេលស្មារតីរបស់អ្នកត្រូវផ្តោតចិត្តទុកដាក់ជាពិសេស និងការទទួលយកឱកាសដ៏អស្ចារ្យនានាដែលរង់ចាំអ្នក ។ សំណួរនោះគឺថា តើអ្នកនឹងចង់សរសេរអ្វីអំពីខ្លួនអ្នកក្នុងរយៈពេល ៥, ១០—ឬ ២០ ឆ្នាំខាងមុខទៀតនោះ ឬរហូតដល់ពេលអ្នកស្លាប់ ?

**តើការមានចិត្តក្លាហានមានន័យដូចម្តេច ?**

នៅក្នុងការនិមិត្តដ៏អស្ចារ្យបំផុតមួយដែលបានកត់ត្រានៅក្នុងព្រះគម្ពីរដ៏បរិសុទ្ធ ព្យាការី យ៉ូសែប ស្ម៊ីធ បានពិពណ៌នាអំពីលក្ខខណ្ឌរបស់អស់អ្នកដែលនឹងគ្រងនគរសេឡេស្ទាលទុកជាមរតក បន្ទាប់ពួកគេបានរស់ឡើងវិញ និង បន្ទាប់ពីការជំនុំជម្រះ ។ កណ្ឌដដែលនេះនៅក្នុងគម្ពីរគោលលទ្ធិ និង សេចក្តីសញ្ញា ( កណ្ឌ ៧៦ ) ក៏បើកសម្តែងពីលក្ខខណ្ឌ និង កាលៈទេសៈនៃអស់អ្នកដែលពុំសមនឹងទទួលនគរសេឡេស្ទាល ប៉ុន្តែជាអស់អ្នកដែលនឹងទទួលនគរទេរេស្ទ្រាល និងនគរទេឡេស្ទាលជំនួសវិញ ។

ក្នុងការថ្លែងពីអស់អ្នកដែលនឹងគ្រងនគរទេរេសស្ទ្រាលទុកជាមរតកនោះ វិវរណៈនេះបង្រៀនយើងថាពួកគេ « [ ជា ] មនុស្សមានកិត្តិយសនៅលើផែនដី ដែលខ្វាក់ដោយសារឧបាយកលនៃមនុស្ស. . . [ និង ] ដែលទទួលសិរីល្អ [ របស់ព្រះ ] ប៉ុន្តែពុំមែនភាពពោរពេញរបស់ទ្រង់ឡើយ » ( គ. និង ស. ៧៦:៧៥–៧៦ ) ។ បន្ទាប់មកយើងរៀនពីគោលការណ៍ដ៏គួរឲ្យភ្ញាក់ផ្អើលនេះ ៖ « ពួកគេនេះហើយដែល *ពុំក្លាហានក្នុងទីបន្ទាល់ពីព្រះយេស៊ូវ* ហេតុដូច្នោះហើយ ពួកគេពុំបានមកុដលើនគរនៃព្រះរបស់យើងឡើយ » ( គ. និង ស. ៧៦:៧៩ ការគូសបញ្ជាក់បានបន្ថែម ) ។

*ក្លាហានគឺការរស់នៅតាមជំនឿរបស់យើង អនុវត្តអ្វីដែលយើងបង្រៀន រក្សាបទបញ្ញត្តិទាំងឡាយ ។*

សូមគិតពីរឿងនោះបន្តិច ។ តើយើងនឹងបាត់បង់សិរីល្អនៃនគរសេឡេស្ទាលរួមទាំងពរជ័យដ៏មហិមា និង អស់កល្បជានិច្ចរបស់នគរនេះ ដោយសារតែយើងពុំក្លាហានក្នុងការថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវ នៅលើផែនដីនេះនៅក្នុងសេចក្តីជំនឿជីវិតរមែងស្លាប់ ស្ថានភាពសាកល្បងរបស់យើងឬ ?

តើភាពក្លាហានក្នុងទីបន្ទាល់អំពីព្រះយេស៊ូវមានន័យដូចម្តេច ? សាវកមួយរូបនាសម័យទំនើបរបស់ព្រះអម្ចាស់បានប្រកាសដូចនេះ ៖

« វាតម្រូវឲ្យមានភាពអង់អាច និង មោះមុត ដើម្បីប្រើភាពខ្លាំង ថាមពល និង សមត្ថភាពរបស់យើងនៅក្នុងចម្បាំងជាមួយលោកិយ ដើម្បីច្បាំងសម្រាប់សេចក្តីល្អនៃសេចក្តីជំនឿ ។ . . . មូលដ្ឋានគ្រឹះដ៏ធំនៃភាពក្លាហាននៅក្នុងបុព្វហេតុនៃសុចរិតភាព គឺជាការគោរពប្រតិបត្តិចំពោះក្រឹត្យវិន័យទាំងអស់នៃដំណឹងល្អទាំងស្រុង ។

ក្លាហានក្នុងទីបន្ទាល់អំពីព្រះយេស៊ូវគឺ ‹ មករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ › ដ្បិតយើងត្រូវលះបង់ចោលនូវ ‹ អស់ទាំងអំពើដ៏ឥតបរិសុទ្ធ › ហើយ ‹ ស្រឡាញ់ព្រះ › ឲ្យអស់ពី ‹ សមត្ថភាព អស់ពីគំនិត និងអស់ពីកម្លាំង › របស់យើង ( ម៉ូរ៉ូណៃ ១០:៣២ ) ។

« ក្លាហានក្នុងទីបន្ទាល់អំពីព្រះយេស៊ូវគឺ ត្រូវជឿលើព្រះគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់ជាមួយនឹងជំនឿឥតងាករេ ។ ត្រូវដឹងពីសេចក្តីពិត និង ទេវភាពនៃកិច្ចការរបស់ព្រះអម្ចាស់នៅលើផែនដី ។ . . .

ក្លាហានក្នុងទីបន្ទាល់អំពីព្រះយេស៊ូវគឺត្រូវ ‹ ឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លានៃសេចក្តីសង្ឃឹមដ៏ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប › ។ ត្រូវ ‹ កាន់ខ្ជាប់ដរាបដល់ចុងបំផុត › ( នីហ្វៃទី ២ ៣១:២០ ) ។ ត្រូវរស់នៅតាមជំនឿរបស់យើង អនុវត្តអ្វីដែលយើងបង្រៀន រក្សាបទបញ្ញត្តិទាំងឡាយ ។ ត្រូវបង្ហាញអំពី ‹ សាសនាដែលបរិសុទ្ធ › នៅក្នុងជីវិតមនុស្ស ត្រូវទៅសួរសុខទុក្ខ ‹ ពួកកំព្រា និង ពួកមេម៉ាយក្នុងកាលដែលគេមានសេចក្តីវេទនា › ហើយឲ្យរក្សាខ្លួនរបស់យើង ‹ មិនឲ្យប្រឡាក់ដោយលោកិយនេះឡើយ › ( យ៉ាកុប ១:២៧ ) ។

« ក្លាហានក្នុងទីបន្ទាល់អំពីព្រះយេស៊ូវគឺត្រូវទប់អស់ទាំងតណ្ហារបស់យើង គ្រប់គ្រងតម្រេករបស់យើង ហើយយកឈ្នះលើរឿងកាមគុណ និង អំពើអាក្រក់ទាំងឡាយ ។ ត្រូវយកឈ្នះលោកិយនេះ ដូចដែលទ្រង់បានធ្វើជាគំរូដ៏ល្អឥតខ្ចោះ ហើយបង្ហាញអង្គទ្រង់ថាជាអ្នកដែលក្លាហានបំផុតក្នុងចំណោមកូនចៅរបស់ព្រះវរបិតារបស់យើង ។ ត្រូវមានក្រមសីលធម៌ស្អាតស្អំ ត្រូវថ្វាយដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗ ត្រូវគោរពថ្ងៃឈប់សម្រាក ត្រូវអធិស្ឋានដោយស្មោះអស់ពីចិត្ត ត្រូវលះបង់អ្វីៗទាំងអស់ដែលជារបស់យើងលើអាសនា ប្រសិនបើយើងត្រូវបានសូមឲ្យធ្វើបែបនោះ ។

« ក្លាហានក្នុងទីបន្ទាល់អំពីព្រះយេស៊ូវគឺត្រូវ នៅខាងព្រះអម្ចាស់គ្រប់រឿងទាំងអស់ ។ ត្រូវជ្រើសរើសដូចទ្រង់បានជ្រើសរើស ។ ត្រូវគិតដូចទ្រង់ព្រះតម្រិះ ជឿអ្វីដែលទ្រង់ជឿ និយាយអ្វីដែលទ្រង់បានមានបន្ទូល ហើយធ្វើអ្វីដែលទ្រង់បានធ្វើនៅក្នុងស្ថានភាពដូចគ្នានេះ ។ ត្រូវស្គាល់គំនិតរបស់ព្រះគ្រីស្ទ ហើយរួបរួមនឹងទ្រង់ដូចជាទ្រង់រួបរួមនឹងព្រះវរបិតាទ្រង់ដែរ » ។[១]

ឥឡូវខ្ញុំសូមបន្ថែមអ្វីមួយដែលព្រះអង្គសង្គ្រោះរបស់យើង គឺព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ បានបង្រៀនអំឡុងពេលទ្រង់គង់នៅលើផែនដីក្នុង ការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ៖

« កុំឲ្យស្មានថា ខ្ញុំមកនឹងតាំងឲ្យមានសេចក្តីមេត្រីនៅផែនដីឡើយ ខ្ញុំមិនមែនមក



ដើម្បីតាំងឲ្យមានសេចក្ដីមេត្រីទេ គឺឲ្យមានដាវវិញ ។

ដ្បិតខ្ញុំបានមក ដើម្បីនឹងនាំឲ្យគេទាស់នឹងឪពុកខ្លួន ឲ្យកូនស្រីទាស់នឹងម្ដាយ ហើយកូនប្រសាស្រីទាស់នឹងម្ដាយក្មេក ។

ឯពួកសត្រូវរបស់អ្នកណា នោះគឺជាពួកអ្នកនៅផ្ទះជាមួយនឹងខ្លួននោះឯង ។

អ្នកណាដែលស្រឡាញ់ឪពុក ឬម្ដាយជាជាងខ្ញុំ នោះមិនគួរនឹងខ្ញុំទេ ហើយអ្នកណាដែលស្រឡាញ់កូនប្រុស ឬកូនស្រី ជាជាងខ្ញុំនោះក៏មិនគួរនឹងខ្ញុំដែរ ។

អ្នកណាដែលមិនយកឈើឆ្កាងខ្លួនមកតាមខ្ញុំ អ្នកនោះមិនគួរនឹងខ្ញុំឡើយ ។

អ្នកណាដែលរកបានជីវិតខ្លួន នោះនឹងត្រូវបាត់ជីវិតទៅតែអ្នកណា ដែលបាត់ជីវិតដោយយល់ដល់ខ្ញុំ អ្នកនោះនឹងបានជីវិតវិញ » ( ម៉ាថាយ ១០:៣៤–៣៩ ) ។

គោលបំណងរបស់យើងនៅក្នុងជីវិតរមែងស្លាប់នេះ គឺគ្មានអ្វីក្រៅពីការរៀបចំខ្លួនដើម្បីរស់នៅម្ដងទៀត ក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌ដែលពោរពេញដោយក្ដីស្រឡាញ់របស់យើង ក្នុងនាមជាអ្នកគ្រងមរតកស្មើនឹងព្រះយេស៊ូវគ្រីស្ទ ។ សិរីរុងរឿងនេះមាននៅក្នុងក្រុមគ្រួសារអស់កល្បជានិច្ច នៅជាមួយភរិយា ឬ ស្វាមី និង កូនៗ ព្រមទាំងពូជពង្សរបស់យើង គឺមានដល់មនុស្សគ្រប់គ្នា ទោះជាមនុស្សមួយចំនួននឹងទទួលពរជ័យនៃការបង្កើតក្រុមគ្រួសារតែនៅបន្ទាប់ពីជីវិតរមែងស្លាប់នេះប៉ុណ្ណោះក្ដី ។

ពរជ័យបែបនោះតម្រូវឲ្យយើងលីឈើឆ្កាង ហើយបន្ដក្លាហានរហូតដល់ទីបំផុតក្នុងទីបន្ទាល់ ហើយបម្រើព្រះអម្ចាស់ដែលជាព្រះអង្គសង្គ្រោះរបស់យើង ។

**រៀបចំខ្លួនដើម្បីប្រព្រឹត្តតាម**

ផ្លូវដែលយើងម្នាក់ៗតម្រូវឲ្យដើរតាមនោះមានឱកាស និង ឧបសគ្គជាច្រើន ។ យើងតម្រូវឲ្យធ្វើការសម្រេចចិត្តជាច្រើនរៀងរាល់ថ្ងៃ—ការសម្រេចចិត្តមួយចំនួនវាតូចតាច និង ទំនងដូចជាមិនសូវសំខាន់ រីឯការសម្រេចចិត្តមួយចំនួនទៀតសំខាន់ និង មានលទ្ធផលយូរអង្វែង ។

វាគឺជារឿងពិតដែលយើងម្នាក់ៗនឹងត្រូវបានហៅឲ្យធ្វើកិច្ចការក្នុងគ្រាលំបាក ហើយដែលនឹងលុតដំពួកយើង ។ គ្រាទាំងនេះនឹងកំណត់អំពីខ្លួនយើង និង អ្វីដែលយើងនឹងប្រែក្លាយ ។ ជារឿយៗគ្រាទាំងនោះកើតឡើង នៅពេលវាមិនសមស្រប ហើយមិនទូលំទូលាយដើម្បីប្រព្រឹត្តវាដោយសុចរិត និង ដោយចិត្តក្លាហាន ។



អ្នកនឹងជួបរឿងបែបនេះ នៅពេលអ្នកសរសេរពីរឿងរ៉ាវក្នុងជីវិតរបស់អ្នក ជាគ្រាដែលលុតដំអ្នកខ្លាំងបំផុត ដែលអ្នកធ្លាប់ជួប នៅពេលអ្នកឈរយ៉ាងរឹងប៉ឹងតែម្នាក់ឯងនោះ ។

ឥឡូវនេះខ្ញុំនិយាយពីរឿងមួយនៃការឈរយ៉ាងរឹងប៉ឹងតែឯងនៅក្នុងចំណោមការប្រឆាំងដ៏ធំធេង ។ មានគ្រាមួយអំឡុងខែ វិច្ឆិកា ឆ្នាំ ១៨៣៨ ព្យាការី យ៉ូសែប ស្ម៊ីធ និង អ្នកផ្សេងទៀត រួមទាំង អែលឌើរ ប៉ាលី ភី ប្រាត្ត ( ឆ្នាំ ១៨០៧–៥៧ ) ត្រូវបានជាប់ច្រវ៉ាក់ ហើយដាក់គុកនៅក្នុងទីក្រុង រិចម៉ន្ត រដ្ឋ មិសសួរី ស.រ.អា. ។

អែលឌើរ ប្រាត្ត កត់ត្រាអំពីហេតុការណ៍ដូចតទៅនេះអំឡុងពេលពួកលោកជាប់គុក ៖

« នៅយប់ដ៏អាប់អួមួយនោះ យើងបានទម្រេតខ្លួន ដូចជាដេកលក់ រហូតដល់យប់ជ្រៅ តែត្រចៀក និងដួងចិត្តយើងឈឺចាប់ ពេលយើងស្ដាប់ឮរាប់ម៉ោងនូវការចំអក ពាក្យជេរអាក្រក់ៗ ការប្រមាថគួរឲ្យខ្លាច និងភាសាស្មោកគ្រោករបស់ពួកអ្នកយាម ដែលមេក្លោងរបស់ពួកគេគឺវរសេនីយឯក ប្រាយ ហើយពួកគេនិយាយរៀបរាប់ប្រាប់គ្នាអំពីទង្វើឆក់ប្លន់ កាប់សម្លាប់ ការលួច ជាដើម ដែលពួកគេបានធ្វើចំពោះ ‹ *ពួកមរមន* › និង ពួកអ្នកជិតខាង អំឡុងពេលនៅ ហ្វារវែស្ទ [ រដ្ឋមិសសួរី ] ។ ពួកគេថែមទាំងបានអួតអាងអំពីការបង្ខូចព្រហ្មចារី ដោយការចាប់រំលោភភរិយា កូនស្រី និង ស្រីព្រហ្មចារិយ និង ការបាញ់សម្លាប់ ឬ វាយបំបែកក្បាលរបស់បុរស ស្ត្រី និង ក្មេងៗ ។

ខ្ញុំបានស្ដាប់ឮរហូតដល់ខ្ញុំខ្ពើមឆ្អើមជាខ្លាំង តក់ស្លុត និង ពេញដោយកំហឹងដែលវាពិបាកសម្រាប់ខ្ញុំ ដើម្បីអត់ទ្រាំពុំបាននឹងឈរឡើង ហើយស្ដីបន្ទោសដល់ពួកអ្នកយាមនោះ ប៉ុន្តែខ្ញុំពុំនិយាយអ្វីទាំងអស់ទៅយ៉ូសែប ឬ អ្នកផ្សេងទៀតទោះបីខ្ញុំដេកនៅជិតនឹងលោក ហើយបានដឹងថាលោកពុំទាន់ដេកក្ដី ។ រំពេចនោះ លោកបានក្រោកឈរឡើង ហើយនិយាយដូចជាសំឡេងផ្គរលាន់ ឬដូចជាតោគ្រហឹម និយាយយ៉ាងច្បាស់ដែលខ្ញុំអាចនៅចាំបានថា

« ‹ ស្ងាត់ទៅ ! មនុស្សអាក្រក់ក្នុងរណ្ដៅដ៏អប្រិយអើយ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ខ្ញុំស្ដីបន្ទោសដល់អ្នក ហើយបញ្ជាឲ្យអ្នកស្ងាត់ភ្លាម ដ្បិតខ្ញុំនឹងមិនរស់នៅមួយនាទីទៀត ហើយស្ដាប់ឮភាសាដូច្នេះឡើយ ។ ឈប់និយាយភ្លាម បើមិនដូច្នោះអ្នក ឬខ្ញុំនឹងស្លាប់ឥឡូវនេះ ! ›

« លោកបានឈប់វាចា ។ លោកបានឈរយ៉ាងមុតមាំនៅក្នុងមហិទ្ធានុភាពខ្លាំងណាស់ ។ ដោយជាប់ច្រវ៉ាក់ និងគ្មានអាវុធផងនោះលោកស្ងប់ស្ងាត់ មិន

ក្រញេងក្រញាង ហើយថ្លៃថ្នូរប្រៀបដូចជាទេវតាមួយអង្គ នោះលោកបានមើលទៅអ្នកយាម ដែលដាក់អាវុធចុះ ឬ ទម្លាក់វាទៅលើដី ឱបជង្គង់រួញខ្លាចនៅគៀនជញ្ជាំង ឬក្រាបចុះនឹងជើងលោក បានសុំទោសដល់លោក ហើយនៅស្ងៀមរហូតដល់វេនផ្លាស់ប្តូរអ្នកយាម » ។[២]

ភាពក្លាហានដែលព្យាការី យ៉ូសែប ស្ម៊ីធ បានបង្ហាញពុំបានត្រៀមទុកសម្រាប់ព្យាការី ឬ សមាជិកសាសនាចក្រពីមុនឡើយ ។ មានឧបទ្ទវហេតុមួយនៅក្នុងជីវិតរបស់ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ( ឆ្នាំ ១៨៣៨–១៩១៨ ) មាននូវភាពក្លាហាននេះ ។ នៅក្នុងរដូវស្លឹកឈើជ្រុះឆ្នាំ ១៨៥៧ កាលលោកមានអាយុ ១៩ ឆ្នាំ យ៉ូសែប អេហ្វ បានត្រឡប់មកពីបេសកកម្មដែលលោកបានបម្រើនៅ ហាវ៉ៃ ស.រ.អា. នោះលោកបានចូលរួមនឹងក្រុមរទេះសេះនៅក្នុងរដ្ឋ កាលីហ្វូញ៉ា ស.រ.អា. ។ វាគឺជាគ្រាដ៏មានគ្រោះថ្នាក់បំផុតសម្រាប់ពួកបរិសុទ្ធ ។ ទាហានរបស់ ចនស្តុន កំពុងធ្វើព្យុហយាត្រាតម្រង់ទៅរដ្ឋ យូថាហ៍ ហើយមនុស្សជាច្រើនមានអារម្មណ៍មិនល្អចំពោះសាសនាចក្រ ។

ល្ងាចមួយ ពួកទុច្ចរិតមួយចំនួនបានជិះសេះចូលមកក្នុងជំរុំក្រុមរទេះសេះ ដោយជេរផ្តាសារ ហើយគំរាមកំហែងធ្វើបាបពួកមរមនគ្រប់រូបដែលពួកគេជួប ។ មនុស្សភាគច្រើនដែលនៅក្នុងក្រុមរទេះសេះនោះបានលាក់ខ្លួនក្នុងគុម្ពោតព្រៃ ប៉ុន្តែ យ៉ូសែប អេហ្វ បានគិតក្នុងចិត្តលោកដូចនេះ ៖ « តើខ្ញុំនឹងរត់ចេញពីបងប្អូនទាំងនេះឬ ? ហេតុអ្វីខ្ញុំគួរតែខ្លាចពួកគេ ? »

ដោយគិតបែបនោះ លោកបានដើរសំដៅទៅរកម្នាក់ដែលឈ្លានពានចូលមកនោះ ដោយមានកាន់កាំភ្លើងខ្លីនៅក្នុងដៃ ដែលស្រែកសួរថា « តើឯងជាពួកមរមនឬ ? »

យ៉ូសែប អេហ្វ បានឆ្លើយតបថា « បាទលោក ខ្ញុំគឺជាអ្នកជឿស៊ប់ មិនងាករេ ជឿទាំងស្រុង » ។

នៅពេលនោះ មនុស្សទុច្ចរិតនោះបានចាប់ដៃរបស់លោក ហើយនិយាយថា « ឯងជា ——— ——— មនុស្សដែលគួរឲ្យចូលចិត្តបំផុតដែលខ្ញុំធ្លាប់ជួបពីមុនមក ! ល្អណាស់ អ្នកកម្លោះអើយ យើងសប្បាយចិត្តដោយជួបមនុស្សម្នាក់ ដែលឈរយ៉ាងរឹងប៉ឹងចំពោះជំនឿស៊ប់របស់ខ្លួនបែបនេះ » ។[៣]

ឥឡូវនេះអ្នកធ្លាប់ជួបនូវគ្រាសំខាន់មួយចំនួននៅក្នុងជីវិតរបស់អ្នក ! ឥឡូវនេះអ្នកកំពុងសរសេរ ឬ នឹងសរសេរពីមួយគ្រាទៅមួយគ្រា នូវប្រវត្តិផ្ទាល់ខ្លួនរបស់អ្នក ។ អ្នកនឹងមានគ្រាដែលត្រូវតែប្រព្រឹត្ត ទោះជាមានគ្រាផ្សេងទៀត ដែលអ្នកមិនប្រព្រឹត្តដោយវាងវៃក្តី ។ មានឱកាស ការសម្រេចចិត្តជាច្រើនដែលនឹងត្រូវធ្វើ ហើយឧបសគ្គនានាដែលនឹងកើតមានឡើងនៅចំពោះមុខ ។

នៅក្នុងផែនការដ៏មហិមារបស់ព្រះវរបិតាសួគ៌យើង ចូរចងចាំថាយើងមិននៅតែឯងឡើយ ! មនុស្សជាច្រើននៅក្នុងជីវិតនេះ និង មនុស្សជាច្រើនដែលនៅជ្រុងម្ខាងទៀតនៃជីវិតរមែងស្លាប់ ជារៀងរាល់ថ្ងៃកំពុងអង្វរជំនួសអ្នករាល់គ្នានៅចំពោះព្រះអម្ចាស់ ។ អំណាចដ៏មហិមាបានប្រទានដល់អ្នក តាមរយៈពិធីបរិសុទ្ធដែលអ្នកបានទទួល និង សេចក្តីសញ្ញាដែលអ្នកបានចុះ ។ លើសពីអ្វីទាំងអស់នោះ ព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រាទ្រង់ដែលពេញដោយក្តីស្រឡាញ់—គឺព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ជាអង្គគាំទ្ររបស់យើង—កំពុងមានវត្តមានជួយអ្នកឲ្យហែលឆ្លងកាត់ក្នុងជីវិតនេះ ។ នៅក្នុងការបង្រៀនដ៏មានឥទ្ធិពលមួយ អំឡុងពេលនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ ទ្រង់បានប្រទានការអញ្ជើញដល់មនុស្សគ្រប់រូប ហើយក៏អញ្ជើញដល់ពួកយើងម្នាក់ៗផងដែរ ៖

« អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សម្រាក ។

ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាពនោះអ្នករាល់គ្នានឹងបានសម្រាកដល់ព្រលឹង ។

ពីព្រោះនឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល » ( ម៉ាថាយ ១១: ២៨–៣០ ) ។

ខ្ញុំសូមថ្លែងទីបន្ទាល់យ៉ាងមុតមាំអំពីព្រះជន្មដ៏ពិតប្រាកដរបស់ព្រះជាព្រះវរបិតាដ៏អស់កល្បជានិច្ច និងព្រះរាជបុត្រារបស់ទ្រង់ជាព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ ខ្ញុំក៏សូមថ្លែងទីបន្ទាល់ផងដែរថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺពិតជាសាសនាចក្រដែលបានស្តារឡើងវិញរបស់ព្រះអម្ចាស់ និងជានគរព្រះនៅលើផែនដីនេះ ។

សូមឲ្យខ្ញុំ—និង អស់អ្នកដែលចែកចាយទីបន្ទាល់នេះ—បន្តមានចិត្តក្លាហានចំពោះបុព្វហេតុដ៏អស្ចារ្យនេះ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាមួយ ដែលមានចំណងជើងថា « Being Valiant » ដែលបានថ្លែងនៅមហាវិទ្យាល័យពាណិជ្ជកម្ម អិល.ឌី.អេស. កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៤ ។ ដើម្បីទទួលបានសុន្ទរកថាទាំងស្រុង ជាភាសាអង់គ្លេស សូមចូលទៅគេហទំព័រ ldsbc.edu ។*

**កំណត់ចំណាំ**


១. ប្រ៊ូស អ័រ ម៉ាក់ខន់ឃី « Be Valiant in the Fight of Faith » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៤ ទំព័រ ៣៥ ។
២. *Autobiography of Parley Parker Pratt* បានបោះពុម្ព Parley P. Pratt Jr. ( ឆ្នាំ ១៩៣៨ ) ទំព័រ ២១០–១១ ។
៣. សូមមើល *Teachings of Presidents of the Church: Joseph F. Smith* ( ឆ្នាំ ១៩៩៨ ) ទំព័រ ១០៤ ។




**ការឈរយ៉ាងរឹងប៉ឹងចំពោះអ្វីដែលយើងជឿ**

« សូមយើងមានភាពក្លាហានជានិច្ច ហើយរៀបចំខ្លួនដើម្បីឈរគាំទ្រចំពោះអ្វីដែលយើងជឿ ហើយបើយើងត្រូវឈរម្នាក់ឯងនៅក្នុងដំណើរការនោះ ចូរយើងធ្វើដូច្នោះដោយភាពក្លាហានបានពង្រឹងដោយចំណេះដឹងដែលតាមពិតនោះ យើងមិនដែលនៅម្នាក់ឯងទេ ពេលយើងឈរជាមួយនឹងព្រះវរបិតាសួគ៌ » ។

ប្រធាន ថូម៉ាស អេស ម៉នសុន
**« Dare to Stand Alone »**
***Liahona*** **ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៦៧ ។**



**ដោយអែលឌើរ ហ្គែរី អ៊ី ស្ទីវិនសុន**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

# កំពុងដែលខំព្យាយាមឲ្យបានរបស់ផ្សេងៗ នោះចូរខំឲ្យបាន យោបល់ផង

*យោបល់ពិតប្រាកដនឹងកើតមានចំពោះអ្នក នៅពេលអ្នកទទួលស្គាល់ទំនាក់ទំនងនៃការសិក្សា និង ការអធិស្ឋាន នៅពេលអ្នករក្សាការតាំងចិត្តបម្រើ អំឡុងពេលរៀន និង ធ្វើការរកប្រាក់ចំណូល ព្រមទាំងនៅពេលអ្នកទុកចិត្ត ហើយពឹងផ្អែកលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។*

ខ្ញុំបានចំណាយពេលយ៉ាងច្រើន រៀននៅក្នុងបណ្ណាល័យកាលខ្ញុំជានិស្សិតមហាវិទ្យាល័យ ។ គ្រប់ពេលខ្ញុំបានចូលក្នុងបណ្ណាល័យ នោះមានសញ្ញាមួយដាក់សម្រាប់ស្វាគមន៍នៅលើច្រកចូលដែលសរសេរថា « កំពុងដែលខំឲ្យបានរបស់ផ្សេងៗ នោះចូរខំឲ្យបានយោបល់ផង » ( សុភាសិត ៤:៧ ) ។

យើងទាំងអស់គ្នាដឹងថា ការធ្វើច្រំដែលៗធ្វើឲ្យមានការចងចាំ ។ ហេតុដូច្នោះហើយ ខ្ញុំបានឆ្លាក់ខគម្ពីរដែលដកស្រង់ពីគម្ពីរសុភាសិតនេះក្នុងចិត្តរបស់ខ្ញុំជានិច្ច ដោយអានវាគ្រប់ពេលដែលខ្ញុំចូលទៅក្នុងបណ្ណាល័យ អំឡុងពេលបួនឆ្នាំនៃការសិក្សានៅមហាវិទ្យាល័យ ។

ខ្ញុំសូមផ្ដល់ការទូន្មានដូចគ្នានេះចំពោះអ្នករាល់គ្នា ៖ « កំពុងដែលខំឲ្យបានរបស់ផ្សេងៗនោះ ចូរខំឲ្យបានយោបល់ផង » ។ ខ្ញុំក៏សំណូមពរឲ្យ អ្នកគិតពីអត្ថន័យនៃខគម្ពីរនេះ និង របៀបដែលខគម្ពីរនេះផ្ដល់ប្រយោជន៍ដល់អ្នក ។ ខ្ញុំបានធ្វើដូច្នោះហើយ ។ ខ្ញុំបានពិចារណាអំពីខគម្ពីរនេះក្នុងចិត្តខ្ញុំម្ដងហើយម្ដងទៀត ហើយការបកស្រាយរបស់ខ្ញុំអំពីអត្ថន័យនៃខគម្ពីរនេះបានផ្លាស់ប្ដូរជាច្រើន ។ ប្រហែលជាអ្នកអាចទទួលបានប្រយោជន៍ពីការសង្កេតរបស់ខ្ញុំ ។

**ដួងចិត្តដែលមានយោបល់**

កាលជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងនៅប្រទេសជប៉ុន ដោយពុះពាររៀនភាសាដ៏លំបាក នោះខ្ញុំបានស្ដាប់ឮវាក្យសព្ទមួយចំនួនយ៉ាងលឿន និង ញាប់ ។ ពាក្យស្វាគមន៍ដូចជាពាក្យទាំងពីរនេះ *ohayo gozaimasu* ( អរុណសួស្ដី ) ឬ *konnichiwa* ( សាយ័ណ្ហសួស្ដី ) ។ ពាក្យមួយទៀតគឺ *wakarimasen*, ដែលមានន័យថា « ខ្ញុំមិនយល់ទេ » ។ ពេលនិយាយពាក្យនេះគេចាប់ដៃគ្នាទៅវិញទៅមក ហាក់បីដូចជាការឆ្លើយតបយ៉ាងពេញចិត្តមួយពីសំណាក់ប្រជាជនជប៉ុនទៅដល់អ្នកផ្សព្វផ្សាយសាសនាវ័យក្មេង នៅពេលពួកគេព្យាយាមសន្ទនាជាមួយប្រជាជននោះ ។

ដំបូង នៅពេលខ្ញុំបានគិតអំពីអត្ថន័យនៃឃ្លា « កំពុងដែលខំឲ្យបានរបស់ផ្សេងៗនោះ ចូរខំឲ្យបានយោបល់ផង » ខ្ញុំបានគិតអំពីពាក្យ *យោបល់* ទាក់ទងនឹងពាក្យការយល់ដឹងច្រើនជាង ៖ គឺជាអ្វីដែលខ្ញុំអាចស្ដាប់ឮដោយត្រចៀកខ្ញុំ និង យល់ក្នុងចិត្តខ្ញុំ ។ ខ្ញុំបានគិតដល់ពាក្យរបស់ភាសាជប៉ុនដែលនិយាយថា *wakarimasen* ។ តើខ្ញុំយល់ ឬ មិនយល់ ?

នៅពេលខ្ញុំបានសិក្សា និង សង្កេតមើលការប្រើពាក្យ *យោបល់* នៅក្នុងព្រះគម្ពីរ និង ប្រសាសន៍មកពីព្យាការីដែលនៅរស់ នោះខ្ញុំបានយល់ពីអត្ថន័យដ៏ជ្រាលជ្រៅរបស់វា ។ សូមពិចារណាអំពីប្រសាសន៍នេះមកពីអែលឌើរ រ៉ូប៊ឺត ឌី ហែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ កាលលោកជាប៊ីស្សពជាអធិបតីនៃសាសនាចក្រ ៖

« ដំបូងយើងចាប់ផ្ដើមដោយបញ្ញា ជាបញ្ញាដែលយើងមានមកតាំងពីកំណើត ។ នៅពេលយើងស្រាវជ្រាវរកចម្លើយ សិក្សា

គំនូរដោយ រ៉ូប៊ឺត ហាន់


Planet Nine?
silver
47
Ag
107.868
gold
79
Au
196.967

*យើងបន្ថែមចំណេះដឹង បទពិសោធន៍ ប្រាជ្ញា និងជំនួយ មកពីព្រះវិញ្ញាណបរិសុទ្ធតាមរយៈ ការអធិស្ឋានទៅលើបញ្ញា ។ បន្ទាប់មកយើងនឹងទទួលបានយោបល់ នៅក្នុងដួងចិត្តរបស់យើង ។*






**ទុកចិត្តលើព្រះអម្ចាស់ និង ព្រះបន្ទូលទ្រង់**

« ចូរធ្វើជាគំរូនៃសេចក្ដីជំនឿមានន័យថា យើងទុកចិត្តទៅលើព្រះអម្ចាស់ និងព្រះបន្ទូលរបស់ទ្រង់ ។ វាមានន័យថា យើងមានហើយយើងចិញ្ចឹមបីបាច់ជំនឿ ដែលនឹងដឹកនាំគំនិត និងសកម្មភាពរបស់យើង ។ សេចក្ដីជំនឿរបស់យើងទៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងព្រះវរបិតាសួគ៌របស់យើង នឹងមានឥទ្ធិពលលើគ្រប់អ្វីដែលយើងធ្វើ ។ នៅក្នុងស្ថានភាពប្របូកប្របល់នៃជំនាន់របស់យើង ការជំទាស់ក្នុងមនសិកា និងចលាចលនៃការរស់នៅប្រចាំថ្ងៃ នោះការកាន់ខ្ជាប់សេចក្ដីជំនឿ បានក្លាយទៅជាយុថ្កាក្នុងជីវិតយើង » ។

ប្រធាន ថូម៉ាស អេស ម៉នសុន « **Be an Example and a Light** » ***Liahona*** ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៨៧ ។

ហើយ អប់រំខ្លួនយើង មានន័យថា យើងបន្ថែមចំណេះដឹងទៅលើបញ្ញាដែលមានមកជាមួយយើងនោះ ។ យើងបន្ថែមបទពិសោធន៍ទៅលើចំណេះដឹងរបស់យើង ដែលនាំយើងទៅរកកម្រិតមួយនៃប្រាជ្ញា ។ ក្រៅពីប្រាជ្ញារបស់យើង យើងបន្ថែមជំនួយពីព្រះវិញ្ញាណបរិសុទ្ធតាមរយៈការអធិស្ឋានដោយសេចក្ដីជំនឿរបស់យើង ទូលសូមការណែនាំខាងវិញ្ញាណ និងកម្លាំង ។ លំដាប់នោះ យើងឈានដល់ *យោបល់* មួយនៅក្នុងចិត្តរបស់យើង—ដែលជំរុញយើងឲ្យ ‹ ធ្វើអ្វីដែលត្រឹមត្រូវ ចូរឲ្យផលមកតាមក្រោយ › ( *ទំនុកតម្កើង* ឆ្នាំ ១៩៨៥ លេខ ១៤៧ ។ អារម្មណ៍នៃដួងចិត្តដែលមាន *យោបល់* ផ្ដល់ស្មារតីនៃការធានាអះអាងដ៏ជឿជាក់ដល់យើង គឺមិនត្រឹមតែដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើអ្វីដែលត្រឹមត្រូវ ទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក្ដី ។ *យោបល់* នៅក្នុងដួងចិត្តរបស់យើងកើតឡើងពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងការសិក្សា និង ការអធិស្ឋាន » ។[1]

ឥឡូវនេះចូរពិចារណាម្ដងទៀត ៖ « កំពុងដែលខំឲ្យបានរបស់ផ្សេងៗនោះ ចូរខំឲ្យបានយោបល់ផង » ។ យោបល់នៅក្នុងបរិបទនេះកើតមកពីបញ្ញា ចំណេះដឹង បទពិសោធន៍ ប្រាជ្ញា និងការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ—ដែលទាំងអស់នេះដឹកនាំយើងឲ្យស្គាល់ ហើយ ធ្វើអ្វីដែលត្រឹមត្រូវ ។

ភាគច្រើនអ្នកទាំងអស់គ្នាកំពុងឆ្ពោះទៅ ឬ បានចូលដល់ដំណាក់កាលនៃការសម្រេចចិត្តដ៏សំខាន់ក្នុងជីវិតរបស់អ្នក ។ អ្នកប្រែកាន់តែមានភាពឯករាជ្យពីមួយឆ្នាំទៅមួយឆ្នាំ ហើយអ្នកកំពុងធ្វើដំណើរឆ្ពោះទៅ « ខំឲ្យបានរបស់ផ្សេងៗ » នៅក្នុងដំណាក់កាលនៃជីវិតរបស់អ្នក ។ តើអ្នកកំពុងតែខំឲ្យបានអ្វីខ្លះ ? អ្នកប្រហែលជាខំឲ្យបានស្វាមី ឬ ភរិយា មានគ្រួសារផ្ទាល់ខ្លួន និង ការងារជាដើម ។

ដើម្បីរៀបចំកិច្ចការសំខាន់ៗទាំងនេះ ដែលយើង « ខំឲ្យបាន » នោះយើងក៏ត្រូវទទួល « យោបល់ » ដូចខគម្ពីរបង្រៀនដែរ ។ យោបល់នេះកើតឡើងតាមរយៈការពឹងផ្អែកទាំងលើការសិក្សា និង ការអធិស្ឋាន ។ និយាយម៉្យាងទៀត យើងត្រូវទុកចិត្ត ហើយពឹងផ្អែកលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ អាលម៉ាពិពណ៌នាការណ៍នេះ នៅពេលលោកប្រដូចព្រះបន្ទូលទៅនឹងគ្រាប់ពូជមួយគ្រាប់ ។ ដូចលោកបានថ្លែងថា « វាចាប់ផ្ដើមបំភ្លឺ *យោបល់* របស់ខ្ញុំ មែនហើយវាចាប់ផ្ដើមមានរសជាតិឆ្ងាញ់ចំពោះខ្ញុំ » ( អាលម៉ា ៣២:២៨ ការគូសបញ្ជាក់បានបន្ថែម ) ។

ជារឿយៗប្រធាន ថូម៉ាស អេស ម៉នសុន ដកស្រង់ខគម្ពីរមកពីគម្ពីរសុភាសិតដែលជួយបន្ថែមឲ្យយល់ពីការណ៍នេះ ៖ « ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត និង កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ » ( សុភាសិត ៣:៥ ) ។[2]

នៅពេលយើងទុកចិត្ត ហើយពឹងផ្អែកលើព្រះអម្ចាស់ នោះទំហំនៃយោបល់កើតឡើងពីទ្រង់ចូលទៅក្នុងដួងចិត្តរបស់យើង ។

### « ព្រះហស្តរបស់ព្រះអម្ចាស់នៅលើពួកយើង »

ខ្ញុំសូមផ្ដល់ឧទាហរណ៍មួយអំពីស្ត្រីដ៏មានឥទ្ធិពលម្នាក់ ដែលបានដើរតួយ៉ាងសំខាន់នៅក្នុងការស្ដារឡើងវិញ ដែលបានទុកចិត្តលើព្រះអម្ចាស់ ហើយពុំបានពឹងផ្អែកលើយោបល់របស់ខ្លួនគាត់ឡើយ ។

មិនយូរប៉ុន្មានបន្ទាប់ពីសាសនាចក្របានបង្កើតឡើងនៅក្នុងទីក្រុង ប៉ាលម៉ៃរ៉ា រដ្ឋ នូវ យ៉ោក ម្ដាយរបស់យ៉ូសែប លូស៊ី ម៉ាក ស៊្មីធ បានបន្តនៅទីក្រុង វ៉ៃតធើរលូ រដ្ឋ នូវ យ៉ោក ជាមួយពួកបរិសុទ្ធមួយក្រុមធំ អំឡុងពេលដែលស្វាមីរបស់គាត់ យ៉ូសែប ស៊ីញ៉ររ និង កូនប្រុសមួយចំនួនរបស់ពួកគេ រួមមានទាំង យ៉ូសែប ជុញ៉ររ បាន ចាកចេញមុនគាត់ទៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ ការទទួលខុសត្រូវរបស់គាត់ គឺត្រូវនាំពួកបរិសុទ្ធក្រុមនេះទៅរដ្ឋ អូហៃអូ នៅពេលគាត់បានទទួលសារលិខិតពី កូនប្រុសរបស់គាត់ ដែលជាព្យាការី ។

សារលិខិតនោះបានមកដល់គាត់នៅដើមរដូវផ្ការីកឆ្នាំ ១៨៣១ ។ ដោយមាន ជំនួយមកពីបងប្អូនប្រុសមួយចំនួន លូស៊ី បានចាប់ផ្ដើមនាំក្រុមនោះទៅទីក្រុង បាសហ្វាឡូ រដ្ឋ នូវ យ៉ោក ដោយមានបំណងធ្វើដំណើរទៅរដ្ឋ អូហៃអូ ដោយជិះ ទូកកាត់ព្រែកអេរី ។ គាត់បាននិយាយដូចនេះ ៖ « នៅពេលបងប្អូនប្រុសបានគិត ថា រដូវផ្ការីកគឺជាពេលសមល្មម ដើម្បីធ្វើដំណើរតាមជើងទឹក យើងទាំងអស់គ្នា បានចាប់ផ្ដើមរៀបចំ ដើម្បីចេញដំណើរទៅទីក្រុង ខឺតឡង់ ។ យើងបានជួលទូក មួយ . . . ហើយ . . . ពួកយើងមានគ្នាចំនួនប៉ែតសិបនាក់ » ។

ក្រោយមក នៅពេលពួកគេបានជិះទូកទៅដល់ ព្រែកអេរី ហើយបានឆ្ពោះ ទៅទីក្រុង បាហ្វាឡូ នោះគាត់និយាយដូចនេះ ៖ « ខ្ញុំបានហៅបងប្អូនប្រុសស្រី ឲ្យជុំគ្នា ហើយរំឭកពួកគេថា យើងធ្វើដំណើរដោយសារតែសេចក្ដីត្រាស់បង្គាប់ របស់ព្រះអម្ចាស់ គឺដូចជាលោកឪពុកលីហៃ កាលលោកបានចាកចោលទីក្រុង យេរូសាឡិម ហើយដោយភក្ដីភាព នោះ យើងមានហេតុផលនឹងរំពឹងបានពរជ័យ ដូចគ្នានោះដែរមកពីព្រះ ។ ក្រោយមកខ្ញុំបានសូមពួកគេឲ្យមានចិត្តរឹងប៉ឹង *ហើយ តម្រង់ចិត្តរបស់ពួកគេឡើងចំពោះព្រះជាបន្តបន្ទាប់នៅក្នុងការអធិស្ឋាន* ប្រយោជន៍ ឲ្យយើងអាចចម្រើនឡើង » ។

នៅប្រហែលជាពាក់កណ្ដាលផ្លូវទៅទីក្រុង បាហ្វាឡូ ដែលចេញពីវ៉ៃតធើរលូ គឺ ការធ្វើដំណើរតាមព្រែកជីកនោះបានប្រែជាពុំអាចធ្វើដំណើរបាន ។ ស្ថានភាព សម្រាប់ពួកបរិសុទ្ធ ៨០ នាក់គ្មានភាពងាយស្រួលឡើយ ហើយការរអ៊ូរទាំបាន ចាប់ផ្ដើមឡើងភ្លាម ។ លូស៊ីបានបង្រួបបង្រួមសេចក្ដីជំនឿរបស់ពួកគេដោយពឹងផ្អែក លើព្រះអម្ចាស់ ។ គាត់ប្រាប់ពួកគេដូចនេះ ៖ « ទេ ទេ . . . បងប្អូនមិនស្រែកឃ្លាន ឡើយ ទោះជាបងប្អូនប្រុស ឬ នរណាផ្សេងទៀតក្ដី សូមមានចិត្តអត់ធ្មត់ ហើយ ឈប់រអ៊ូរទាំ ។ ខ្ញុំគ្មានចិត្តសង្ស័យឡើយ ហើយព្រះហស្ដរបស់ព្រះអម្ចាស់នៅលើ ពួកយើង » ។

នៅពេលពួកគេបានទៅដល់ទីក្រុង បាហ្វាឡូនៅថ្ងៃទី ៥បន្ទាប់ពីចេញពីវ៉ៃតធើរ លូ កំពង់ផែដែលត្រូវនាំទៅដល់ព្រែកអេរីនោះបានកក ។ ពួកគេបានធ្វើដំណើរលើ ទូកជាមួយមេបញ្ជាការ ប្លេក ជាបុរសម្នាក់ដែលបានស្គាល់ លូស៊ី ស៊្មីធ និង គ្រួសារ របស់គាត់ ។

ពីបីថ្ងៃក្រោយមក ទោះបីជាស្ថានភាពនៅលើទូកនោះមិនអំណោយផលដល់ ពួកគេទាំងអស់គ្នាឲ្យបន្តស្នាក់នៅ អំឡុងពេលរង់ចាំការប្រាប់ឲ្យចេញដំណើរក្ដី លូស៊ី បានរៀបរាប់ថា « ចាប់តាំងពីពេលនោះមកមេបញ្ជាការ ប្លេក បានស្នើសុំឲ្យអ្នកធ្វើ ដំណើរបន្តជិះនៅលើទូកនោះទៀត ដោយសារគាត់ចង់ត្រៀមខ្លួនជាស្រេច ដើម្បី ចាប់ផ្ដើមគ្រានៃការប្រុងប្រយ័ត្ន ក្នុងពេលដំណាលគ្នានោះដែរ គាត់បានបញ្ជូនមនុស្ស ម្នាក់ឲ្យទៅវាស់វែងមើលជម្រៅនៃទឹកកក ហើយនៅពេលបុរសនោះត្រឡប់មកវិញ បានរាយការណ៍ថា ទឹកកកនោះកករឹងកម្ពស់ ៦ ម៉ែត្រ ហើយថាតាមគំនិតរបស់គាត់ នោះយើងនឹងបន្តនៅលើកំពង់ផែនេះ យ៉ាងហោចណាស់ពីរសប្ដាហ៍ទៀត » ។

ព័ត៌មាននេះធ្វើឲ្យមនុស្សនៅក្នុងក្រុមមានការភ័យរន្ធត់ជាខ្លាំង ។ គ្រឿងបរិក្ខារ ប្រើប្រាស់បានអស់ ហើយស្ថានភាពមានការលំបាក ។ លូស៊ី ម៉ាក ស៊្មីធ បាន រៀបរាប់បន្ថែមទៀតអំពីការក្រើនរំឭកដល់ពួកបរិសុទ្ធដូច្នេះ ៖ « បងប្អូននិយាយថា បងប្អូនដាក់ទីទុកចិត្តរបស់ខ្លួនលើព្រះ ដូច្នេះតើបងប្អូនអាចមានអារម្មណ៍រអ៊ូរទាំ និង ស្ដីបន្ទោសដូចបងប្អូនបានធ្វើនេះយ៉ាងដូចម្ដេច ! បងប្អូនកាន់តែគ្មានហេតុផលជាង ពួកកូនចៅសាសន៍អ៊ីស្រាអែលទៅទៀត ដ្បិតបងប្អូនស្រីក្នុងសាសនាចក្ររបស់ខ្ញុំចង់ បានកៅអីដ៏សុខស្រួលរបស់ពួកគេ ហើយបងប្អូនប្រុសដែលខ្ញុំរំពឹងថាជាអ្នកដែល រឹងប៉ឹង និង មានកម្លាំងប្រកាសថាពួកគេជឿយ៉ាងប្រាកដថា ពួកគេនឹងឃ្លានដាច់ ពោះស្លាប់ ពីមុនពួកគេទៅដល់គោលដៅនៃដំណើររបស់ពួកគេ ។ ហើយហេតុអ្វីវា ប្រែជាបែបនេះ ? តើមាននរណាម្នាក់គ្មានអាហារគ្រប់គ្រាន់ឬ ? . . . តើសេចក្ដីជំនឿ របស់បងប្អូននៅឯណា ? តើការទុកចិត្តរបស់បងប្អូនទៅលើព្រះនៅត្រង់ណា ? តើ បងប្អូនមិនដឹងទេឬថា អ្វីៗទាំងអស់គឺទ្រង់ជាអង្គដែលធ្វើកិច្ចការទាំងនេះ ហើយថា ទ្រង់គ្រប់គ្រងលើកិច្ចការទាំងនេះដោយព្រះហស្ដរបស់ទ្រង់ផ្ទាល់ ? ហើយគិតថា ពួកបរិសុទ្ធទាំងអស់នៅទីនេះគួរតែតម្រង់ចិត្តរបស់ខ្លួនឡើង ដោយការអធិស្ឋានទៅ កាន់ព្រះថា នឹងមានផ្លូវអាចបើកបាននៅចំពោះមុខយើង នោះវាពិតជាងាយណាស់ សម្រាប់ទ្រង់ ដើម្បីបំបែកទឹកកកនោះ ប្រយោជន៍ឲ្យយើងអាចបន្តដំណើររបស់យើង ទៅមុខទៀត ! »

ឥឡូវនេះ សូមអង្កេតពីសេចក្ដីជំនឿដ៏អស្ចារ្យរបស់អ្នកម្ដាយស៊្មីធ—ថាតើ គាត់បានជ្រើសរើសទុកចិត្តលើព្រះអម្ចាស់ខ្លាំងប៉ុណ្ណា ហើយថាគាត់បានសូមឲ្យ ពួកបរិសុទ្ធដែលនៅជាមួយគាត់ កុំឲ្យពឹងផ្អែកលើយោបល់របស់ពួកគេខ្លាំងប៉ុណ្ណា ៖

« ‹ ឥឡូវនេះ ឱបងប្អូនប្រុសស្រីទាំងឡាយអើយ ប្រសិនបើបងប្អូនទាំងអស់គ្នា នឹងអំពាវនាវទៅដល់ស្ថានសួគ៌ អំពីបំណងប្រាថ្នារបស់បងប្អូន ដើម្បីឲ្យដុំទឹកកកនេះ អាចនឹងបែក ហើយដើម្បីឲ្យយើងអាចបន្តដំណើរទៅមុខបាន ដរាបណាព្រះអម្ចាស់ មានព្រះជន្មរស់ នោះវានឹងសម្រេចបានយ៉ាងដូច្នោះ › ។ រំពេចនោះ មានសំឡេង មួយបន្លឺឡើងដូចជាផ្គរលាន់ ។ មេបញ្ជាការបានស្រែកថា ‹ អ្នកគ្រប់គ្នា ចូរទៅកាន់ កន្លែងរៀងខ្លួន › ។ ដុំទឹកកកបានបែកប្រេះចេញ ដោយទុកច្រកតូចមួយសម្រាប់ ទូក ហើយនៅពេលទូកបានឆ្លងកាត់តាមផ្លូវតូចចង្អៀតនោះ ស្លាបចាក់របស់ម៉ាស៊ីន ទូកបានបាក់ដោយសារការប៉ះទង្គិចជាមួយទឹកកក ទាំងសំឡេងស្រែកបញ្ជាពី មេបញ្ជាការ រួមនឹងសំឡេងស្រែកយ៉ាងពេញទំហឹងរបស់អ្នកបើកក្ដោងទូក និង សំឡេងទឹកកក ព្រមទាំងសំឡេងស្រែករបស់អ្នកមើលពីលើដីគោក បានបង្ហាញ



បន្ទាប់ពីលើកទឹកចិត្តដល់បងប្អូនប្រុសស្រី ដែលស្ថិតក្នុងភាពតែលតោលឲ្យឈប់រអ៊ូរទាំ ហើយតម្រង់ចិត្តរបស់ពួកគេទៅស្ថានសួគ៌ លូស៊ី ម៉ាក ស្មីធ បាននិយាយថា « ដុំទឹកកកបានបែកប្រេះចេញ ដោយទុកច្រកតូចមួយសម្រាប់ទូក » ។ បន្ទាប់ពីទូករបស់ពួកបរិសុទ្ធបានឆ្លងទៅផុតភ្លាម ទឹកកកក៏បានកកជាប់ភ្ជាប់គ្នាវិញ ។

ពីឈុតឆាកដែលគួរឲ្យរន្ធត់ខ្លាំងបំផុត ។ យើងបានឆ្លងផុតតែបន្តិចតាមផ្លូវដែលទឹកកកនោះបានប្រេះចេញពីគ្នា ពីមុនពេលដែលទឹកកកភ្ជិតជាប់គ្នាវិញម្ដងទៀត ហើយបងប្អូនប្រុសនៅទីក្រុងខូលស្វិល ត្រូវបានទុកឲ្យនៅទីក្រុងបាហ្វាឡូ ដោយពុំមកតាមយើងឡើយ ។

« នៅពេលយើងចាកចេញពីកំពង់ផែ មានមនុស្សម្នាក់ដែលមើលពីលើដីគោក បានស្រែកឡើងថា ‹ នោះន៎ក្រុមអ្នកដំណើរ « មរមន » ! ទូកនោះបានលិចចុះទៅក្នុងទឹកជ្រៅជាងមុន២៣សង់ទីម៉ែត្រ ហើយឃើញថា ទូកនោះនឹងលិច—វាប្រាកដជាលិច › ។ ប្រាកដណាស់ ពួកគេប្រាកដក្នុងចិត្តថាដូច្នោះ ទើបពួកគេបានដើរសំដៅទៅរកការិយាល័យ [ សារព័ត៌មាន ] ហើយឲ្យគេចុះផ្សាយអំពីរឿងនោះថា ពួកយើងបានលិចទូក ដូច្នោះនៅពេលពួកយើងបានទៅដល់ហ្វែផត នោះយើងអានព័ត៌មានអំពីការស្លាប់របស់យើងផ្ទាល់ » ។[៣]

**« កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ »**

« កំពុងដែលខំឲ្យបានរបស់ផ្សេងៗ នោះចូរខំឲ្យបានយោបល់ផង » ឬ និយាយម្យ៉ាងទៀតថា « ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត និង កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ » ( សុភាសិត ៣:៥ ) ។

ខ្ញុំបានសង្កេតមើលផ្ទាល់អំពីទុក្ខព្រួយ និង ការបំផ្លិចបំផ្លាញផ្ទាល់ ធ្លាក់ទៅលើអស់អ្នកដែលផ្ដោតចិត្តលើ « ការខំឲ្យបាន » របស់ខាងលោកិយ ដោយមិនផ្ដោតលើ « យោបល់ » របស់ព្រះអម្ចាស់ ។ វាហាក់បីដូចជាអស់អ្នកដែលពឹងផ្អែកលើយោបល់របស់ខ្លួន ឬ ដាក់ទីទុកចិត្តរបស់ខ្លួនទៅលើដៃនៃមនុស្ស ទំនងជាបង្កើតវិសមាមាត្រនៃការផ្ដោតចិត្តទុកដាក់ ឬ ការលោភចង់បានវត្ថុនានា កិត្យានុភាព អំណាច និង មុខនាទី ។ ប៉ុន្តែការបន្ត « ខំឲ្យបាន » ដែលស្របជាមួយនឹងការណែនាំពីខគម្ពីរអំពី « យោបល់ » នឹងគ្រប់គ្រងចំណង់ចង់បានខាងលោកិយរបស់អ្នក ។ វានឹងធ្វើឲ្យមានបរិបទត្រឹមត្រូវសម្រាប់សកម្មភាពរបស់អ្នក ថាជាសមាជិកដែលមានប្រយោជន៍ចំពោះសង្គម និង នគររបស់ព្រះអម្ចាស់ ។

កាលជានិស្សិតវ័យក្មេង ដែលពោរពេញដោយមហិច្ឆិតា ខ្ញុំចាំពីការស្ដាប់តាមអ្នកប្រឹក្សាដែលគួរឲ្យគោរព និង មានជោគជ័យ ដែលផ្ដល់យោបល់ថា យើងចាត់ចែងមហិច្ឆិតាឲ្យបានត្រឹមត្រូវ តាមរយៈការធ្វើតាមរបៀបរបបមួយនៃ « ការរៀន, ការរកប្រាក់ចំណូល, ការបម្រើ » ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ ១៩១០–២០០៨ ) បានបង្រៀនគំរូមួយ ដែលនាំឲ្យមានទីទុកចិត្តលើព្រះអម្ចាស់ និង ពឹងផ្អែកលើទ្រង់ជាងពឹងលើខ្លួនយើង ។ លោកមានប្រសាសន៍ដូចនេះ ៖ « យើងម្នាក់ៗមានការទទួលខុសត្រូវបួនយ៉ាង ។ ទីមួយ យើងមានការទទួលខុសត្រូវចំពោះគ្រួសារយើង ។ ទីពីរ យើងមានការទទួលខុសត្រូវចំពោះនិយោជកយើង ។ ទីបី យើងមានការទទួលខុសត្រូវចំពោះកិច្ចការរបស់ព្រះអម្ចាស់ ។ ទីបួន យើងមានការទទួលខុសត្រូវចំពោះខ្លួនយើង » ។

យើងត្រូវចេះថ្លឹងថ្លែងវា ។ ប្រធាន ហ៊ិងគ្លី បានផ្ដល់យោបល់ថា យើងបំពេញការទទួលខុសត្រូវទាំងបួននេះ តាមរយៈការអធិស្ឋានជាគ្រួសារ រាត្រីជួបជុំក្រុមគ្រួសារ ការសិក្សាព្រះគម្ពីរជាគ្រួសារ ភាពទៀងត្រង់ និង ភាពស្មោះត្រង់ចំពោះនិយោជករបស់យើង បំពេញការទទួលខុសត្រូវរបស់យើងចំពោះសាសនាចក្រ ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ការសម្រាក ការកម្សាន្ត និង ការហាត់ប្រាណ ។[៤]

អ្នកប្រាជ្ញទស្សនវិជ្ជាអាមេរិក និង កវីនិពន្ធ រ៉ាលហ្វ វ៉ លដូ អែរមើសុន បាននិយាយដូចនេះ « គ្រានេះ ក៏ដូចជាគ្រាណាៗដែរ វាគឺជាគ្រាមួយដ៏ល្អបំផុត ប្រសិនបើយើងដឹងថា យើងត្រូវធ្វើអ្វីខ្លះនៅគ្រានោះ » ។[៥]

សំណាងល្អណាស់ ពួកបរិសុទ្ធថ្ងៃចុងក្រោយដឹងថាត្រូវធ្វើអ្វីជានិច្ច ។ ដោយការចេះដឹងរបស់អ្នកអំពីព្រះវរបិតាសួគ៌ដែលពោរពេញដោយក្ដីស្រឡាញ់ និង ផែនការនៃសុភមង្គលដ៏មហិមា នោះអ្នកដឹងអំពីអ្វីដែលត្រូវធ្វើ ។ ឥឡូវនេះ សូមប្រឹងប្រែងឲ្យកាន់តែខ្លាំងឡើង ឲ្យអស់ពីសមត្ថភាពរបស់អ្នក ។

នៅក្នុងសុន្ទរកថាសន្និសីទទូទៅ ប្រធាន ម៉នសុនបានដកស្រង់ពីគម្ពីរសុភាសិតដែលលោកធ្លាប់បានដកស្រង់ពីមុន ៖ « ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ » ។ « ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវអ្នកចុះ នោះទ្រង់នឹងតម្រង់អស់ទាំងផ្លូវច្រករបស់អ្នក » ។ បន្ទាប់មកលោកមានប្រសាសន៍ថា « នោះគឺជាអ្វីដែលខ្ញុំបានធ្វើក្នុងជីវិតរបស់ខ្ញុំ » ។[៦] ឱ នោះគឺជាជីវិតមួយដែលគួរតែយកធ្វើជាគំរូណាស់ ។

ខ្ញុំមានក្ដីសង្ឃឹមដ៏ធំធេងពីអ្នករាល់គ្នា ហើយព្រះវរបិតា និង ព្រះរាជបុត្រាក៏មានក្ដីសង្ឃឹមបែបនោះដែរ ។ ខ្ញុំសូមបញ្ចប់នៅត្រង់ចំណុចដែលខ្ញុំបានចាប់ផ្ដើម—ជាមួយនឹងការដាស់តឿន ដែលមាននៅក្នុងគម្ពីរសុភាសិត ៖ « កំពុងដែលខំឲ្យបានរបស់ផ្សេងៗនោះ ចូរខំឲ្យបានយោបល់ផង » ។

ចូរខំឲ្យបានយោបល់ពិតប្រាកដ ។ យោបល់ពិតប្រាកដនឹងកើតមានចំពោះអ្នកនៅពេលអ្នកទទួលស្គាល់ទំនាក់ទំនងនៃការសិក្សា និង ការអធិស្ឋាន នៅពេលអ្នករក្សាការតាំងចិត្តដើម្បីបម្រើអំឡុងពេលរៀន និង ធ្វើការរកប្រាក់ចំណូល ព្រមទាំងនៅពេលអ្នកមិនពឹងផ្អែកលើខ្លួនឯង ប៉ុន្តែពឹងផ្អែកលើព្រះអម្ចាស់វិញនោះ ។ ■

*ដកស្រង់ពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន មួយ « Lean Not unto Thine Own Understanding » បានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥ ។ ដើម្បីទទួលបានសុន្ទរកថាទាំងស្រុង ជាភាសាអង់គ្លេស សូមចូលទៅ speeches.byu.edu ។*

**កំណត់ចំណាំ**

១. រ៉ូបឺត ឌី ហែល « Making Righteous Choices at the Crossroads of Life » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ ទំព័រ ១០ ការគូសបញ្ជាក់បានបន្ថែម ។
២. ឧទាហរណ៍សូមមើល ថូម៉ាស អេស. ម៉នសុន « A Word at Closing » *Liahona* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ១១២ ។
៣. លូស៊ី ម៉ាក ស្ម៊ីធ *History of Joseph Smith by His Mother, Lucy Mack Smith* ( ឆ្នាំ ១៩៧៩ ) សូមមើលទំព័រ ១៩៥–៩៩, ២០២–២០៥ ការគូសបញ្ជាក់បានបន្ថែម ។
៤. សូមមើល ហ្គរដុន ប៊ី ហ៊ិងគ្លី « Rejoicing in the Privilege to Serve » *Worldwide Leadership Training Meeting* ថ្ងៃទី ២១ខែ មិថុនា ឆ្នាំ ២០០៣ ទំព័រ ២២, ២៣ ។
៥. រ៉ាលហ្វ វ៉លដូ អែរមើសុន នៅក្នុង « The American Scholar » សុន្ទរកថាដែលបានថ្លែងនៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៨៣៧ នៅមហាវិទ្យាល័យខេមប្រ៊ីដ ។
៦. ថូម៉ាស អេស. ម៉នសុន « A Word at Closing » ទំព័រ ១១២ ដកស្រង់ពី សុភាសិត ៣:៥–៦ ។

# ការគោរពស្ត្រី—ដោយមិនគិតពីអាយុឡើយ

ខ្ញុំត្រូវបានហៅឲ្យបង្រៀនថ្នាក់បព្វជិតភាពអើរ៉ុននៅក្នុងសាខារបស់ខ្ញុំ ហើយនៅថ្ងៃអាទិត្យមួយខ្ញុំត្រូវបង្រៀនប្រធានបទអំពីការគោរពដល់ស្ត្រីភេទ ។ អំឡុងពេលបង្រៀនយើងបានពិភាក្សាថា ការគោរពនោះគប្បីបង្ហាញចំពោះស្ត្រីគ្រប់រូប តាំងពីកូនក្មេងរហូតដល់មនុស្សពេញវ័យ ដូចដែលបានចែងនៅក្នុងសៀវភៅសិក្សាបព្វជិតភាពអើរ៉ុន ។

ហ្គាព្រីយ៉ែល ( ឈ្មោះត្រូវបានប្ដូរ ) ជាយុវជនម្នាក់នៅក្នុងថ្នាក់ បាននិយាយថា ចំពោះរូបគាត់ ស្ត្រីគឺជាមនុស្សស្រីដែលមានអាយុចាស់ល្មម ដែលស្មើនឹងម្ដាយរបស់គាត់ ហើយមនុស្សស្រីដែលក្មេងជាងនោះគប្បីគោរពដល់គាត់ដោយសារគាត់គឺជាបុរស ។ គ្មាននរណាម្នាក់នៅក្នុងថ្នាក់នោះយល់ស្របជាមួយគាត់ឡើយ ដែលធ្វើឲ្យគាត់នឹកស្មានមិនដល់ ។

យើងបានបន្តពិភាក្សាអំពីរបៀបនានា ដើម្បីបង្ហាញការគោរពដល់ស្ត្រីភេទ ហើយខ្ញុំបានប្រាប់ពួកគេថា កិច្ចការមួយដែលខ្ញុំធ្វើនោះគឺ ខ្ញុំសុខចិត្តឲ្យកៅអីរបស់ខ្ញុំនៅលើឡានដឹកអ្នកដំណើរសាធារណៈ នៅពេលមានស្ត្រីឡើងជិះលើឡាននោះ ទោះបីជាខ្ញុំត្រូវឈររហូតដល់ទៅ ៣០-៤០នាទី ពីមុនដល់គោលដៅដែលខ្ញុំត្រូវចុះក្ដី ។ ខ្ញុំបានប្រាប់ពួកគេថា បុរសៗគួរតែឈរ ហើយឲ្យស្ត្រីអង្គុយវិញ ។ ហ្គាព្រីយ៉ែលនៅតែគ្មានអារម្មណ៍ពេញចិត្តនឹងមេរៀននោះ ។

ពីរថ្ងៃក្រោយមក ខ្ញុំបានជិះឡានក្រុង ហើយអង្គុយនៅកៅអីមុខ ។ គ្មានកៅអីទំនេរឡើយ ពេលបុរសម្នាក់ និង កូនស្រីរបស់គាត់បានឡើងជិះឡាននោះ ហើយបានដើរទៅជួរក្រោយ ។ មិនយូរប៉ុន្មានក្រោយមក មានស្ត្រីចំណាស់ម្នាក់បានឡើងឡានក្រុងនោះ ហើយខ្ញុំបានក្រោកឈរឡើង ហើយឲ្យកៅអីទៅគាត់អង្គុយ ។

បុរសម្នាក់នៅអង្គុយពីក្រោយខ្ញុំបានគោះស្មាខ្ញុំដោយចង្អុលទៅខាងក្រោយនោះ ហើយបានប្រាប់ខ្ញុំថា មានយុវជនម្នាក់បានសូមឲ្យគាត់ឃ្លាំមើលពីសកម្មភាពរបស់ខ្ញុំ ។ ខ្ញុំបានដើរទៅខាងក្រោយ ដើម្បីមើលថាតើយុវជននោះជានរណា ។ អ្នកនៅក្បែរនោះបានញញឹម ដោយសារយុវជននោះបានឲ្យកៅអីរបស់ខ្លួនទៅបុរសដែលមានកូនស្រីអាយុបួនឆ្នាំនោះអង្គុយ ដែលពួកគេទើបតែបានឡើងជិះឡានមុននោះបន្តិច ។ យុវជននោះគឺជា ហ្គាព្រីយ៉ែល ដែលជាយុវជននៅក្នុងថ្នាក់បព្វជិតភាពរបស់ខ្ញុំ ដែលមិនសូវពេញចិត្តនឹងប្រធានបទអំពីការគោរពដល់ស្ត្រីភេទនោះ ។

គាត់បាននិយាយមកកាន់ខ្ញុំថា « ខ្ញុំបានអង្គុយមើល ថាតើអ្នកនឹងក្រោកឈរឲ្យស្ត្រីដែលឡើងជិះឡាននោះអង្គុយដែរឬទេ ។ ខ្ញុំរំជួលចិត្តយ៉ាងខ្លាំងនៅពេលខ្ញុំឃើញថាអ្នកបានធ្វើដូច្នោះមែន ហើយខ្ញុំចាំពីមេរៀនរបស់យើងកាលពីថ្ងៃអាទិត្យ ហើយខ្ញុំបានក្រោកឈរឡើងទុកកៅអីឲ្យក្មេងស្រីតូច និង ឪពុករបស់នាងអង្គុយវិញ » ។

ខ្ញុំរីករាយយ៉ាងខ្លាំង ដោយខ្ញុំបានឃើញថាយុវជនរបស់យើង រស់នៅតាមអ្វីដែលពួកគេបានរៀននៅក្នុងសាសនាចក្រ ។ គាត់ធ្លាប់គិតថា ការគោរពនោះគឺសម្រាប់តែស្ត្រីវ័យចំណាស់ប៉ុណ្ណោះ ប៉ុន្តែបន្ទាប់ពីយើងបានរៀនមេរៀននៅថ្ងៃអាទិត្យនោះមក គាត់បានជ្រើសយកការបង្ហាញការគោរពដល់ក្មេងស្រីអាយុបួនឆ្នាំ ។

ខ្ញុំក៏រីករាយផងដែរ ដែលខ្ញុំបានជ្រើស ដើម្បីរស់នៅតាមអ្វីដែលខ្ញុំបង្រៀន ដោយជួយគាត់ឲ្យរៀនបង្ហាញការគោរពដល់ស្ត្រីគ្រប់វ័យទាំងអស់ ។ ខ្ញុំបានឆ្ងល់ថា តើគាត់មានអារម្មណ៍បែបណា ប្រសិនបើខ្ញុំពុំបានក្រោកឈរឡើង ហើយឲ្យកៅអីទៅស្ត្រីនៅក្នុងឡាននោះអង្គុយ ។ ខគម្ពីរមួយបានផុសឡើងក្នុងចិត្តខ្ញុំ ៖ « បើអ្នករាល់គ្នាដឹងសេចក្ដីទាំងនេះ ហើយប្រព្រឹត្តតាមនោះមានពរហើយ » (យ៉ូហាន ១៣:១៧) ។ ■

អូវី អូសារ៉េទីន ហ្វ្រាយឌេ ទីក្រុង អ៊ីឌូ ប្រទេស នីហ្សេរីយ៉ា

ស្ត្រីចំណាស់ម្នាក់បានឡើងឡានក្រុងនោះ ហើយខ្ញុំបានក្រោកឈរឡើង ហើយឲ្យកៅអីទៅគាត់អង្គុយ ។



រចនារូបភាពដោយ យ៉ូស្វេ ដេននីស



ខ្ញុំទទួលអារម្មណ៍យ៉ាងជាក់លាក់ពីព្រះវិញ្ញាណដឹកនាំខ្ញុំ ឲ្យមើលពីខ្សែស្រឡាយមួយទៅខ្សែស្រឡាយមួយទៀត រហូតដល់ត្រឹមខាងជីតារបស់ខ្ញុំ ។

# ឥឡូវនេះ តើមានឈ្មោះណាខ្លះដែលត្រៀមរួចជាស្រេច ?

ថ្ងៃអាទិត្យមួយបន្ទាប់ពីសម័យប្រជុំចុងក្រោយនៃសន្និសីទទូទៅ ខ្ញុំមានអារម្មណ៍បំផុសគំនិតយ៉ាងខ្លាំង ឲ្យចុះឈ្មោះចូលគណនីកម្មវិធីស្រាវជ្រាវពង្សប្រវត្តិរបស់ខ្ញុំ ហើយធ្វើកិច្ចការពង្សប្រវត្តិមួយចំនួន ។ ខ្ញុំមានចិត្តស្ទាក់ស្ទើរ ក្នុងការធ្វើកិច្ចការពង្សប្រវត្តិរបស់ខ្ញុំ ដោយសារខ្ញុំព្យាយាមធ្វើវាច្រើនដងកាលពីពេលមុន តែមិនសូវមានជោគជ័យសោះ ។ គ្រួសាររបស់ខ្ញុំបានធ្វើកិច្ចការពង្សប្រវត្តិនេះជាច្រើនមកហើយ ហើយខ្ញុំបានគិតក្នុងចិត្តថា គ្មានកិច្ចការអ្វីទៀតដែលនៅសល់សម្រាប់ខ្ញុំធ្វើឡើយ ។

ខ្ញុំបានអង្គុយចុះ ហើយដកដង្ហើមធំដែលបង្ហាញពីភាពស្មុគស្មាញ នៅពេលខ្ញុំបានមើលឃើញកន្លែងមួយដែលគ្មានព័ត៌មាន ដែលខ្ញុំបានព្យាយាមធ្វើអស់ជាច្រើនឆ្នាំមក ដោយសង្ឃឹមថាថ្ងៃនេះគឺជាវេលាចុងក្រោយដែលខ្ញុំអាចរកបានព័ត៌មានមួយចំនួន ។ ខ្ញុំបានចាប់ផ្ដើមស្រាវជ្រាវដូចធម្មតា តាមរយៈកំណត់ត្រាជំរឿន អាពាហ៍ពិពាហ៍ សំបុត្រកំណើត ហើយមួយម៉ោងក្រោយមកខ្ញុំពុំបានរកឃើញព័ត៌មានអ្វីឡើយ ។ បន្ទាប់មកព្រះវិញ្ញាណដែលបានខ្សឹបប្រាប់ខ្ញុំពេញមួយចុងសប្ដាហ៍អំឡុងពេលសម័យប្រជុំសន្និសីទនោះ បានបំផុសគំនិតខ្ញុំឲ្យអធិស្ឋាន ហើយរកមើលថា ឥឡូវនេះ តើមានឈ្មោះណាខ្លះដែលត្រៀមរួចជាស្រេច ដើម្បីឲ្យកិច្ចការរបស់ពួកគេចប់សព្វគ្រប់នោះ ។

នៅពេលខ្ញុំអធិស្ឋានចប់ ខ្ញុំបានត្រឡប់ទៅមើលឈ្មោះរបស់ខ្ញុំវិញ ហើយបន្តមើលតាមខ្សែស្រឡាយនោះ ។ ខ្ញុំទទួលអារម្មណ៍យ៉ាងជាក់លាក់ពីព្រះវិញ្ញាណដឹកនាំខ្ញុំ ឲ្យមើលពីខ្សែស្រឡាយមួយទៅខ្សែស្រឡាយមួយទៀត រហូតដល់ត្រឹមខាងជីតារបស់ខ្ញុំ ។ មួយម៉ោងជាងក្រោយមក ខ្ញុំបានទទួលអារម្មណ៍នៃព្រះវិញ្ញាណមានពេញក្នុងបន្ទប់នោះ ហើយខ្ញុំបានរកឃើញឈ្មោះប្រាំមួយ ដើម្បីយកទៅព្រះវិហារបរិសុទ្ធ ។ នៅពេលខ្ញុំបញ្ចប់ការស្នើសុំឈ្មោះទាំងនោះសម្រាប់ព្រះវិហារបរិសុទ្ធ ខ្ញុំបានក្រឡេកមើលកំណត់ត្រាមួយចំនួនដែលខ្ញុំបានទទួលព័ត៌មាននោះ ។ ខ្ញុំបានយំ ហើយចិត្តខ្ញុំពេញដោយអំណរ—ព័ត៌មាននោះបានមកពីអ្នកធ្វើលិបិក្រម ដែលបានស្ម័គ្រចិត្តចំណាយពេលវេលារបស់ពួកគេ ដើម្បីបញ្ចូលកំណត់ត្រានានាសម្រាប់ជីដូនជីតារបស់ខ្ញុំ ។ ខ្ញុំបានធ្វើលិបិក្រមឈ្មោះសម្រាប់មនុស្សដទៃទៀត អស់មួយម៉ោងទៀត ដោយអំណរគុណ ។

នាថ្ងៃនោះទីបន្ទាល់របស់ខ្ញុំបានកើនឡើង ដោយអំណរគុណចំពោះហេតុផលពីរយ៉ាង ។ ទីមួយ អំឡុងពេលសន្និសីទទូទៅ ព្រះវិញ្ញាណបានដឹកនាំខ្ញុំឲ្យធ្វើកិច្ចការពង្សប្រវត្តិ ហើយស្គាល់ឈ្មោះដែលត្រូវស្វែងរក ។ ទីពីរ អរគុណដល់សមាជិកសាសនាចក្រនៅទូទាំងពិភពលោក ដែលធ្វើលិបិក្រមឈ្មោះ ប្រយោជន៍ឲ្យមនុស្សដូចជាខ្ញុំ អាចរកឈ្មោះដូនតារបស់យើងបានយ៉ាងច្បាស់លាស់ និង លឿន ហើយពន្លឿនកិច្ចការរបស់ពួកគាត់ ។ ខ្ញុំមានទីបន្ទាល់យ៉ាងជាក់ច្បាស់ និង ដ៏មានឥទ្ធិពលអំពីកិច្ចការរបស់ព្រះ ដែលបានផ្សព្វផ្សាយចេញទៅទូទាំងពិភពលោក ។ ■

ឡេសា វីមភី រដ្ឋ ណេវ៉ាដា ស.រ.អា.

# ការអធិស្ឋានរបស់គ្រូក្រុមកាយរិទ្ធិ

ខ្ញុំគឺជាគ្រូក្រុមកាយរិទ្ធិដែលបាននាំយុវជន ២០ នាក់ និង អ្នកដឹកនាំពីរនាក់ក្នុងសកម្មភាពធ្វើដំណើរមួយនៅក្នុងរដ្ឋ យូថាហ៍ ភាគខាងត្បូង ស.រ.អា. ។

នៅពេលរថយន្តរបស់យើងមកដល់ផ្លូវមួយដែលនឹងនាំយើងទៅកន្លែងបោះជំរំ នោះខ្ញុំបានឈប់ ហើយខ្ញុំបានមើលវាលខ្សាច់ដែលនៅពីមុខខ្ញុំនោះ ។ យើងបានធ្វើដំណើរបែបនេះច្រើនដងហើយ ប៉ុន្តែដោយសារហេតុផលមួយចំនួន វាធ្វើឲ្យខ្ញុំមើលមិនឃើញផ្លូវដែលខ្ញុំបានស្គាល់ឡើយ ។ ខ្ញុំបានមើលឆ្វេងស្ដាំដោយប្រុងប្រយ័ត្ន ដោយរកមើលផ្លូវដែលខ្ញុំស្គាល់ ។

មិនថាផ្លូវណាដែលខ្ញុំបានបត់ទៅឡើយ ផ្លូវទាំងនោះគឺជាផ្លូវទាល់ ។

មេឃចាប់ផ្ដើមងងឹតហើយ ។ ទីបំផុតខ្ញុំបានឈប់ឡាន ហើយប្រាប់ឲ្យពួកគេទាំងអស់គ្នាបន្តជិះនៅលើឡាន ។ ខ្ញុំបានចាប់យកពិល ហើយប្រាប់ពួកគេថា ខ្ញុំនឹងដើរទៅរកផ្លូវ ហើយផ្ដល់សញ្ញាឲ្យពួកគេ នៅពេលខ្ញុំរកឃើញផ្លូវ ។

អ្វីដែលខ្ញុំបានធ្វើនោះគឺលុតជង្គង់ចុះ ហើយបានទូលអង្វរដល់ព្រះវរបិតាសួគ៌ ឲ្យជួយពួកយើងចេញផុតពីស្ថានភាពដ៏តានតឹងនោះ ។ ខ្ញុំបានថ្វាយដួងចិត្តខ្ញុំដល់ទ្រង់ ដោយទូលទ្រង់ពីការរៀបចំ សេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះក្មេងៗទាំងនោះ អំណរគុណរបស់ខ្ញុំចំពោះឪពុករបស់ពួកគេដែលបានមកជាមួយពួកយើង និង សេចក្ដីជំនឿដ៏ស៊ប់របស់ខ្ញុំថា ទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់ខ្ញុំឲ្យបានលឿន ។ ខ្ញុំបានបញ្ចប់ការអធិស្ឋាន ហើយក្រោកឈរឡើង ។ ខ្ញុំបានសង្ឃឹមថា ពេលខ្ញុំក្រោកឡើង បញ្ចាំងពិលទៅក្នុងទីងងឹតនោះ នឹងឃើញពន្លឺចាំងមកភ្លាមលើផ្លូវត្រូវ ។

ប៉ុន្តែគ្មានអ្វីបានកើតឡើងឡើយ ។

ខ្ញុំបានសម្លឹងមើលទៅមុខដោយស្ងប់ស្ងាត់ ដោយបញ្ចាំងពន្លឺពិលទៅយ៉ាងឆ្ងាយតាមដែលអាចធ្វើបាន ។

នៅតែគ្មានឃើញអ្វីសោះ ។

ខ្ញុំមិនអាចជឿឡើយ ។ ខ្ញុំ *បានដឹង* ថា នៅពេលដែលខ្ញុំក្រោកឡើង នោះខ្ញុំនឹងឃើញផ្លូវ ។ ខ្ញុំ *បានដឹង* ថាព្រះអម្ចាស់នឹងមិនបំបាក់ទឹកចិត្តខ្ញុំឡើយ ជាពិសេសដោយសារមានមនុស្សជាច្រើនដែលពឹងផ្អែកលើរូបខ្ញុំ ។

ឥឡូវនេះខ្ញុំត្រូវត្រឡប់ទៅវិញ ហើយនិយាយជាមួយឪពុកពីររូបដែលមានអារម្មណ៍ស្មុគស្មាញ ហើយឡានរបស់ពួកគាត់មានសុទ្ធតែយុវជនដែលឆុងឆាំង អន្ទះសា ដែលពួកគេគ្រប់គ្នាបានសួរថា « តើពួកយើងមកដល់ហើយឬនៅ ? »

រចនារូបភាពដោយ អេលែន ហ្គានស៍



អ្វីដែលខ្ញុំបានធ្វើនោះគឺលុតជង្គង់ចុះ ហើយបានទូលអង្វរដល់ព្រះវរបិតាសួគ៌ ឲ្យជួយពួកយើងចេញផុតពីស្ថានភាពដ៏តានតឹងនោះ ។

ខ្ញុំបានសុំទោស ហើយអះអាងប្រាប់ពួកគេថា ខ្ញុំបានធ្វើដំណើរបែបនេះ ២០ ដងហើយក្នុងជីវិតរបស់ខ្ញុំ ហើយថាខ្ញុំបានស្គាល់ផ្លូវគឺនៅទីនោះឯង ។ តែខ្ញុំមិនឃើញផ្លូវនោះឡើយ ។

ទីបំផុតយើងបានសម្រេចចិត្តបើកឡានចូលទៅទីក្រុង ហើយជួលសណ្ឋាគារពីរបន្ទប់ ។ យើងនឹងចាប់ផ្ដើមដោយស្រស់ស្រាយម្ដងទៀតនៅព្រឹកថ្ងៃសៅរ៍ ។

ដោយសារយើងពុំអាចបង្កាត់ភ្លើងជាភ្លើងក្នុងជំរំ ដើម្បីចម្អិនអាហារពេលល្ងាចដែលយើងយកមកជាមួយបាន នោះយើងបានទៅកន្លែងលក់នំភីស្សាក្នុងមូលដ្ឋាន ដែលយើងបានឃើញវានៅចុងភូមិនោះ ។

ភីស្សានោះមានរសជាតិឆ្ងាញ់ ហើយក្មេងទាំងនោះមានចិត្តរីករាយ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍ខ្មាសអៀន ដែលយើងត្រូវបង់ប្រាក់សម្រាប់ថ្លៃសណ្ឋាគារ និង អាហារពេលល្ងាចនោះ ។

នៅពេលយើងបរិភោគអាហារខ្ញុំឆ្ងល់ថា ហេតុអ្វីព្រះវរបិតាសួគ៌មិនឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ ស្រាប់តែខ្ញុំបានឮសំឡេងខ្ទរយ៉ាងខ្លាំង ។

ខ្ញុំបានក្រោកឡើង ហើយបើកទ្វារហាងភីស្សានោះមើល ហើយបានឃើញភ្លៀងធ្លាក់យ៉ាងខ្លាំងដែលខ្ញុំមិនធ្លាប់ឃើញពីមុនឡើយ ។ មានរន្ទះបាញ់ឆ្វេចឆ្វាចទៅភាគទិសពាយព្យ—គឺនៅចំកន្លែងដែលខ្ញុំបានអធិស្ឋានទូលសូមចម្លើយ កាលពីមួយម៉ោងមុននោះ ។ នៅគ្រានោះ ព្រះវិញ្ញាណបានសន្ធប់លើរូបខ្ញុំ ហើយខ្ញុំដឹងថាព្រះអម្ចាស់ *បាន* ឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ !

នៅព្រឹកបន្ទាប់ ផ្ទៃមេឃស្រឡះល្អ ហើយនៅពេលយើងធ្វើដំណើរត្រឡប់ទៅតាមផ្លូវដើរហុយដែលយើងបានវង្វេងនោះ ខ្ញុំបានបើកឡានទៅឈប់ត្រង់កន្លែងដែលខ្ញុំបានឈប់កាលយប់មុននោះ ។ ឥឡូវនេះខ្ញុំដឹងហើយថា ជួនកាលចម្លើយនៃការអធិស្ឋានគឺឆ្លើយថាទេ ប៉ុន្តែការអធិស្ឋានទាំងនោះ *តែងតែ* បានឆ្លើយតបជានិច្ច ។ ■

គូនី រ៉ូហ្វីសុន រដ្ឋ យូថាហ៍ ស.រ.អា.

រូបភាពដោយ ជែង អៀ




ខ្ញុំបានសងពេលវេលាវិញជាច្រើន—ជាពេលដែលខ្ញុំចំណាយមើលថៃ និង លេងជាមួយកូនៗរបស់ខ្ញុំ ពេលអាន និង ពេលសិក្សាសៀវភៅផ្សេងៗ ។

# ការកែសម្រួលកិច្ចការអាទិភាពរបស់ខ្ញុំ

មិនយូរប៉ុន្មានបន្ទាប់ពីខ្ញុំបានចាប់ផ្ដើមសរសេរកំណត់ហេតុបណ្ដាញគ្រួសាររបស់យើង នោះខ្ញុំបានឃើញថា ខ្ញុំចំណាយរាល់ពេលទំនេររបស់ខ្ញុំផ្ញើបច្ចុប្បន្នភាពវា ហើយគិតពីរបៀបដែលអាចធ្វើឲ្យកាន់តែច្នៃប្រឌិត និង គួរឲ្យចាប់អារម្មណ៍ ។ ខ្ញុំបានចំណាយពេលយ៉ាងច្រើន អានកំណត់ហេតុបណ្ដាញរបស់មនុស្សផ្សេងទៀតផងដែរ ។

នៅអំឡុងពេលពីរបីសប្ដាហ៍នោះ ខ្ញុំបានដាក់អាទិភាពលើការសរសេរកំណត់ហេតុបណ្ដាញ ដោយយកទាំងពេលសិក្សាព្រះគម្ពីរប្រចាំថ្ងៃរបស់ខ្ញុំ និង ការអានសៀវភៅផ្សេងៗទៀតប្រើដើម្បីសរសេរវាផងដែរ ។ ខ្ញុំពុំអាចផ្ចង់អារម្មណ៍ឡើយអំឡុងពេលសិក្សា ខ្ញុំពុំចង់អានសៀវភៅច្រើនឡើយ ហើយខ្ញុំមានអារម្មណ៍ថាខ្វះព្រះវិញ្ញាណនៅក្នុងជីវិត ។ ខ្ញុំមានការអត់ធ្មត់តិចតួចជាមួយកូនៗរបស់ខ្ញុំ ហើយពេលវេលាដែលខ្ញុំគប្បីនៅជាមួយពួកគេ ខ្ញុំបែរជាចំណាយពេលនោះប្រើកុំព្យូទ័រទៅវិញ ។

ការសរសេរកំណត់ហេតុបណ្ដាញមិនមែនជារឿងមិនសមរម្យនោះទេ ការពិតវាជាវិធីមួយដ៏អស្ចារ្យដើម្បីបន្តទាក់ទងជាមួយគ្រួសារ និង មិត្តភក្តិ ។ ប៉ុន្តែដោយសារខ្ញុំមានអារម្មណ៍ថា ការផ្ដោតចិត្តទុកដាក់របស់ខ្ញុំបានបង្វែរចេញឆ្ងាយពីកិច្ចការ ដែលផ្ដល់គ្រឹះខាងវិញ្ញាណដ៏រឹងមាំសម្រាប់ខ្ញុំ នោះខ្ញុំបានដឹងថាខ្ញុំត្រូវតែផ្លាស់ប្ដូរ ។

ខ្ញុំបានចាប់ផ្ដើម តាំងចិត្តខ្លួនឯងថា ខ្ញុំមិនចាំបាច់ត្រូវសរសេរកំណត់ហេតុបណ្ដាញរាល់ថ្ងៃឡើយ ហើយខ្ញុំក៏មិនចាំបាច់ពិនិត្យមើលកំណត់ហេតុបណ្ដាញរបស់មនុស្សដទៃទៀតរៀងរាល់ថ្ងៃផងដែរ ។ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំនៅតែអាចចំណាយពេលទំនេរប្រើកុំព្យូទ័រ បន្ទាប់ពីខ្ញុំបានបញ្ចប់ការសិក្សាព្រះគម្ពីរ និង ការអានសៀវភៅផ្សេងៗទៀតប៉ុណ្ណោះ ។ នៅពេលខ្ញុំបានធ្វើកិច្ចការសំខាន់ៗចប់សព្វគ្រប់ហើយ ជាទូទៅខ្ញុំគ្មានពេលច្រើនដើម្បីសរសេរកំណត់ហេតុបណ្ដាញឡើយ ប៉ុន្តែការណ៍នោះវាមិនជាថ្វីទេ ។ ខ្ញុំបានសងពេលវេលាវិញជាច្រើន—ជាពេលដែលខ្ញុំចំណាយមើលថៃ និង លេងជាមួយកូនៗរបស់ខ្ញុំ ពេលអាន និង ពេលសិក្សាសៀវភៅផ្សេងៗ ។

បន្ទាប់ពីពីរបីថ្ងៃក្រោយការកែសម្រួលកិច្ចការអាទិភាពមក ខ្ញុំបានកត់សម្គាល់ឃើញថា ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណកាន់តែច្រើនឡើងនៅក្នុងជីវិតខ្ញុំម្ដងទៀត ។

ខ្ញុំដឹងថា នៅពេលខ្ញុំដាក់អាទិភាពធ្វើកិច្ចការដែលនឹងផ្ដល់ប្រយោជន៍ខាងវិញ្ញាណដល់ខ្ញុំរៀងរាល់ថ្ងៃ នោះខ្ញុំនឹងទទួលអារម្មណ៍ពីព្រះវិញ្ញាណកាន់តែច្រើនឡើងរាល់ថ្ងៃ ។ ខ្ញុំដឹងថា ការចំណាយពេលសិក្សាព្រះគម្ពីរ អានទស្សនាវដ្ដីសាសនាចក្រ និង សៀវភៅល្អផ្សេងទៀត ព្រមទាំងការគិតពីកិច្ចការនានាដែលសំខាន់អស់កល្បជានិច្ច អាចជួយយើងឲ្យក្លាយជាភរិយា ម្ដាយ និង សមាជិកសាសនាចក្ររបស់ព្រះអម្ចាស់កាន់តែប្រសើរឡើង ។ ■

ជីននី ដេវីស រដ្ឋ តិចសាស ស.រ.អា.



ដោយអែលឌើរ ស៊ី ស្កត ហ្គ្រូ
ក្នុងពួកចិតសិបនាក់

# គោលការណ៍របស់ពួកព្យាការីអំពី *ភាពស្មោះត្រង់*

**តើមានការសម្រេចចិត្ត និង ការតាំងចិត្តអ្វីខ្លះ ដែលអ្នកត្រូវធ្វើក្នុងពេលនេះ និង នាពេលអនាគតដើម្បីជួយអ្នកឲ្យបន្តស្មោះត្រង់នោះ ?**

ជាង ២០ ឆ្នាំកន្លងមកហើយ ខ្ញុំបានបញ្ចប់ការបម្រើរបស់ខ្ញុំជាប្រធានបេសកកម្មនៅក្នុងទ្វីបអាមេរិកខាងត្បូង ។ ភរិយារបស់ខ្ញុំ រ៉ុនដា និង រូបខ្ញុំបានឃើញពីជោគជ័យដ៏អស្ចារ្យ ព្រមទាំងសោកនាដកម្មដ៏ឈឺចាប់នៅក្នុងជីវិតរបស់ពួកអ្នកផ្សព្វផ្សាយសាសនារបស់យើង អំឡុងពេល ២០ ឆ្នាំកន្លងមកនេះ ។

ភាគច្រើនអ្នកផ្សព្វផ្សាយសាសនារបស់យើងមានចិត្តរីករាយ ដែលបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ចិញ្ចឹមកូនចៅដោយសុចរិត ហើយបញ្ជូនពួកគេទៅបម្រើបេសកកម្ម ព្រមទាំងបម្រើដោយស្មោះត្រង់នៅក្នុងការហៅបម្រើក្នុងអង្គការជំនួយ និង បព្វជិតភាពរបស់សាសនាចក្រ ។ ប៉ុន្តែមានអ្នកផ្សព្វផ្សាយសាសនាមួយចំនួន ប្រែជាមិនស្មូរសកម្ម មួយចំនួនបានរៀបការ ហើយលែងលះគ្នា និង មួយចំនួនទៀតត្រូវបានកាត់កាលចេញពីសាសនាចក្រ ។

តើអ្វីខ្លះដែលធ្វើឲ្យមានការផ្លាស់ប្តូរ នៅក្នុងជីវិតរបស់អតីតអ្នកផ្សព្វផ្សាយសាសនារបស់យើង ? តើពួកគេអាចធ្វើអ្វីខ្លះផ្សេងពីនោះដើម្បីចៀសវាងពីសោកនាដ្ឋកម្មផ្ទាល់ខ្លួននោះ ? ចុះចំពោះរូបប្អូនៗវិញនោះ ? តើប្អូនៗនឹងនៅទីណាក្នុងអំឡុង ២០ ឆ្នាំទៀត ? តើមានការសម្រេចចិត្ត និង ការតាំងចិត្តអ្វីខ្លះ ដែលប្អូនៗត្រូវធ្វើក្នុងពេលនេះ និង នាពេលអនាគតដើម្បីជួយប្អូនៗឲ្យបន្តស្មោះត្រង់នោះ ?

ខ្ញុំសូមផ្តល់យោបល់នូវគោលការណ៍ ១០ យ៉ាងដែលនឹងជួយប្អូនៗ ។

## ១ បន្តចិញ្ចឹមបីបាច់ទីបន្ទាល់របស់ប្អូនៗ

បទពិសោធន៍ដ៏ពេញដោយព្រះវិញ្ញាណនៅក្នុងបេសកកម្ម បង្កើតជាគ្រឹះនៃសេចក្តីជំនឿ ដែលអាចប្រទានពរប្អូនៗពេញមួយជីវិតនេះ ។ គ្រឹះនៃសេចក្តីជំនឿនោះអាចចុះថយដោយសារតែការព្រងើយកន្តើយ ឬ អំពើបាបប៉ុណ្ណោះ ។

ថ្មីៗនេះ ខ្ញុំបានសម្ភាសអ្នកត្រឡប់ពីបេសកកម្មម្នាក់ ដែលមិនស្មូរសកម្ម ដែលបានគិតថាគាត់បាត់បង់សេចក្តីជំនឿហើយ ។ ខ្ញុំបានសួរគាត់ថាគាត់បានអាន ហើយ សិក្សាព្រះគម្ពីរមរមន ដូចគាត់បានធ្វើកាលនៅជាអ្នកផ្សព្វផ្សាយសាសនាឬទេ ។ គាត់បាននិយាយថា គាត់ពុំបានធ្វើទេឡើយ ដោយសារគាត់បានបាត់បង់សេចក្តីជំនឿលើយ៉ូសែប ស្ម៊ីធ ហើយ ។

ខ្ញុំបានទទួលការបំផុសគំនិតឲ្យសួរសំណួរនេះដល់គាត់ ៖ « តើប្អូនជាប់ពាក់ព័ន្ធនឹងការណ៍អាសគ្រាមឬ ? » គាត់បានឆ្លើយថា បាទមែន ។ ខ្ញុំបានប្រាប់គាត់ថា វាមិនគួរឲ្យភ្ញាក់ផ្អើលទេ ដែលគាត់បាត់បង់សេចក្តីជំនឿនោះ ។

ខ្ញុំបានពន្យល់ថា ទីបន្ទាល់គ្មានអ្វីក្រៅពីព្រះវិញ្ញាណបរិសុទ្ធ ដែលថ្លែងជាសាក្សីដល់ព្រលឹងយើងអំពីភាពពោរពេញនៃសេចក្តីពិតរបស់ដំណឹងល្អ និង សាសនាចក្រដែលបានស្តារឡើងវិញឡើយ ។ នៅពេលយើងពុំបានអធិស្ឋាន ហើយ សិក្សាព្រះគម្ពីរ លំដាប់នោះឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតយើងនឹងចុះខ្សោយបន្ថយការទប់ទល់របស់យើងចំពោះការល្បួង ។ នៅពេលយើងមានអំពើបាប ហើយមិនស្អាតស្អំ នោះយើងបាត់បង់ភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ។ ការបន្តគ្មានសាក្សីពីព្រះវិញ្ញាណ នោះយើងអាចងាយចាប់ផ្តើមគិតថា យើងគ្មានទីបន្ទាល់ ហើយប្រហែលជាពុំធ្លាប់មានទីបន្ទាល់ផងដែរ ។

ទីបន្ទាល់របស់យើងត្រូវការបន្តចិញ្ចឹមបីបាច់ ។ ការចិញ្ចឹមបីបាច់នោះកើតឡើងពីការអធិស្ឋានផ្ទាល់ខ្លួន ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ—ជាពិសេសព្រះគម្ពីរមរមន—និងការបម្រើនៅក្នុងសាសនាចក្រពេញមួយជីវិតរបស់យើង ។





## ២ ធ្វើតាមពាក្យទូន្មានរបស់ពួកព្យាការី និង ពួកសាវកនៅរស់

ខ្ញុំនឹងរំឭកអំពីពាក្យទូន្មានរបស់ពួកព្យាការី ដែលអាចជួយប្អូនៗឲ្យមានអាពាហ៍ពិពាហ៍ដ៏រីករាយ គ្រួសារស្មោះត្រង់ និង ជីវិតដ៏មានជោគជ័យ ។ ខ្ញុំសំដៅលើ « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។ ខ្ញុំនឹងចែកចាយផ្នែកសំខាន់ៗមួយចំនួនពីការប្រកាសនោះ ដែលបានចេញផ្សាយដោយគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់កាលពីឆ្នាំ ១៩៩៥ ។ យើងគាំទ្រពួកបងប្អូនប្រុសទាំងនេះថា ជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ ពួកលោកមានប្រសាសន៍មកកាន់កូនចៅរបស់ទ្រង់នៅលើផែនដី ជំនួសព្រះអង្គ ។

នៅថ្ងៃដែលសាសនាចក្របានស្ថាបនាឡើង ព្រះបានមានបន្ទូលទាក់ទងនឹងព្យាការីរបស់ទ្រង់ថា « ដ្បិតពាក្យសម្ដីរបស់លោកនោះហើយ អ្នកនឹងបានទទួលហាក់ដូចជាបានមកពីព្រះឱស្ឋរបស់យើងផ្ទាល់ ដោយសេចក្ដីអត់ធន់ និង សេចក្ដីជំនឿគ្រប់យ៉ាង » ។ បន្ទាប់មកព្រះអម្ចាស់ សន្យានូវពរជ័យខាងសាច់ឈាម និង ពរជ័យដ៏នៅអស់កល្បជានិច្ច នៅពេលយើងធ្វើតាមពាក្យទូន្មានរបស់ព្យាការី ៖ « ដ្បិតដោយសារការធ្វើការទាំងនេះហើយ ទ្វារស្ថាននរកនឹងពុំដែលឈ្នះអ្នកឡើយ មែនហើយ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងកម្ចាត់អំណាចនៃសេចក្ដីងងឹតចេញពីអ្នកទៅ ហើយនឹងបណ្ដាលឲ្យផ្ទៃមេឃញាប់ញ័រដើម្បីសេចក្ដីល្អដល់អ្នក និងសិរីល្អដល់ព្រះនាម របស់ទ្រង់ » ( គ. និង ស. ២១:៥–៦ ) ។

វាជាពរជ័យដ៏អស្ចារ្យអ្វីម្ល៉េះនៅក្នុងគ្រាដ៏លំបាកទាំងនេះ ។



## ៣ ត្រូវផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ហើយរក្សាសេចក្ដីសញ្ញារបស់ប្អូនៗ

ព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ « ប្រកាសថា អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រី គឺត្រូវបានតែងតាំងឡើង ដោយព្រះ ហើយថា គ្រួសារ ជាផ្នែកដ៏សំខាន់មួយនៅក្នុងផែនការរបស់ព្រះដ៏បង្កបង្កើតសម្រាប់គោលដៅដ៏នៅអស់កល្បជានិច្ចនៃកូនចៅរបស់ទ្រង់ » ។ ពួកលោកបន្ថែមដូចនេះ ៖ « ផែនការនៃសុភមង្គលដ៏ទេវភាពនេះ ផ្ដល់លទ្ធភាពដល់ទំនាក់ទំនងក្រុមគ្រួសារឲ្យចេះតែបន្តមានរហូតហួសពីសេចក្ដីស្លាប់ ។ ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាពិសិដ្ឋនានា ដែលមាននៅក្នុងព្រះវិហារបរិសុទ្ធ អាចធ្វើឱ្យបុគ្គលម្នាក់ៗ ត្រឡប់ទៅកាន់ វត្តមាននៃព្រះវិញ ហើយដើម្បីឲ្យក្រុមគ្រួសារ អាចត្រូវបានរួបរួមគ្នាដ៏អស់កល្បជានិច្ច » ។[1]

ការសម្រេចចិត្តសំខាន់ដែលអ្នកត្រូវធ្វើនៅក្នុងជីវិតនេះ « គឺដើម្បីរៀបអាពាហ៍ពិពាហ៍ជាមួយ មនុស្សត្រឹមត្រូវ នៅកន្លែងត្រឹមត្រូវ ដោយសិទ្ធិអំណាចត្រឹមត្រូវ »[2] ហើយបន្ទាប់មករក្សាសេចក្ដីសញ្ញាព្រះវិហារបរិសុទ្ធរបស់ប្អូនៗ ។ បើគ្មានការផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធទេ នោះក៏គ្មានភាពតម្កើងឡើងដែរ ។

ដើម្បីមានគុណសម្បត្តិទទួលបានភាពតម្កើងឡើង គូស្វាមីភរិយាត្រូវចូលក្នុង « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ហើយសេចក្ដីសញ្ញានោះ [ ត្រូវ ] បានភ្ជាប់ដល់ពួកគេ ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា ដោយអ្នកណាដែលត្រូវបានលាប »—គឺជាព្យាការី ។ ប្រសិនបើយើងរក្សាសេចក្ដីសញ្ញាព្រះវិហារបរិសុទ្ធរបស់យើង នោះយើងនឹង « គ្រងបល្ល័ង្កទាំងឡាយ នគរទាំងឡាយ ក្សត្របុរីទាំងឡាយ និង អំណាចទាំងឡាយ អំណាចគ្រប់គ្រងទាំងឡាយ គ្រប់ទីកម្ពស់ និងជម្រៅទាំងអស់ . . . និងសិរីល្អរបស់ពួកគេ ក្នុងអ្វីៗគ្រប់ទាំងអស់ . . . គឺជាសិរីល្អដែលនឹងបានពូជដ៏បរិបូរ និងបន្តបន្ទាប់ជារៀងដរាបតទៅ » ( គ. និង ស. ១៣២:១៩ សូមមើលខទី ៧ ផងដែរ ) ។

ការផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធមាននូវការសន្យានៃពរជ័យអស់កល្បជានិច្ចនៅក្នុងជីវិតបន្ទាប់ ហើយក៏បង្កើតឲ្យមានភាពស្រដៀងគ្នានេះដែរនៃអាពាហ៍ពិពាហ៍ដ៏រីករាយក្នុងជីវិតនេះ ។ ក្នុងនាមជាបុត្រា ឬ បុត្រីរបស់ព្រះដែលបានការតែងតាំងប្អូនៗបានចុះសេចក្ដីសញ្ញាមកកាន់ផែនដីនៅជំនាន់នេះ ដើម្បីស្ថាបនានគរព្រះ ។ ការស្ថាបនានគរព្រះនោះរួមមានអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួនរបស់អ្នកក្នុងព្រះវិហារបរិសុទ្ធ ។

ខាងលើ ៖ រូបថតនៅខាងក្រៅព្រះវិហារបរិសុទ្ធ ម៉ានីល ហ្វីលីពីន

## ៤ ជាដៃគូជាមួយព្រះក្នុងការនាំកូនវិញ្ញាណរបស់ទ្រង់មកកាន់ផែនដី

ការប្រកាសអំពីក្រុមគ្រួសារចែងដូចនេះ ៖ « ព្រះបញ្ញត្តិទីមួយដែលព្រះបានប្រទានដល់លោកអ័ដាម និងនាងអេវ៉ា ទាក់ទងទៅនឹងសមត្ថភាពរបស់ពួកគេសម្រាប់ភាពជាឪពុកម្ដាយ ក្នុងនាមជាស្វាមី និងភរិយា ។ យើងសូមប្រកាសថា ព្រះបញ្ញត្តិរបស់ព្រះសម្រាប់កូនចៅរបស់ទ្រង់ ដើម្បីបង្កើតកូនចៅឲ្យចម្រើនជាច្រើនឡើងឲ្យមានពាសពេញលើផែនដីនោះ នៅតែឲ្យប្រតិបត្តិនៅឡើយ » ។

ក្រុមគ្រួសារសព្វថ្ងៃនេះមានកូនតិចជាងក្រុមគ្រួសារជំនាន់មុន— សូម្បីតែក្រុមគ្រួសារ អិល.ឌី.អេស. ។ យើងអាចរកឃើញហេតុផលនានាជានិច្ច ដើម្បីបង្ហាញហេតុផលសមរម្យក្នុងការពន្យារពេល ឬ កំណត់ចំនួនកូនដែលយើងមាន ។ ឧទាហរណ៍ « យើងត្រូវបញ្ចប់ការសិក្សាជាមុនសិន » ឬ « យើងត្រូវមានការងារល្អប្រសើរសិន ដើម្បីយើងអាចមានប្រាក់គ្រប់គ្រាន់ » ឬ « ហេតុអ្វីត្រូវដកយកភាពសប្បាយរីករាយចេញពីអាពាហ៍ពិពាហ៍ ដោយត្រូវមានកូនទៅវិញ ? »

ប្អូនៗបានទទួលពរជាមួយនឹងទីបន្ទាល់ អំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ។ ប្អូនៗមានពរជ័យនៃភាពអស់កល្បជានិច្ចផ្ដល់ឲ្យកូនចៅរបស់ប្អូនៗ ។ ចូរកុំឲ្យមានគំនិតថា ប្អូនៗត្រូវតែផ្គត់ផ្គង់អ្វីៗគ្រប់យ៉ាងខាងសាច់ឈាមដល់ពួកគេនោះឡើយ ។ អំណោយដ៏អស្ចារ្យបំផុតដែលប្អូនៗមាន ដើម្បីផ្ដល់ឲ្យកូនចៅរបស់ប្អូនៗនោះគឺ មធ្យោបាយឆ្ពោះទៅកាន់អ្វីៗខាងវិញ្ញាណនៅក្នុងនគរព្រះ ។

នៅពេលប្អូនៗប្រឹក្សាគ្នាជាមួយស្វាមី ឬ ភរិយាប្អូនៗដោយការអធិស្ឋានអំពីការមានកូន ចូរចាំថា ប្អូនៗគឺជាយុវវ័យដែលមានសិទ្ធិពីកំណើតដ៏ថ្លៃថ្នូរ ។ សូមកុំទុកព្រះឲ្យនៅក្រៅនៃការពិភាក្សារបស់ប្អូនៗឡើយ ។ សូមចែកចាយសិទ្ធិដើម្បីចាប់កំណើតនេះជាមួយកូនវិញ្ញាណប្រុសស្រីជាច្រើនថា ព្រះបានរៀបចំបញ្ជូនពួកគេមកផ្ទះរបស់ប្អូនៗ ។ លើសពីនោះទៀត ពួកគេគឺជាកូនចៅខាងវិញ្ញាណរបស់ទ្រង់ជាយូរយារណាស់មកហើយ ពីមុនពួកគេនឹងក្លាយជាកូនចៅរបស់ប្អូនៗ ។

ដោយមានជំនឿលើព្រះ និង ប្រសាសន៍របស់ពួកព្យាការីទ្រង់ ចូរឆ្ពោះទៅមុខ ដោយកុំដោះសារ ឬ ស្ទាក់ស្ទើរឡើយ ហើយបង្កើតក្រុមគ្រួសារអស់កល្បផ្ទាល់ខ្លួន ។

## ៥ ចូរកុំបណ្ដោយខ្លួនទៅក្នុងការណ៍អាសគ្រាម ឬ ឥរិយាបថអសីលធម៌ផ្សេងទៀត

ការប្រកាសនោះបន្តថា « កូនចៅមានសិទ្ធិនឹងទទួលកំណើតមកក្នុងចំណងនៃអាពាហ៍ពិពាហ៍ហើយ និងត្រូវបានចិញ្ចឹមបីបាច់ដោយឪពុកម្ដាយដែលគោរពប្រតិបត្តិតាមសច្ចានៃអាពាហ៍ពិពាហ៍ដោយស្មោះត្រង់ទាំងស្រុង » ។

ដោយស្មោះត្រង់ទាំងស្រុងមានន័យថាស្មោះត្រង់ខាងរូបកាយ ព្រមទាំងចិត្តគំនិតចំពោះស្វាមីភរិយារបស់ប្អូនៗ ។ ការណ៍អាសគ្រាម និង ទំនាក់ទំនងតាមអ៊ិនធើរណែតគឺជាឧទាហរណ៍មួយនៃភាពមិនស្មោះត្រង់ខាងចិត្តគំនិត ។ នៅពេលស្វាមី ឬ ភរិយាពាក់ព័ន្ធនឹងការណ៍អាសគ្រាម ពួកគាត់បំពានការទុកចិត្តដ៏សំខាន់បំផុតនៃភាពស្និទ្ធស្នាលពីធម្មជាតិ ។ ស្វាមី ឬ ភរិយាដែលពុំបានដឹងរឿងនោះមានអារម្មណ៍ថាត្រូវបានគេក្បត់ ។ ទំនុកចិត្ត និង ការជឿជាក់នៅក្នុងអាពាហ៍ពិពាហ៍កាន់តែចុះខ្សោយទៅៗ ។ ការពាក់ព័ន្ធនឹងការណ៍អាសគ្រាមគឺជាគ្រាប់ពូជនៃការប្រព្រឹត្តសេចក្ដីកំផិត ។

ខ្ញុំសូមចែកចាយអារម្មណ៍មួយចំនួនរបស់បុរសម្នាក់ ដែលបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ប៉ុន្តែបានបាត់បង់គ្រួសាររបស់គាត់ទៅវិញ ដោយសារតែការណ៍អាសគ្រាម និង ទំនាក់ទំនងតាមអ៊ិនធើរណែតជាមួយស្ត្រីផ្សេង ។ ដោយក្ដីកើតទុក្ខគាត់បានសរសេរដូចនេះ ៖ « ខ្ញុំពុំបានស្ដាប់តាមពាក្យដែលបានផ្ដល់ដល់ខ្ញុំ នៅក្នុងពររបស់លោកអយ្យកោឡើយ ដែលបានចែងថា សាតាំងនឹងគ្មានអំណាចអ្វីនៅក្នុងជីវិតរបស់ខ្ញុំឡើយ លុះត្រាណាខ្ញុំអនុញ្ញាតឲ្យវាធ្វើបែបនោះ ។ ខ្ញុំបានឲ្យអំណាចនោះទៅវាច្រើនណាស់ ហើយបន្តិចម្ដងៗ វាបានយកអំណាចនោះ ហើយវាបានប្រើអំណាចនោះដើម្បីបំផ្លាញជីវិតរបស់ខ្ញុំជាមួយភរិយា និង កូនៗរបស់ខ្ញុំ ។ ខ្ញុំស្រឡាញ់ពួកគេដោយអស់ពីដួងចិត្តរបស់ខ្ញុំ ហើយខ្ញុំនៅតែស្រឡាញ់ និង ស្រឡាញ់ពួកគេជារៀងដរាបតទៅ ប៉ុន្តែសេចក្ដីស្រឡាញ់នោះពុំមានគ្រប់គ្រាន់ដើម្បីអាចយកឈ្នះលើអំណាចដែលខ្ញុំ បានស្ម័គ្រចិត្តឲ្យទៅសាតាំងនៅក្នុងជីវិតរបស់ខ្ញុំដើម្បីបំផ្លាញសេចក្ដីស្រឡាញ់នោះឡើយ ។ ការបង្រៀនរបស់សាសនាចក្របានផ្ដល់របៀបមួយដល់ [ យើង ] ដើម្បីត្រឡប់ទៅជាគ្រួសារដែលបានផ្សារភ្ជាប់សម្រាប់ពេលនេះ និងអស់កល្បជានិច្ច ទៅនឹងព្រះវរបិតាសួគ៌របស់យើង ដែលខ្ញុំនឹងមានប្រសិនបើខ្ញុំបានស្ដាប់ និង គោរពតាម ប៉ុន្តែទីបំផុតខ្ញុំពុំបានធ្វើតាមការបង្រៀននោះឡើយ » ។

នោះជាសោកនាដកម្មដ៏ខ្លោចផ្សាអ្វីម្ល៉េះ ។





## ៦ បង្រៀន និង រស់នៅតាមដំណឹងល្អនៅក្នុងគេហដ្ឋានរបស់អ្នក

ការប្រកាសបង្រៀនយើងអំពី កិច្ចការនានាដែល យើងត្រូវតែធ្វើដើម្បីមានភាពរីករាយនៅក្នុងគេហដ្ឋានរបស់យើង ។ « សុភមង្គលនៅក្នុងជីវិតគ្រួសារអាចកើតមានឡើងបាន នៅពេលយើងធ្វើតាមការបង្រៀនរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ អាពាហ៍ពិពាហ៍ និងគ្រួសារដែលមានជោគជ័យ នោះគឺត្រូវស្ថាបនា និងថែរក្សានៅលើគោលការណ៍នៃសេចក្ដីជំនឿ ការអធិស្ឋាន ការប្រែចិត្ត ការអភ័យទោស ការគោរពគ្នា សេចក្ដីស្រឡាញ់ សេចក្ដីមេត្តាករុណា ការងារ និងកម្មវិធីកម្សាន្តល្អៗនានា » ។

កាលភរិយាខ្ញុំ និង ខ្ញុំទើបតែរៀបការថ្មីថ្មោង យើងបានព្យាយាមបង្កើតទម្លាប់ដ៏រឹងប៉ឹងមួយក្នុងការអានព្រះគម្ពីរជាមួយគ្នារៀងរាល់ថ្ងៃជាគ្រួសារម្ដងហើយម្ដងទៀត ។ នៅពេលកូនច្បងរបស់យើងមានអាយុប្រហែលប្រាំពីរឆ្នាំ យើងទម្លាប់អានព្រះគម្ពីររាល់ថ្ងៃ ។ យើងអាននៅពេលព្រឹកមុនធ្វើកិច្ចការផ្សេងៗ យើងបានបន្តស្មោះត្រង់តាំងពីគ្រានោះរៀងរហូតមក ។ នៅពេលទម្លាប់នោះបានបង្កើតឡើងជាមួយកូនផ្សេងៗទៀត កូនដែលតូចៗមានចិត្តចង់ចូលរួម នៅពេលពួកគេមានអាយុធំល្មម ។ ជារឿយៗយើងត្រូវអានគម្ពីរមុនម៉ោង ៦ ព្រឹក ដោយសារមានថ្នាក់សិក្ខាសាលានៅពេលព្រឹកព្រហាម ។

គូស្វាមីភរិយាដែលទើបរៀបការមានកាតព្វកិច្ចចាប់ផ្ដើមទម្លាប់គ្រួសារសុចរិតផ្ទាល់ខ្លួនរបស់ពួកគេ—ដោយសិក្សាព្រះគម្ពីរជាគ្រួសារប្រចាំថ្ងៃ អធិស្ឋានជាគ្រួសារ និង រៀបចំកូនៗរបស់ពួកគេឲ្យទៅបម្រើបេសកកម្ម និង រៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ។

## ៧ គោរពដល់តួនាទីជាឪពុក និងម្ដាយនៅក្នុងការចិញ្ចឹមកូន

ការប្រកាសនោះក៏ចែកចាយពីការទូន្មានសំខាន់ៗអំពីការចិញ្ចឹមកូន ៖« ម្ដាយមានភារកិច្ចសំខាន់ ដើម្បីថែរក្សាបីបាច់កូនចៅរបស់ខ្លួន ។ នៅក្នុងការទទួលខុសត្រូវដ៏ពិសិដ្ឋទាំងនេះឪពុក និង ម្ដាយមានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមកជា *ដៃគូស្មើគ្នា* » ។

ជួនកាលឪពុក ឬ ម្ដាយម្នាក់អាចមានអារម្មណ៍ថា គាត់មានគុណសម្បត្តិប្រសើរជាង ក្នុងការចិញ្ចឹម និង ដាក់វិន័យកូនៗ ។ ព្យាការីនៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះបានបង្រៀនម្ដងហើយម្ដងទៀតថា ស្វាមី និងភរិយាបង្កើតបានជាដៃគូមួយនៅក្នុងអាពាហ៍ពិពាហ៍ ថារាល់ការសម្រេចចិត្តទាំងអស់ទាក់ទងនឹងគ្រួសារ គប្បីត្រូវពិភាក្សារួមគ្នា និង ចុះសម្រុងគ្នា ។

ដៃគូស្មើគ្នាគឺត្រូវធ្វើជាគូស្មើគ្នា ។ ប្រឹក្សា និង អធិស្ឋានជាមួយគ្នា ។ ត្រូវឲ្យព្រះវិញ្ញាណដឹកនាំ ដើម្បីដឹងពីវិធីដ៏មានប្រសិទ្ធិភាពបំផុតក្នុងការចិញ្ចឹមកូនៗរបស់ប្អូនៗជាមួយគ្នា ។ ជោគវាសនាអស់កល្បជានិច្ចរបស់ពួកគេ គឺកើតមកពីការសម្រេចចិត្តរបស់ប្អូនៗ ។

## ៨ ប្រើសិទ្ធិជ្រើសរើសខាងសីលធម៌របស់ប្អូនៗដើម្បីជ្រើសធ្វើតាមព្រះអង្គសង្គ្រោះ

ការសម្រេចចិត្តទាក់ទងនឹងឃ្លាថា តើប្អូនៗនឹងនៅទីណានៅក្នុងរយៈពេល ២០ ឆ្នាំ ឬ ២០ ទសវត្សរ៍ទៀតគឺអាស្រ័យលើប្អូនៗទាំងស្រុង ។ ប្អូនៗមានសេរីភាពជ្រើសរើស ប៉ុន្តែលទ្ធផលអស់កល្បជានិច្ចនឹងកើតឡើងពីជម្រើសរបស់ប្អូនៗនោះ ។ ដោយសារតែដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ មនុស្សទាំងអស់ « ត្រូវបានប្រោសលោះឲ្យរួចពីការធ្លាក់ [ ទើប ] ពួកគេមានឥស្សរភាពរហូតតទៅ ដោយដឹងខុស និងត្រូវដើម្បី *ធ្វើសកម្មភាពដោយខ្លួនឯង* ហើយពុំមែនទទួលសកម្មភាពទេ លើកលែងតែដោយការធ្វើទោសតាមក្រឹត្យវិន័យនៅក្នុងថ្ងៃដ៏មហិមា ហើយចុងក្រោយបង្អស់ ស្របតាមព្រះបញ្ញត្តិទាំងឡាយ ដែលព្រះទ្រង់បានប្រទានមក ។

ហេតុដូច្នោះហើយ មនុស្សលោកមាន . . . សេរីភាពរើសយកឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈព្រះជាអ្នកសង្រ្គោះដ៏ធំរបស់មនុស្សលោកទាំងអស់ ឬក៏រើសយកការជាប់ឃុំឃាំង និង ការស្លាប់ស្របតាមការជាប់ឃុំឃាំង និង អំណាចរបស់អារក្ស ដ្បិតវាព្យាយាមធ្វើឲ្យមនុស្សលោកទាំងអស់មានទុក្ខវេទនាដូចវាដែរ » ( នីហ្វៃទី ២ ២:២៦–២៧ ការគូសបញ្ជាក់បានបន្ថែម ) ។

សាតាំងស្អប់ប្អូនៗ ដោយសារប្អូនៗជាមនុស្សបែបណា និង ដោយសារអ្វីដែលប្អូនៗតំណាងឲ្យ ។ វាចង់ឲ្យប្អូនៗរងទុក្ខវេទនាដូចជាវាដែរ ។ ព្រះយេស៊ូវគ្រីស្ទមានព្រះទ័យស្រឡាញ់ប្អូនៗ ។ ទ្រង់បានបង់ថ្លៃសម្រាប់អំពើបាបរបស់ប្អូនៗ ។ ទ្រង់បានលះបង់ព្រះជន្មទ្រង់ដើម្បីប្អូនៗ ។ ទ្រង់អញ្ជើញប្អូនៗឲ្យធ្វើតាមទ្រង់ ហើយប្រែចិត្តប្រសិនបើចាំបាច់ ។ នៅពេលប្អូនៗជ្រើសធ្វើតាមព្រះអង្គសង្គ្រោះ នោះប្អូនៗនឹងមាន « អំណរក្នុងជីវិតនេះ និង ជីវិតអស់កល្បជានិច្ចក្នុងជីវិតបន្ទាប់ » ។[៣]

## ៩ បង្កើនសេចក្ដីជំនឿដើម្បីកាន់ខ្ជាប់ ដរាបដល់ចុងបំផុត

សេចក្ដីជំនឿកើតឡើងនៅពេលប្អូនៗបានប្រែចិត្តជឿលើព្រះអម្ចាស់ ។ ព្យាការីនីហ្វៃបានបង្រៀនដូចនេះ ៖ « ហេតុដូច្នេះហើយ អ្នករាល់គ្នាត្រូវតែឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ និង មនុស្សគ្រប់រូប ។ ហេតុដូច្នោះហើយ បើសិនជាអ្នករាល់គ្នាខិតខំជឿនទៅមុខ ដោយទទួលនូវព្រះបន្ទូលនៃព្រះគ្រីស្ទ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត មើលចុះនោះព្រះវរបិតាទ្រង់មានព្រះបន្ទូលថា ៖ អ្នករាល់គ្នានឹងមានជីវិតដ៏នៅអស់កល្បជានិច្ច » ( នីហ្វៃទី២ ៣១:២០ ) ។

ថ្មីៗនេះប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍នៅក្នុងសន្និសីទទូទៅថា « អនាគតរបស់អ្នកភ្លឺត្រចះត្រចង់ដូចជាសេចក្ដីជំនឿរបស់អ្នកដែរ » ។[៤] នោះរួមមានទាំងជំនឿដើម្បីកាន់ខ្ជាប់ និង យកឈ្នះលើឧបសគ្គទាំងអស់ ទាំងការអាក់អន់ចិត្ត ការក្បត់ និង ការខកចិត្ត ។ សេចក្ដីជំនឿរបស់ប្អូនៗដើម្បីកាន់ខ្ជាប់នឹងកំណត់ពីគោលដៅរបស់ប្អូនៗ ដែលជាជោគវាសនាដ៏អស់កល្បជានិច្ច ។

## ១០ ដាក់ឆន្ទៈរបស់ប្អូនៗឲ្យចុះចូលនឹង ព្រះហឫទ័យរបស់ព្រះ

ខ្ញុំអធិស្ឋានសូមឲ្យព្រះបានបណ្ដាលដួងចិត្តរបស់ប្អូនៗជាមួយនឹងបំណងប្រាថ្នា ដើម្បីធ្វើកិច្ចការនានាឲ្យបានកាន់តែប្រសើរឡើង និង ក្លាយខ្លួនកាន់តែប្រសើរជាងមុន ព្រមទាំងធ្វើតាមដំបូន្មានរបស់ព្យាការីដែលនៅរស់របស់យើង ។ ខ្ញុំសង្ឃឹមថា ប្អូនៗមានបំណងប្រាថ្នា ដើម្បីពង្រឹងការតាំងចិត្តរបស់ខ្លួន ឲ្យប្រែក្លាយជាអ្វីទាំងអស់ដែលព្រះបានតែងតាំងប្អូនៗតាំងពីមុនផែនដីមកម្ល៉េះ ។

« ប្អូនប្រុស [ និង ប្អូនស្រី ]តើយើងនឹងមិនទៅមុខ ដោយសារចលនាដ៏ធំមហិមានេះទេឬ ? ចូរទៅមុខ ហើយកុំថយក្រោយឡើយ ។ ចូរមានចិត្តក្លាហានចុះ . . . ហើយចូរទៅ ចូរទៅរកជ័យជម្នះ ! . . . ចូរយើងថ្វាយដង្វាយដល់ព្រះអម្ចាស់ ដោយសេចក្ដីសុចរិត ក្នុងនាមជាសាសនាចក្រ ហើយជាប្រជារាស្ត្រ ហើយជាពួកបរិសុទ្ធថ្ងៃចុងក្រោយចុះ » ( គ. និង ស. ១២៨:២២, ២៤ ) ។

តើដង្វាយនោះអាចជាអ្វីខ្លះ ដែលប្អូនៗគ្រប់គ្នាអាចថ្វាយដល់ព្រះបាន ? វាគឺជាអំណោយទានមួយដែលទ្រង់ពុំធ្លាប់តម្រូវចង់បានពីប្អូនៗឡើយ ។ វាគឺជាដង្វាយនៃឆន្ទៈរបស់ប្អូនៗ ដើម្បីចុះចូលនឹងព្រះហឫទ័យរបស់ទ្រង់ ។ វាគឺជាការដាក់សិទ្ធិជ្រើសរើសរបស់ប្អូនៗនៅលើអាសនានៃការបូជាផ្ទាល់របស់ប្អូនៗ ។

មានមេរៀនមួយនៃ *មេរៀនអំពីសេចក្ដីជំនឿ* ដែលបានរៀបចំឡើងដោយពួកបងប្អូនប្រុសពីជំនាន់ដើមនៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ចែងដូចនេះ ៖ « សាសនាដែលមិនតម្រូវឲ្យមានការបូជាអ្វីទាំងអស់ គឺគ្មានអំណាចគ្រប់គ្រាន់ ដើម្បីបង្កើតជំនឿដែលចាំបាច់ដល់ជីវិត និង សេចក្ដីសង្គ្រោះនោះទេ » ។[៥]

សិទ្ធិជ្រើសរើសរបស់ប្អូនៗគឺជាដង្វាយមួយ ដែលប្អូនៗអាចថ្វាយចំពោះព្រះ ។ តាមរយៈការស្ម័គ្រចិត្តដាក់ឆន្ទៈរបស់ប្អូនៗទៅតាមព្រះហឫទ័យរបស់ទ្រង់ នោះប្អូនៗនឹងក្លាយដូចជាទ្រង់ ។

ខ្ញុំសូមបញ្ចប់ដោយថ្លែងទីបន្ទាល់របស់ខ្ញុំអំពីព្រះអង្គសង្គ្រោះ ។ តាមរយៈកម្រិតដែលប្អូនៗអនុវត្តសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ ដាក់ឆន្ទៈរបស់ប្អូនៗឲ្យចុះចូលនឹងព្រះហឫទ័យរបស់ព្រះ ធ្វើតាមដំបូន្មានរបស់ព្យាការី ហើយធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នោះប្អូនៗនឹងមានភាពស្មោះត្រង់ ភាពរីករាយ និង ជ័យជម្នះ ។ ■

*ចេញមកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋានមួយ « Where Will You Be in 20 Years » បានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់-អៃដាហូ នៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១២ ។ ដើម្បីទទួលបានសុន្ទរកថាទាំងស្រុងជាភាសាអង់គ្លេស សូមចូលទៅគេហទំព័រ web.byui.edu/devotionalsandspeeches ។*



**កំណត់ចំណាំ**

១. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩ ការគូសបញ្ជាក់បានបន្ថែម ។
២. ប្រ៊ូស អ័រ.ម៉ាខន់ឃី « Agency or Inspiration ? » *New Era* ខែ មករា ឆ្នាំ ១៩៧៥ ទំព័រ ៣៨ ។
៣. ហ្គរដុន ប៊ី ហ៊ិងគ្លី *Caesar, Circus, or Christ ?* Brigham Young University Speeches of the Year ( ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៦៥ ) ទំព័រ ៨ សូមមើលផងដែរ រ័សុល អិម ណិលសុន « Spiritual Capacity » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ទំព័រ ១៦ ។
៤. ថូម៉ាស អេស. ម៉នសុន « Be of Good Cheer » *Liahona* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៩២ ។
៥. *Lectures on Faith* ( ឆ្នាំ ១៩៨៥ ) ទំព័រ ៦៩ ។


បារចនាម៉ូតធលឆ្នាំ ២០១៧
ចូរសូម
យ៉ាកុប ១:៥–៦
« តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូម ដល់ព្រះដែលទ្រង់ប្រទាន ដល់មនុស្សទាំងអស់ ដោយសទ្ធា ឥត បន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ ។ តែត្រូវឲ្យអ្នកនោះ សូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ ។ ដ្បិតអ្នកណា ដែលសង្ស័យ នោះប្រៀបដូចជារលក សមុទ្រដែលត្រូវផាត់ដោយខ្យល់ ទាំង រំពើកចុះឡើង » ។




ហេតុអ្វីជ្រើសយកបាវចនានេះ ហើយវាមានន័យយ៉ាងណាចំពោះអ្នក ? បងប្រុស ស្ទេផាន ដ័បុលយូ អូវើសិន ប្រធានយុវជនទូទៅ និង ស៊ីស្ទើរ បូនី អិល អូស្កាសុន ប្រធានយុវនារីទូទៅចែកចាយយោបល់របស់ពួកគាត់ ។

## ហេតុអ្វីជ្រើសយកខគម្ពីរនេះ ?

**ស៊ីស្ទើរ អូស្កាសុន ៖** ព្រះអម្ចាស់ជ្រាបដឹងពីសារលិខិតដែលប្អូនៗត្រូវការ ហើយវាអស្ចារ្យណាស់ បញ្ហាមួយចំនួនដែលបានកើតឡើងអំឡុងឆ្នាំនេះ ត្រូវបានដោះស្រាយតាមរយៈបាវចនានេះ ហើយវាពិតជាត្រូវនឹងអ្វីដែលកំពុងកើតឡើងក្នុងជីវិតរបស់ប្អូន ។

នៅពេលយើងបានពិភាក្សាខគម្ពីរ យ៉ាកុប ១:៥–៦ ដែលជាបាវចនាសម្រាប់ឆ្នាំនេះ ព្រះវិញ្ញាណបានមានវត្តមានពេញក្នុងបន្ទប់នេះ ។ ហើយយើងទាំងអស់គ្នាយល់ស្របថា វាគឺជាខគម្ពីរដ៏អស្ចារ្យសម្រាប់យុវវ័យរបស់យើង ដោយសារវាមានទំនាក់ទំនងមួយចំនួន ។ វាទាក់ទងនឹងប្រវត្តិសាសនាចក្រ—វាជាខគម្ពីរដែលយ៉ូសែប ស្ម៊ីធបានអាន ហើយបានបំផុសគំនិតលោកឲ្យទៅព្រៃពិសិដ្ឋ ហើយអធិស្ឋាន ។ ហើយទំនាក់ទំនងទីពីរដ៏អស្ចារ្យនោះគឺថា ខគម្ពីរនេះមានទីបន្ទាល់អំពីបេសកកម្មដ៏ទេវភាពរបស់យ៉ូសែប ស្ម៊ីធ ជាអ្វីមួយដែលយើងត្រូវការក្នុងគ្រាមួយ ដែលពិភពលោកនេះកំពុងបន្តចោទសួរអំពីកិត្តិនាមរបស់លោក និងប្រវត្តិសាសនាចក្រ ។ វាក៏ជាសារលិខិតអំពីរបៀបដែលយើងទទួលវិវរណៈផ្ទាល់ខ្លួនក្នុងជីវិតរបស់យើងដែលមនុស្សគ្រប់គ្នាត្រូវតែដឹង ។

**បងប្រុស អូវើន ៖** មានរឿងរ៉ាវជាច្រើនកំពុងកើតឡើងនៅក្នុងជីវិតរបស់ប្អូនសព្វថ្ងៃនេះ ហើយប្អូនមានសំណួរជាច្រើន ។ ជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយសង្គមទាំងអស់ និង គេហទំព័ររុករកដែលយើងមាន មានប្រភពជាច្រើនដែលប្អូនអាចងាកទៅរកចម្លើយចំពោះសំណួររបស់ប្អូនអំពីសេចក្ដីជំនឿ ។ ខគម្ពីរសំខាន់នេះបង្ហាញពីដំណើរការនៃវិវរណៈរបស់យ៉ូសែប ស្ម៊ីធ ដែលជាគំរូមួយដែលយើងអាចធ្វើតាមបាន ។

## តើយុវវ័យអាចយកខគម្ពីរ យ៉ាកុប ១:៥–៦ មកអនុវត្ត និង ប្រើចំពោះខ្លួនពួកគេយ៉ាងដូចម្ដេច ?

**ស៊ីស្ទើរ អូស្កាសុន ៖** ខគម្ពីរនេះមានសារលិខិតដ៏អស្ចារ្យ ។ ខគម្ពីរនោះចែងថា « សូមដោយចិត្តជឿឥតសង្ស័យអ្វីសោះ » ( យ៉ាកុប ១:៦ ) ។ ការណ៍នេះបណ្ដាលឲ្យមានអារម្មណ៍រំជួលចិត្ត ។ ប្អូនត្រូវសូមដោយចិត្តជឿ មិនមែនចិត្តសង្ស័យឡើយ ។

**បងប្រុស អូវើន ៖** ហើយការសូមដោយចិត្តជឿមានន័យថា ការសូមដោយចិត្តស្មោះសរ ។ នៅពេលយ៉ូសែប ស្ម៊ីធ បានទទួលចម្លើយថាត្រូវចូលរួមសាសនាចក្រណាមួយ លោកពុំបានមានប្រសាសន៍ថា « នោះជារឿងល្អដែលគួរដឹងនោះទេ ប៉ុន្តែ . . . » លោកបានឈានទៅមុខដោយសេចក្ដីជំនឿ ។

**ស៊ីស្ទើរ អូស្កាសុន ៖** ចូរចាំថា នោះគឺជាការអធិស្ឋានដ៏សុចរិតមួយ គឺមិនមែនជាការអធិស្ឋានទូលសូមអ្វីដែលយើងចង់បានឡើយ ប៉ុន្តែជាការអធិស្ឋានស្វែងរកអ្វីដែលព្រះមានព្រះទ័យសម្រាប់យើង ។

## តើមានការទូន្មានអ្វីខ្លះ ដែលអ្នកផ្ដល់ឲ្យយុវវ័យក្នុងការប្រើការអធិស្ឋានបែបនេះនៅក្នុងជីវិតរបស់ពួកគេ ?

**ស៊ីស្ទើរ អូស្កាសុន ៖** សូមធ្វើឲ្យការអធិស្ឋាននេះក្លាយជាទម្លាប់ ។ ប្អូនៗពុំអាចភ្លេចវាឡើយ ។ ប្អូនៗមិនអាចព្រងើយកន្តើយនឹងវាឡើយ ។ បងប្រុសរបស់យ៉ារេឌបានផ្ដល់គំរូមួយអំពីរឿងនេះ ( សូមមើល អេធើរ ២:១៤ ) ។

**បងប្រុស អូវើន ៖** ការភ្លេចអធិស្ឋានជារឿយៗគឺជារឿងមួយ ប៉ុន្តែអ្វីមួយដែលកាន់តែមានបញ្ហាជាងនេះនោះគឺការបែរចេញពីព្រះអម្ចាស់ ហើយពុំចង់អធិស្ឋាន ។ នៅពេលប្អូនៗមានអារម្មណ៍ថាប្អូនមិនគួរអធិស្ឋាន នោះគឺជាពេលដែលប្អូនត្រូវការអធិស្ឋានជាខ្លាំង ។ ហើយប្រសិនបើប្អូនអធិស្ឋាន ហើយអានព្រះគម្ពីរ នោះប្អូននឹងធ្វើស្របតាមព្រះវិញ្ញាណ ។ ហើយប្រសិនបើប្អូនពុំធ្វើបែបនេះទេ នោះប្អូនកំពុងដកខ្លួនរបស់ប្អូនថយចេញហើយ ។

**ស៊ីស្ទើរ អូស្កាសុន ៖** យើងអាចទូលផ្ទាល់ជាមួយព្រះ ។ ទ្រង់ពុំបានកំណត់ពេលវេលាឡើយ ។ នោះគឺជាអំណោយទានមួយដ៏អស្ចារ្យអ្វីម្ល៉េះ ដែលយើងដឹងថា យើងអាចធ្វើបែបនោះបាន ហើយថាទ្រង់គង់នៅទីនោះជានិច្ច ។

## តើអ្នកបានរៀនអធិស្ឋានប្រកបដោយអត្ថន័យយ៉ាងដូចម្ដេច ?

**ស៊ីស្ទើរ អូស្កាសុន ៖** ខ្ញុំគិតមិនឃើញពីបទពិសោធន៍មួយណាឡើយ វាគឺជាកម្រិតដ៏ខ្ពស់បំផុតក្នុងពេលវេលានៃជីវិតនេះ ។ ការអធិស្ឋានបានក្លាយជាផ្នែកមួយប្រកបដោយអត្ថន័យបំផុតចំពោះខ្ញុំ ដោយសារខ្ញុំបានប្រឹងប្រែងអធិស្ឋានជាប្រចាំ ។ ខ្ញុំកាន់តែពូកែស្ដាប់ និង ទទួលចម្លើយបានប្រសើរឡើង ។ យើងបានរៀន ហើយយើងបានទទួលវាកាន់តែប្រសើរឡើង ដរាបណាយើងចុះប្រឡូកក្នុងដំណើរការនេះ ។ វាគឺជាការអធិស្ឋានជាប្រចាំរៀងរាល់ថ្ងៃ ធ្វើឲ្យប្រាកដថា ខ្ញុំពុំបានខកខាននូវឱកាសទូលជាមួយព្រះវរបិតាសួគ៌របស់ខ្ញុំឡើយ ។ ដរាបណាយើងកាន់តែអធិស្ឋាន ដរាបនោះយើងកាន់តែពូកែស្ដាប់រកចម្លើយទាំងនោះ ។

**បងប្រុស អូរីន ៖** កាលខ្ញុំនៅយុវវ័យ នៅពេលខ្ញុំត្រូវការដឹងរឿងអ្វីមួយ ខ្ញុំបានចាំអំពីការនិមិត្តដំបូង ហើយគិតថា « យ៉ូសែប ស្ម៊ីធ បានធ្វើរឿងនេះ ។ ខ្ញុំពុំត្រូវការ ការបើកសម្ដែងដ៏ធំអស្ចារ្យអ្វីឡើយ ប៉ុន្តែខ្ញុំត្រូវការចម្លើយ » ។ ដូច្នោះខ្ញុំបានធ្វើតាមលំនាំនោះដោយសេចក្តីជំនឿ ។ ខ្ញុំចាំពីការលុតជង្គង់ ហើយឱនក្បាលរបស់ខ្ញុំចុះ ព្រមទាំងពោលពាក្យអធិស្ឋានពួៗ ។ ការបន្តធ្វើតាមលំនាំនោះ បានប្រទានពរដល់ជីវិតរបស់ខ្ញុំជាច្រើនលើកច្រើនគ្រា ដើម្បីទទួលវិវរណៈផ្ទាល់ខ្លួន ។

## តើចំណុចសំខាន់បំផុតណាខ្លះ ដែលយុវវ័យអាចរៀនអំពីខគម្ពីរនេះ ?

**បងប្រុស អូរីន ៖** ខ្ញុំសូមគូសបញ្ជាក់ជាថ្មីអំពីលំនាំនៃការអធិស្ឋានដែលយ៉ូសែប ស្ម៊ីធបានធ្វើ ។ កាលអាយុ ១៤ ឆ្នាំ លោកបានច្របូកច្របល់ ដូច្នោះលោកបានអានព្រះគម្ពីររបស់លោក ។ ការនិមិត្តដំបូងពុំមែនជាពេលវេលាខ្លី ដែលកើតឡើងដោយសារយ៉ូសែបលុតជង្គង់ចុះអធិស្ឋាននោះឡើយ ។ មានរឿងជាច្រើនដែលត្រូវធ្វើពីមុននោះ ។ លោកបានសញ្ជឹងគិតពីសំណួររបស់លោកម្ដងហើយម្ដងទៀត ។ នៅពេលលោកឃើញ យ៉ាកុប ១:៥–៦ លោកបានមានប្រសាសន៍ថា « ពុំដែលមានបទគម្ពីរណាមួយដែលមានប្រសិទ្ធភាពទៅលើចិត្តមនុស្សដូចជាបទគម្ពីរនេះ មានប្រសិទ្ធភាពមកលើចិត្តខ្ញុំឡើយ » ( យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:១២ ) ។ ខគម្ពីរនោះបានចាក់ចូលទៅក្នុងដួងចិត្តរបស់លោកយ៉ាងខ្លាំង ហើយក្រោយមកលោកបានអនុវត្តតាមខគម្ពីរនោះប្រាប់ ។ លោកបានអធិស្ឋានដោយស្មោះអស់ពីចិត្ត ហើយបន្តឆ្ពោះទៅមុខដោយសេចក្តីជំនឿ ។ ហើយនោះគឺជាអ្វីដែលពួកយើងសង្ឃឹមថា ប្អូនៗនឹងអាចទទួលអារម្មណ៍នេះពីខគម្ពីរនេះក្នុងឆ្នាំ ២០១៧ទាំងមូល។ ■



**ធនធានតាមអ៊ិនធើរណែត**

**ទោះ** បីអ្នកមានគម្រោងធ្វើសកម្មភាព ឬ ធ្វើសន្និសីទ ឬ គិតសាមញ្ញៗអំពីបាវចនានេះដោយខ្លួនអ្នកផ្ទាល់ក្តី នោះអ្នកនឹងឃើញរូបគំនូរ តន្ត្រី និង ធនធានបន្ថែមទៀតសម្រាប់បាវចនាម្ជុតធលឆ្នាំនេះនៅគេហទំព័រ lds.org/go/11752 ។

# ចូរសូម

យ៉ាកុប ១:៥–៦



« តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូម ដល់ព្រះដែលទ្រង់ប្រទានដល់មនុស្ស ទាំងអស់ ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ ។
តែត្រូវឲ្យអ្នកនោះ សូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ ។ ដ្បិតអ្នកណាដែលសង្ស័យ នោះ ប្រៀបដូចជារលកសមុទ្រដែលត្រូវផាត់ដោយខ្យល់ ទាំងរំពើកចុះឡើង » ។

យ៉ាកុប ១:៥–៦

# ការសន្យាទាំង ៥ អំពីការអធិស្ឋាន

ដោយ ខាលីសា ក្រាមើរ

ព្រះវរបិតាសួគ៌បានប្រទានការអធិស្ឋានទុកជារបៀបមួយដើម្បីទាក់ទងដោយផ្ទាល់ជាមួយទ្រង់ ដើម្បីថ្លែងអំណរគុណ ទូលសូមពរជ័យ ហើយ រីកចម្រើនខាងវិញ្ញាណ ។ ជួនកាលអ្វីដែលត្រូវធ្វើនោះគឺឱនក្បាល ឱបដៃ ហើយពោលពាក្យមួយចំនួនដែលសាមញ្ញ ហើយ ស្មោះសរ ។ តើវាអស្ចារ្យណាស់ មែនទេ ? នេះគឺជាការសន្យា ឬ ពរជ័យប្រាំផ្សេងៗគ្នា ដែលយើងអាចទទួលបាន ប្រសិនបើយើងអធិស្ឋាន ៖

## ១ កម្លាំងដើម្បីមានជ័យជម្នះ

ដោយសារយើងជាមនុស្ស យើងអាចមានអារម្មណ៍ទន់ខ្សោយក្នុងចំណុចជាច្រើន—ខាងរូបកាយ អារម្មណ៍ វិញ្ញាណ និង ផ្លូវចិត្ត ។ យើងអាចមានការលំបាកក្នុងការព្យាយាមរត់ប្រណាំង ឬ ប្រឡងឲ្យជាប់ ឬ ទប់ទល់នឹងការល្បួង ឬ ទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។ ប៉ុន្តែការអធិស្ឋានអាចផ្ដល់កម្លាំងដល់យើង ដែលចាំបាច់ដើម្បីយកជ័យជម្នះលើ *អ្វីគ្រប់យ៉ាង* ដែលកើតមាននៅក្នុងជីវិតរបស់យើង ។

ដូចនីហ្វៃបាននិយាយថា « ព្រះអម្ចាស់ទ្រង់មិនចេញបញ្ញាដល់កូនចៅមនុស្សណាឡើយ លើកលែងតែទ្រង់នឹងរៀបចំផ្លូវ ដើម្បីឲ្យគេអាចសម្រេចនូវអ្វីៗ ដែលទ្រង់បានបញ្ញាដល់ពួកគេទុកជាមុនសិន » ( នីហ្វៃទី១ ៣:៧ ) ។ ព្រះអម្ចាស់អាចប្រទានកម្លាំងដល់យើង ដើម្បីសម្រេចបាននូវកិច្ចការល្អៗ ដែលយើងព្យាយាមធ្វើប្រសិនបើកិច្ចការនោះជាព្រះឫទ្ធ័យរបស់ទ្រង់ ។

អធិស្ឋានសូមកម្លាំងឲ្យយកឈ្នះលើការល្បួង ។ អធិស្ឋានសូមកម្លាំងដើម្បីផ្ដោតចិត្តទុកដាក់ ហើយ សិក្សាឲ្យមានប្រសិទ្ធភាពសម្រាប់ការប្រឡង ។ អធិស្ឋានសូមកម្លាំងដើម្បីរត់ទៅដោយឥតនឿយហត់ ។ អធិស្ឋានសូមកម្លាំង ហើយទ្រង់នឹងធ្វើឲ្យអ្នករឹងប៉ឹង ។



## ២ ការអភ័យទោស



ទោះបីវាជារឿងមួយល្អដែលយើងគិតថាយើងពុំល្អឥតខ្ចោះក្តី ។ យើងមានកំហុស ហើយវាគឺជាផ្នែកមួយនៃជីវិតយើង ។ ប៉ុន្តែព្រះអម្ចាស់ផ្ដល់វិធីមួយ ដើម្បីកែតម្រូវកំហុសទាំងនោះ ៖ ព្រះចេស្ដានៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ហើយមធ្យោបាយមួយដើម្បី អាចទទួលបានព្រះចេស្ដាទ្រង់នោះគឺការអធិស្ឋាន ។

នៅពេលយើងទូលសូមការអភ័យទោសតាមរយៈការអធិស្ឋាន នោះយើងអាចត្រូវបានអត់ទោសឲ្យពីអំពើបាបរបស់យើង តាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។ ទោះបីជាយ៉ាងណាអំពើបាបធ្ងន់ធ្ងរអាចត្រូវការជំនួយពីប៊ីស្សព ឬ ប្រធានសាខា ការអធិស្ឋានផ្ទាល់ខ្លួន និង ដោយស្មោះសរនឹងក្លាយជាជំហានទីមួយ *ជានិច្ច* ដើម្បីទទួលការអភ័យទោស—មិនថាយើងកំពុងទូលសូមការអភ័យទោសពីព្រះវរបិតាសម្រាប់ខ្លួនយើង ឬ ជួយយើងឲ្យអភ័យទោសដល់មនុស្សផ្សេងទៀតនោះទេ ។ ទ្រង់នឹងជួយយើងឲ្យរៀនពីរបៀបអភ័យទោសដល់ខ្លួនយើង ។

រចនារូបភាពដោយ ក្លេតុន ថមសុន

## ៣ ចំណេះដឹង និង ការណែនាំ

វិវរណៈផ្ទាល់ខ្លួនអាចជាពរជ័យដំបូងគេនៃការអធិស្ឋាន ដែលអ្នកត្រូវគិតដល់ ជាពិសេសជាមួយនឹងបាវចនាម៉ូតធលថ្មីនេះដែលអ្នកគិតអំពីវា ។ យ៉ូសែប ស្ម៊ីធ ខ្វះចំណេះដឹងថាតើត្រូវចូលរួមជាមួយព្រះវិហារណាមួយ ដូច្នោះលោកបានលុតជង្គង់នៅក្នុងព្រៃពិសិដ្ឋ ហើយទូលសួរសំណួររបស់លោក ហើយលោកបានទទួលចម្លើយ—តាមរបៀបមួយដ៏អស្ចារ្យបំផុត ។

ប៉ុន្តែវិវរណៈពុំមែនមានសម្រាប់តែព្យាការីនោះទេ ហើយវាក៏មិនចាំទាល់តែជាបទពិសោធន៍ដ៏អស្ចារ្យបំផុតដែរ ។ ប្រសិនបើយើងខ្វះប្រាជ្ញាលើរឿងអ្វីមួយយើង *អាច* ហើយ *គួរតែ* ទូលសូមដល់ព្រះ ។ ទ្រង់នឹងឆ្លើយតប ទោះជួនកាលវាមិនតាមអ្វីដែលយើងរំពឹងចង់បានក្តី ។ ព្រះអម្ចាស់នឹងឆ្លើយតបសំណួររបស់យើង ហើយជួយដឹកនាំជីវិតរបស់យើង ប៉ុន្តែយើងត្រូវតែទូលសូមជាមុនសិន !



## ៤ បំណងប្រាថ្នាដើម្បីធ្វើតាមព្រះឫទ័យរបស់ព្រះអម្ចាស់

វាអាចមានការលំបាក ក្នុងការមើលឃើញចំណុចនេះថាជាពរជ័យ—និយាយដោយត្រង់ជួនកាលយើងចង់បានអ្វីៗគ្រប់យ៉ាងសម្រាប់ខ្លួនយើង ដែលព្រះអម្ចាស់ពុំសព្វព្រះឫទ័យឲ្យយើងឡើយ ។ ប៉ុន្តែនៅពេលយើងអធិស្ឋានដើម្បីប្រែចិត្តជឿពិតប្រាកដ ហើយមានបំណងប្រាថ្នាធ្វើតាមព្រះឫទ័យរបស់ព្រះអម្ចាស់ នោះយើងនឹងកត់សម្គាល់អ្វីមួយដែលអស្ចារ្យ ៖ គឺអ្វីដែលយើងចង់បាន ចាប់ផ្តើមកាន់តែដូចអ្វីដែលទ្រង់សព្វព្រះទ័យ ។

ទោះជាយ៉ាងណាការផ្លាស់ប្តូរនៅក្នុងដួងចិត្តនេះនឹងមិនកើតឡើងភ្លាមៗឡើយ ។ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ដូចនេះ ៖ « សម្រាប់យើងភាគច្រើនការប្រែចិត្តជឿជាដំណើរការដែលបន្តជានិច្ច មិនមែនជាហេតុការណ៍តែម្តង ដែលកើតឡើងពីបទពិសោធន៍ដ៏មានឥទ្ធិពល ឬ អស្ចារ្យតែម្តងនោះទេ ។ មួយបន្ទាត់ម្តងៗ មួយសិក្ខាបទម្តងៗ បន្តិចម្តងៗ និង ស្ទើរតែមិនដឹង ការដំរុញគំនិត ពាក្យសម្តី និង ទង្វើ របស់យើងប្រែជាស្របនឹងព្រះទ័យព្រះ » ( « Converted unto the Lord » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ១០៧–៨ ) ។



## ៥ ភាពសុខសាន្ត

ពរជ័យមួយដែលបានសន្យាដល់យើងប្រសិនបើយើងអធិស្ឋាននោះគឺភាពសុខសាន្ត និង ការលួងលោមចិត្តតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ លើសពីនោះទៀត គេហៅទ្រង់ថាព្រះដ៏ជាជំនួយ ។ សូមប្រាកដថាភាពសុខសាន្តនឹងកើតឡើងទោះជាក្នុងគ្រាលំបាកក្តី ។ សូមចាំពីការសន្យារបស់ព្រះអម្ចាស់នៅក្នុង យ៉ូហាន ១៤:២៧ ៖ « ខ្ញុំទុកសេចក្តីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកិយឲ្យទេ ។ កុំឲ្យអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ » ។ ភាពសុខសាន្តនឹងកើតមានឡើងប្រសិនបើយើងទូលសូម ។



ការអធិស្ឋានគឺជាមធ្យោបាយមួយ ទាក់ទងជាមួយព្រះវរបិតាសួគ៌ដែលពេញដោយក្តីស្រឡាញ់របស់យើង ។ សូមប្រើមធ្យោបាយនេះ ហើយឲ្យទ្រង់ប្រទានពរដល់អ្នក ។ ប៉ុន្តែបន្ទាប់ពីការទទួលពរជ័យទាំងនេះតាមរយៈការអធិស្ឋានដោយស្មោះសរហើយនោះ សូមចាំថាត្រូវបង្ហាញអំណរគុណដ៏ស្មោះអស់ពីចិត្តរបស់អ្នក—ដូចដែលអ្នកបានគិតនោះហើយ—គឺការអធិស្ឋាន ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

# ៥ សំណួរចំនួនប្រាំ ដែលត្រូវសួរ *នៅពេលទទួលអារម្មណ៍ថាការអធិស្ឋានពុំបានទទួលចម្លើយ*

ដោយ ម៉ាហ្គារ៉េត វីលឌិន

តើអ្នកធ្លាប់អធិស្ឋាន ហើយរង់ចាំចម្លើយដែលទំនងជាមិនទទួលបានចម្លើយនោះដែរឬទេ ? អ្នកមិននៅតែឯងនោះទេ—ប៉ុន្តែអ្នកអាចប្រាកដថា ព្រះវរបិតាសួគ៌ពិតជាព្រះសណ្ដាប់ការអធិស្ឋានរបស់អ្នក ។ វាសំខាន់ដើម្បីចាំថា ចម្លើយពុំអាចកើតឡើង *នៅពេល* ឬ *តាមរបៀប* ដែលអ្នកចង់បាននោះឡើយ ហើយថាព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ទ្រង់តែងតែជ្រាបដឹងច្បាស់បំផុត ។

នេះគឺជាសំណួរមួយចំនួនដែលអ្នកអាចសួរខ្លួនអ្នក នៅពេលអ្នកមានការលំបាកក្នុងការទទួលចម្លើយចំពោះការអធិស្ឋាន ៖

### ១ តើខ្ញុំត្រៀមខ្លួនរួចជាស្រេចដើម្បីអនុវត្តតាមចម្លើយនោះហើយឬនៅ ?

ការអធិស្ឋានដោយសេចក្ដីជំនឿមានន័យថា ជាការត្រៀមខ្លួនរួចជាស្រេចដើម្បីអនុវត្តតាមចម្លើយដែលអ្នកទទួល—ទោះបីចម្លើយនោះជាចម្លើយដែលអ្នករំពឹងចង់បាន ឬ មិនចង់បានក្ដី ។ មានគ្រាមួយ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលការណែនាំដូចនេះ ៖ « ចូរត្រៀមចិត្តដើម្បីទទួល ហើយគោរពតាមការបង្គាប់ទាំងឡាយ ដែលយើងកំពុងតែនឹងប្រាប់ដល់អ្នកចំពោះអស់អ្នកណាដែលក្រឹត្យវិន័យនេះបានបើកសម្ដែងដល់ពួកគេ នោះត្រូវគោរពតាមក្រឹត្យវិន័យនេះដូចគ្នា » ( គ. និង ស. ១៣២:៣ ) ។ ប្រសិនបើអ្នកអធិស្ឋានថា តើអ្នកគួរតែចូលរួម ឬ មិនចូលរួមពិធីជប់លៀង តើអ្នកនឹងធ្វើតាមដែរឬទេ បើទោះបីជាចម្លើយនោះ ( ឆ្លើយថាអត់ក្ដី ) ?

### ២ តើខ្ញុំបានធ្វើអ្វីគ្រប់យ៉ាងឲ្យអស់ពីសមត្ថភាពរបស់ខ្ញុំដែរឬទេ ?

ឥឡូវនេះឧបមាថា អ្នកពុំបានសិក្សាសម្រាប់ការប្រឡងថ្នាក់វិទ្យាសាស្ត្ររបស់អ្នកឡើយ ដោយសារអ្នកទៅដើរលេងជាមួយមិត្តភក្តិអ្នកទៅវិញ ។ តើព្រះវរបិតាសួគ៌នឹងជួយអ្នកប្រឡងជាប់ដែរឬទេ ប្រសិនបើអ្នកគ្រាន់តែទូលសូមជំនួយពីទ្រង់នោះ ?

យើងត្រូវធ្វើនូវចំណែករបស់យើង ដើម្បីទទួលបានពរជ័យ ។ ដូច្នេះនៅពេលសិក្សាសម្រាប់ការប្រឡង អ្នកអាចអធិស្ឋានសូមកម្លាំងដើម្បីធ្វើកិច្ចការនេះឲ្យបានល្អ ស្របតាមការរៀបចំរបស់អ្នក ។

សូមពិចារណាអំពីគំរូរបស់បុត្រាម៉ូសាយ ដែលមានជោគជ័យក្នុងកិច្ចការផ្សព្វផ្សាយសាសនារបស់ពួកគេ នៅពេលពួកគេបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងកិច្ចការខ្លួន ៖ « ពួកគេបានប្រគល់ខ្លួនទៅក្នុងការអធិស្ឋាន និង ការតមអាហារជាច្រើន ហេតុដូច្នេះហើយ ពួកគេប្រកបដោយវិញ្ញាណនៃការព្យាករណ៍ និង វិញ្ញាណនៃវិវរណៈ ហើយកាលណាគេបង្រៀន គឺគេបង្រៀនដោយអានុភាព និង សិទ្ធិអំណាចពីព្រះ » ( អាលម៉ា ១៧:៣ ) ។



## ៣ ខ្ញុំបានអើពើនឹងចម្លើយនោះឬ ?

ព្រះវរបិតាសួគ៌ព្រះសណ្ដាប់អ្នកជានិច្ច ដូច្នេះវាអាចទៅរួចដែលទ្រង់បានឆ្លើយតបចំពោះការអធិស្ឋានរបស់អ្នកហើយ ។ ដូចមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:១៤ « ដរាបណាអ្នកសូមជាញឹកញាប់ នោះអ្នកបានទទួលការបង្គាប់ពីព្រះវិញ្ញាណរបស់យើង » ។ អ្នកអាចអធិស្ឋានទូលសូមកែវភ្នែកខាងវិញ្ញាណ ដើម្បីទទួលស្គាល់ចម្លើយ ដោយសារជួនកាលការអធិស្ឋានបានឆ្លើយតបតាមរបៀបជំនួស ឬ មិនដោយផ្ទាល់ឡើយ—ដូចជាតាមរយៈទង្វើពីមនុស្សដទៃជាដើម ។

ហើយសូមកុំភ្លេចឆ្លៀតពេលស្ដាប់ផងដែរ ។ អែលឌើរ រីឆាដ ជី ស្កត ( ឆ្នាំ ១៩២៨-២០១៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ដូចនេះ ៖ « ចម្លើយ [ របស់ព្រះវរបិតាសួគ៌ ] កម្រនឹងកើតឡើងណាស់ ខណៈដែលអ្នកកំពុងតែលុតជង្គង់អធិស្ឋាននោះ ។ . . . តែទ្រង់នឹងបំផុសគំនិតអ្នកនៅក្នុងគ្រាដ៏ស្ងប់ស្ងាត់នានា ពេលដែលព្រះវិញ្ញាណអាចរំជួលដល់គំនិត និងដួងចិត្តអ្នកយ៉ាងមានប្រសិទ្ធិភាពបំផុត » ( « Using the Supernal Gift of Prayer » *Liahona* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៩ ) ។

## ៤ តើបំណងប្រាថ្នារបស់ខ្ញុំសុចរិតដែរឬទេ ?

ប្រសិនបើអ្នកទូលសូមអ្វីមួយដែលអ្នកមិនចាប់អារម្មណ៍ខ្លាំង វាទំនងថាការស្នើសុំរបស់អ្នកមិនត្រូវបានផ្ដល់ឲ្យឡើយ ។ ព្រះអង្គសង្គ្រោះបានបង្រៀនយើងថា « ត្រូវអធិស្ឋានដល់ព្រះវរបិតាដោយនូវនាមនៃ [ ព្រះយេស៊ូវគ្រីស្ទ ] ជានិច្ច » ( នីហ្វៃទី៣ ១៨:១៩ ) ដែលបានផ្ដល់យោបល់ថា យើងសូមអ្វីដែលត្រឹមត្រូវ ប្រយោជន៍ឲ្យយើងបានទទួល ។ សូមសួរខ្លួនឯងថា « តើព្រះអង្គសង្គ្រោះមានព្រះទ័យបែបណាចំពោះការចង់បានរបស់ខ្ញុំ » ? ប្រសិនបើបំណងប្រាថ្នារបស់អ្នកផ្ដោតខ្លាំងលើភាពអាត្មានិយម ឬ កិច្ចការផ្សេងៗដែលទុច្ចរិត នោះសូមអធិស្ឋានឲ្យមានការផ្លាស់ប្ដូរចិត្ត ហើយឲ្យដឹងពីអ្វីដែលព្រះអង្គសង្គ្រោះមានព្រះទ័យចំពោះអ្នក ។

## ៥ តើវាជាពេលវេលាត្រឹមត្រូវដែរឬទេ ?

អ្វីដែលយើងទូលសូមអាចជារឿងត្រឹមត្រូវ ប៉ុន្តែពេលវេលាមិនទាន់ដល់ពេលនៅឡើយ ។ ព្រះវរបិតាសួគ៌មានផែនការមួយដ៏មហិមាសម្រាប់យើង ប៉ុន្តែជួនកាលកាលវិភាគរបស់យើងខុសផ្សេងពីទ្រង់បន្តិច ។ « ព្រះបន្ទូលទាំងឡាយរបស់យើងពិត ហើយនឹងមិនខាតបង់ឡើយ ។ . . . ប៉ុន្តែគ្រប់ទាំងអស់ត្រូវតែកើតឡើង តាមពេលរបស់វា » ( គ. និង ស. ៦៤:៣១–៣២ ) ។ វាអាចមានន័យថាជាការរង់ចាំបន្តិចទៀត សម្រាប់ឲ្យរបួសនោះបានជា ឬ សត្វចិញ្ចឹមដែលបាត់នោះអាចរកឃើញវិញ ហើយជួលកាលពេលវេលារបស់ព្រះអម្ចាស់រួមមានដល់ទៅជីវិតបន្ទាប់នេះផងដែរ—ប៉ុន្តែអ្នកអាចដឹងប្រាកដថា ទ្រង់នឹងស្ដាប់ ហើយជួយអ្នកជារៀងតទៅ ។



វាអាចពិបាកដើម្បីអត់ធ្មត់ ជាពិសេសនៅពេលចម្លើយចំពោះការអធិស្ឋានរបស់អ្នកមិនបង្ហាញជាក់ច្បាស់នោះ ។ ប៉ុន្តែនៅពេលអ្នកស្រាវជ្រាវ នោះអ្នកអាចមានចិត្តក្លាហានក្នុងការដឹងថា អ្នកនឹងរកឃើញចម្លើយដែលអ្នកត្រូវការជានិច្ច ប្រសិនបើអ្នកស្វែងរកវាដោយស្មោះអស់ពីចិត្ត ៖ « ឯងរាល់គ្នានឹងស្វែងរកយើង ហើយនឹងឃើញផង គឺកាលណាឯងស្វែងរកយើងឲ្យអស់អំពីចិត្ត » ( យេរេមា ២៩:១៣ ) ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

# សូមដល់ព្រះ

ដោយខ្ជាប់ខ្ជួន ♩= ១៥៦–១៧០

ទំនុកច្រៀង និងទំនុកភ្លេងដោយ នីក ដេយ៍





24
A♭ E♭ B♭
បើ អ្នក សូម___ នោះ ទ្រង់ នឹង ឆ្លើយ___ តប។ បើ លុត ជ ង្គង់ ទ្រង់___ នឹង ជួយ។
28
E♭ E♭/G A♭ E♭ B♭ E♭ E♭/G
បើ អ្នក បិទ___ នេ ត្រា ព្រម ទាំង___ ខ្សឹប ទ្រង់ នឹង ខ្សឹប ទៅ ព្រ___ លឹង អ្នក។___ បើ អ្នក ឈឺ
33
A♭ E♭ B♭ Cm
ចាប់ ទ្រង់ នឹង ព្យា___ បាល។ បើ អ្នក___ រាប___ សា ទ្រង់___ នឹង មក។___
37
រំលងទៅ Coda
នៅលើកទីបី
A♭ E♭ B♭ E♭
បើ អ្នក ខ្វះ ប្រា___ ថ្នា សូម ដល់ ព្រះ។___ សូម ដល់ ព្រះ។___
41
A♭ E♭ G
ពី មុន អ្នក ធ្លាប់___ ភ័យ ខ្លាច រ ងា ហើយ វ ង្វេង___ លើ ផ្ទៃ ជល សា ជំ នឿ នេះ






រូបភាពដោយ ប្រាយអិន បឹប



© 2016 Intellectual Reserve, Inc. All rights reserved. បទចម្រៀងនេះ
អាចថតចម្លងយកមកប្រើប្រាស់ម្ដងម្កាល តែពុំមែនសម្រាប់ធ្វើជាអាជីវកម្មនៅតាមផ្ទះ
និងសាសនាចក្រឡើយ ។ សេចក្ដីប្រកាសនេះត្រូវបិទនៅលើសំណៅថតចម្លងនីមួយៗ ។

# យ៉ាកុប ១:៥–៦

*យ៉ាកុបបានបង្រៀនយើងអំពីរបៀបសូមដល់ព្រះ ដូច្នេះយើងនឹងទទួលបានចម្លើយ ។*



## សូមដោយសេចក្ដីជំនឿ

« តម្រូវការនៃការសូមដោយចិត្តជឿ [ ថ្លែងបញ្ជាក់ ] ពីរឿងដ៏ចាំបាច់ដើម្បីធ្វើតាមតម្រូវការនោះដើម្បីប្រកាស ហើយអនុវត្ត ពុំមែនគ្រាន់តែសម្ដែងឡើងនោះទេ វាគឺជាកាតព្វកិច្ចដើម្បីទូលអង្វរ ហើយអនុវត្ត » ។

អែលឌើរ ដាវីឌ អេ បេដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « **Ask in Faith** » ***Liahona*** ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៩៤ ។

## ឥតបន្ទោស

ព្រះនឹងឆ្លើយតបដល់អ្នក ហើយនឹង *ឥតបន្ទោស* ( រិះគន់ ជេរ ឬ បន្ទោស ) អ្នក ដោយសារតែការសួរទ្រង់ដ៏រាបទាប សូមចម្លើយចំពោះសំណួរដ៏ស្មោះសរ ។



## ឥតសង្ស័យអ្វីសោះ

« ក្នុងគ្រាមានទុក្ខព្រួយ ចូរឲ្យសេចក្ដីសញ្ញារបស់អ្នកក្លាយជាអ្វីដែលសំខាន់បំផុត ហើយចូរឲ្យការគោរពរបស់អ្នកបានឥតល្អៀង ។ បន្ទាប់មក អ្នកអាចសុំដោយសេចក្ដីជំនឿ ដោយឥតប្រែប្រួល ទៅតាមអ្វីដែលអ្នកត្រូវការ ហើយព្រះនឹងឆ្លើយតប » ។

អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « **The Power of Covenants** » ***Liahona*** ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ២២ ។

៥ តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ ។

៦ តែត្រូវឲ្យអ្នកនោះសូមដោយចិត្តជឿឥតសង្ស័យអ្វីសោះ ។ ដ្បិតអ្នកណាដែលសង្ស័យ នោះប្រៀបដូចជារលកសមុទ្រដែលត្រូវផាត់ដោយខ្យល់ ទាំងរំពើកចុះឡើង ។

## ខ្វះប្រាជ្ញា

មានចំណុចមួយចំនួន ឬ ជាច្រើនទៀត ដែលយើងទាំងអស់គ្នាខ្វះប្រាជ្ញាដែលមានតែព្រះប៉ុណ្ណោះដែលអាចប្រទានដល់យើងបាន ។ « ហើយបើមិនមែនជាព្រះវិញ្ញាណនៃព្រះនោះក៏គ្មានអ្នកណាស្គាល់សណ្ឋានព្រះបានដែរ » ( កូរិនថូសទី១ ២:១១ ) ។ នោះជាមូលហេតុដែលយើងទាំងអស់គ្នាត្រូវតែសូមដល់ទ្រង់ ។

## សូមដល់ព្រះ

« ការអធិស្ឋានគឺជាការនិយាយទៅកាន់ព្រះវរបិតាសួគ៌ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។ . . .

គោលបំណងនៃការអធិស្ឋាន គឺមិនមែនដើម្បីផ្លាស់ប្ដូរព្រះហឫទ័យរបស់ព្រះឡើយ ប៉ុន្ដែដើម្បីនឹងទទួលសម្រាប់ខ្លួនយើង និង សម្រាប់អ្នកដទៃនូវព្រះពរនានា ដែលព្រះអម្ចាស់ពិតជាប្រទានឲ្យ ប៉ុន្ដែគឺយើងត្រូវតែសូមដើម្បីឲ្យបានទទួល » ។

សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ការអធិស្ឋាន » **scriptures.lds.org** ។

## ប្រទានដល់មនុស្សទាំងអស់

« ទ្រង់ពុំបដិសេធអ្នកណាម្នាក់ ដែលមករកទ្រង់ឡើយ . . . ហើយមនុស្សទាំងអស់ក៏ដូចគ្នានៅចំពោះព្រះដែរ » ។

នីហ្វៃទី២ ២៦:៣៣

## ដោយសទ្ធា

*ដោយសទ្ធា*—ពាក្យភាសាក្រិកបានបកប្រែមកពីពាក្យ « មិនស្មុគស្មាញ » ដែលអាចបញ្ជាក់ពីន័យត្រង់នៅក្នុងគោលបំណងរបស់ព្រះ ដើម្បីប្រទានដល់យើងដោយព្រះទ័យបើកចំហ និង ទូលាយ ។

*កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖ នៅទំព័រនេះពុំមែនមានន័យថាវាពន្យល់ទូលំទូលាយពីចំណេះចំណានខាងគោលលទ្ធិដែលបានជ្រើសរើសនោះទេ វាគ្រាន់តែជាចំណុចចាប់ផ្ដើមមួយសម្រាប់ការសិក្សាផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះ ។*



# គ្រានៃសេឡេស្ទាល

*ជួនកាលខ្ញុំមានអារម្មណ៍មួយថា ស្ថានសួគ៌នៅមិនឆ្ងាយឡើយ ។*

**ដោយ ហូលី ម៉េហ្គេន ឡារ៉ា ហាន់ធើរ**

នាថ្ងៃមួយ អ្នកដឹកនាំថ្នាក់យុវនារីរបស់ខ្ញុំបានបង្រៀនពួកយើងអំពីគ្រាអស្ចារ្យនានា ដែលអ្នកទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយមានអារម្មណ៍ថានៅក្បែរព្រះ ។ ពួកគេហៅវាថា « គ្រានៃសេឡេស្ទាល » ជាឃ្លាសាមញ្ញមួយដែលងាយចងចាំ ។ សម្រាប់ខ្ញុំ ខ្ញុំបានដឹងរួចទៅហើយថា « គ្រានៃសេឡេស្ទាល » គឺជាអ្វីនោះ ដ្បិតខ្ញុំធ្លាប់ទទួលអារម្មណ៍នេះកាលពីមុន គឺដូចជាពេលដែលអ្នកមានអារម្មណ៍តិចតួច ឬ ភ្លក់រសជាតិនៃជីវិតនៅនគរសេឡេស្ទាលដូច្នោះដែរ ។ ខ្ញុំមានគ្រាទាំងនេះជាច្រើន ។

បន្ទាប់ពីពួកអ្នកដឹកនាំបានណែនាំអំពីគំនិតនេះ យើងបាននាំគ្នាចេញទៅក្រៅថ្នាក់ ។ ព្រះអាទិត្យកំពុងរះចាំងទៅលើដើមឈើ ។ យើងបានបិទភ្នែក ។ ខ្ញុំមានអារម្មណ៍ថា ព្រះអាទិត្យដែលចាំងពន្លឺមកលើមុខខ្ញុំនោះដូចជាខ្យល់ជំនោរបក់មកយ៉ាងកក់ក្ដៅ ។ សត្វបក្សាបក្សីស្រែកច្រៀង ហើយដើមឈើបក់យោលយោគទៅតាមខ្យល់បក់ខណៈដែលយើងរីករាយនឹងការបង្កបង្កើតរបស់ព្រះ ។ នោះហើយគឺជាគ្រានៃសេឡេស្ទាល ។

ពេលមួយទៀតដែលខ្ញុំមានអំពីគ្រានៃសេឡេស្ទាលនោះគឺបន្ទាប់ពីមិត្តភក្តិរបស់ខ្ញុំបានជ្រមុជទឹករួច ។ នៅពេលយើងបានដើរត្រឡប់ចូលទៅក្នុងរោងថ្វាយបង្គំវិញ រហូតដល់កម្មវិធីនោះចប់ នាងបានចាប់ដៃរបស់ខ្ញុំ ហើយនិយាយអំពីភាពអស្ចារ្យដែលពួកយើងបានក្លាយជាមិត្តនឹងគ្នា ហើយនឹងបន្តរហូតតទៅ—គឺរហូតដល់អស់កល្បជានិច្ច ។ ខ្ញុំនឹងមិនភ្លេចគ្រានោះឡើយ ។ ខ្ញុំមានចិត្តរំភើប និង រីករាយ ព្រមទាំងមានអំណរគុណ !

មួយឆ្នាំក្រោយមក យើងទាំងពីរនាក់ មានអំណរដដែលនោះជាថ្មីម្ដងទៀត នៅពេលយើងឈរនៅអាងជ្រមុជទឹក ហើយមើលម្ដាយរបស់នាងចូលទៅក្នុងទឹកនៃបុណ្យជ្រមុជ ។ ពិតជាមានលម្អនៅព័ទ្ធជុំវិញមែន ។

ប្រហែលជាកន្លែងដ៏ល្អបំផុតដើម្បីមានបទពិសោធន៍នេះគឺមាននៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ ។ គ្រាដំបូងដែលខ្ញុំបានចូលក្នុងព្រះវិហារបរិសុទ្ធ នោះខ្ញុំមានពរដែលបានចូលទៅទីនោះជាមួយឪពុកម្ដាយ និង ប្អូនស្រីរបស់ខ្ញុំ ។ ខ្ញុំបានជ្រមុជទឹកឲ្យជីដូនទួតរបស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍ថាគាត់មានក្ដីរីករាយ ។

គ្រានៃសេឡេស្ទាលអាចកើតមានឡើងនៅគ្រប់ទីកន្លែង និង គ្រប់ពេលវេលា—អំឡុងពេលស្ដាប់តន្ត្រី ឬ អំឡុងពេលរាត្រីជួបជុំក្រុមគ្រួសារ ឬ ពេលនៅសាលារៀន ។ ខ្ញុំចាំពីរាត្រីជួបជុំក្រុមគ្រួសារមួយ នៅពេលបងប្អូនទាំងអស់គ្នាបានសើចរហូត ! នោះគឺជាគ្រាមួយដែលខ្ញុំពេញចិត្តបំផុត ។

គ្រានៃសេឡេស្ទាលទាំងនេះបានពង្រឹងទីបន្ទាល់របស់ខ្ញុំ ហើយបានជួយខ្ញុំឲ្យមានស្មារតីមួយកាន់តែមានអំណរគុណថែមទៀត ។ គ្រាទាំងនោះបានបង្រៀនខ្ញុំនូវមេរៀនដ៏អស្ចារ្យជាច្រើន ។ លើសពីនេះទៀត គ្រាទាំងនោះបានធ្វើឲ្យខ្ញុំរីករាយ និង រំភើបចិត្តអំពីដំណឹងល្អ ! ខ្ញុំដឹងថា ប្រសិនបើខ្ញុំបន្តរស់នៅតាមដំណឹងល្អ នោះលម្អទាំងអស់ សុភមង្គល ភាពសុខសាន្ត និង សេចក្ដីស្រឡាញ់ដែលខ្ញុំមាននៅក្នុងគ្រានៃសេឡេស្ទាលនីមួយៗ នឹងក្លាយជាអ្វីមួយដែលខ្ញុំអាចទទួលអារម្មណ៍អំពីវាជានិច្ច—ក្នុងកម្រិតមួយយ៉ាងខ្លាំង—នៅក្នុងនគរសេឡេស្ទាល ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ឡាណាស្សៀរភាគខាងជើងប្រទេសស្កុតឡង់ ។*

# ទីកន្លែងរបស់យើង




រូបថតព្រះវិហារបរិសុទ្ធណៅវូ អ៊ិលលីណោយ ដោយម៉ៃឃើល អេស រ៉េ ហ្វឺង ស.រ.អ. ។

## ការទទួលយក #ការអញ្ជើញនៃព្រះវិហារបរិសុទ្ធ

ខ្ញុំបានជ្រមុជទឹកនៅក្នុងឆ្នាំ ២០១២ ហើយបានចូលរួមក្នុងសាខាមួយនៅមណ្ឌល អ៊ីប៉ូមៀរ ប្រេស៊ីល ។ តាំងពីឆ្នាំ ២០១៤ មក ខ្ញុំពិតជាបានសកម្មក្នុងកិច្ចការពង្សប្រវត្តិណាស់ ។ វាបានចាប់ផ្ដើមជាមួយនឹងការសំណូមពរមកពីអែលឌើរ នែល អិល អាន់ឌើរសិន ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់នៅកម្មវិធី RootsTech ដើម្បីធ្វើបុណ្យជ្រមុជទឹកសម្រាប់ឈ្មោះក្រុមគ្រួសាររបស់ខ្ញុំផ្ទាល់ ។ ខ្ញុំមានអារម្មណ៍តាំងចិត្តពិតប្រាកដដើម្បីធ្វើកិច្ចការពង្សប្រវត្តិ ដោយដឹងថាប្រសិនបើខ្ញុំ « គោះ » នោះវានឹង « បើក » ( សូមមើល ម៉ាថាយ ៧:៧ ) ។

ឥឡូវនេះខ្ញុំមានឈ្មោះជាច្រើនជំនាន់ រូបថត ឯកសារ និង អ្វីៗដែលសំខាន់បំផុត ប្រវត្តិគ្រួសារកាន់តែច្រើនបន្ថែមទៀត ដែលអស្ចារ្យយ៉ាងខ្លាំង ។ ដោយមានព័ត៌មាននេះ ខ្ញុំបានសរសេរសៀវភៅមួយជាមួយរូបថត និង កាលបរិច្ឆេទនានាមកពីពង្សប្រវត្តិរបស់ខ្ញុំ ។ គម្រោងនេះបានជួយខ្ញុំឲ្យទាក់ទងសមាជិកគ្រួសារខ្ញុំ ដែលមិនមែនជាសមាជិកសាសនាចក្រ ហើយបានផ្ដល់ឱកាសដល់ខ្ញុំដើម្បីចែកចាយទីបន្ទាល់ខ្លួន ដែលថាក្រុមគ្រួសារអាចនៅជាមួយគ្នាអស់កល្បជានិច្ច ។

កិច្ចការនេះបានជួយខ្ញុំឈរយ៉ាងរឹងប៉ឹងនៅក្នុងទីបរិសុទ្ធនានា បន្តសកម្មនៅក្នុងសាសនាចក្រ ហើយទទួលការហៅបម្រើព្រះអម្ចាស់តាមរយៈការបម្រើបេសកកម្ម ។

ខ្ញុំមានទីបន្ទាល់ថា កិច្ចការនៃសេចក្ដីសង្គ្រោះដែលបានធ្វើឡើងដោយសាសនាចក្រនៅផ្នែកទាំងសងខាងនៃវាំងននគឺជាការពិត ហើយបានបំផុសគំនិតដោយព្រះវរបិតាសួគ៌របស់យើង ។ ពីមុនបេសកកម្មរបស់ខ្ញុំ នោះខ្ញុំបានមានឱកាសធ្វើបុណ្យជ្រមុជទឹកឲ្យជីដូនជីតារបស់ខ្ញុំ ហើយឥឡូវនេះក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ខ្ញុំមានឱកាសជ្រមុជទឹកមនុស្សដែលកំពុងនៅរស់ ហើយចង់ផ្លាស់ប្ដូរជីវិតរបស់ពួកគេជារៀងរហូត ។ ■

អែលឌើរ ខ្លាឌីអូ ខ្លោស ជុញ៉រ បេសកកម្ម មេសា អារីហ្សូណា

*ខាងលើ ៖ រូបថតនេះតំណាងឲ្យសេចក្ដីស្រឡាញ់របស់ព្រះចំពោះខ្ញុំដោយផ្ទាល់ និង ចំពោះបងប្អូនស្រីរបស់ខ្ញុំ ដែលមានម្នាក់កំពុងបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។ ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទគឺជាអំណោយដែលពុំអាចពិពណ៌នាបាននៅក្នុងជីវិតរបស់យើង ។*

ខេនៀរ អ័រ នៅព្រះវិហារបរិសុទ្ធ ម៉ុនទើរ៉េ ម៉ិកស៊ិក



**ដោយអែលឌើរ អិម រ័សុល បាឡឺដ**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

# របៀប ចែកចាយដំណឹងល្អ

យើងពុំចាំបាច់សោកស្ដាយចំពោះសេចក្ដីជំនឿរបស់យើង ឬ ដកយកអ្វីដែលយើងដឹងថាជាការពិតវិញទ្បើយ ។ ប៉ុន្តែយើងអាចចែកចាយដំណឹងល្អនៅក្នុងស្មារតីមួយនៃការយល់ដឹងដោយក្ដីស្រឡាញ់—ដោយម៉ឺងម៉ាត់ និង មានទំនុកចិត្ត ដោយភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អនៃព្រះ—ដោយមិនគាបសង្កត់ដល់អ្នកដែលស្ដាប់យើង ឬ មានអារម្មណ៍ថា យើងពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនប្រសិនបើពួកគេពុំបានទទួលយកភ្លាមៗនូវអ្វីដែលយើងជឿនោះ ។

នៅពេលយើងមានព្រះវិញ្ញាណបរិសុទ្ធជាដៃគូ នោះយើងអាចធ្វើកិច្ចការសាមញ្ញៗ ដើម្បីជួយនាំការយល់ដឹងអំពីដំណឹងល្អកាន់តែប្រសើរទ្បើង ទៅកាន់ជីវិតនៃសមាជិកសាសនាចក្រដែលមិនសូវសកម្ម ព្រមទាំងអស់អ្នកដែលគ្មានជំនឿដូចជាពួកយើង ។ គ្មានការត្រូវការនូវកម្មវិធីថ្មីដើម្បីធ្វើកិច្ចការនេះទ្បើយ ។ យើងពុំចាំបាច់ត្រូវការសៀវភៅក្បួនខ្នាត ឬ ការហៅបម្រើ ឬ ការប្រជុំបំពាក់បំប៉នទ្បើយ ។ តម្រូវការដែលចាំបាច់នោះគឺសមាជិកល្អរបស់សាសនាចក្រត្រូវរៀន ពឹងផ្អែកលើព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហើយជាមួយនឹងព្រះចេស្ដានេះ អាចឈោងទៅជួយ និង ជះឥទ្ធិពលដល់ជីវិតនៃកូនចៅរបស់ព្រះវរបិតាយើង ។ គ្មានការបម្រើណាដែលយើងអាចធ្វើកាន់តែអស្ចារ្យជាងការចែកចាយ ទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើង ជាមួយអស់អ្នកដែលខ្វះការយល់ដឹងអំពីដំណឹងល្អដែលបានស្ដារទ្បើងវិញរបស់ព្រះយេស៊ូវគ្រីស្ទទ្បើយ ។

ដូច្នេះបងប្អូនប្រុសស្រី តើបងប្អូនបានត្រៀមខ្លួនធ្វើអ្វីមួយហើយឬនៅ ? តើយើងម្នាក់ៗអាចតាំងចិត្តនៅថ្ងៃនេះដើម្បី បង្កើនការរៀបចំខ្លួនខាងវិញ្ញាណរបស់យើង តាមរយៈការស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ហើយដោយមានព្រះចេស្ដារបស់ទ្រង់ជាដៃគូ ផ្ដល់ពរកាន់តែច្រើនដល់កូនចៅរបស់ព្រះវរបិតា ឲ្យមានការយល់ដឹង និង ចំណេះដឹងដែលថាសាសនាចក្រនេះពិតដែរឬទេ ?

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះអង្គសង្គ្រោះមានព្រះជន្មរស់ ហើយទ្រង់នឹងប្រទានពរដល់យើងម្នាក់ៗ ប្រសិនបើយើងនឹងធ្វើឲ្យអស់ពីសមត្ថភាពយើង ដើម្បីជំរុញកិច្ចការដ៏អស្ចារ្យរបស់សាសនាចក្រទ្រង់ឲ្យបន្តឆ្ពោះទៅមុខនោះ ។ សូមឲ្យយើងម្នាក់ៗតាំងចិត្តធ្វើនូវកិច្ចការបន្ថែមទៀត ។ ■

*ដកស្រង់ចេញពីសុន្ទរកថាសន្និសីទទូទៅខែ មេសា ឆ្នាំ ២០០០ ។*



## តើអ្នកបានអនុវត្តគោលការណ៍នេះ ដោយរបៀបណា ?

ខ្ញុំមានអំណរគុណជាខ្លាំងដែលខ្ញុំត្រូវបានចិញ្ចឹមបីបាច់ឲ្យធំទ្បើងនៅក្នុងសាសនាចក្រនេះ ។ ខ្ញុំចូលចិត្តចែកចាយដំណឹងល្អ ហើយខ្ញុំព្យាយាមធ្វើជាគំរូល្អ ដោយសារខ្ញុំដឹងថាមានមិត្តភក្ដិ និង មនុស្សដទៃទៀតកំពុងមើលខ្ញុំ ជាពិសេសព្រះវរបិតាសួគ៌របស់ខ្ញុំ ។ ព្រះវរបិតាគង់នៅស្ថានសួគ៌ពុំមើលរំលង ឬ មិនអើពើនឹងអ្វីដែលអ្នកធ្វើទ្បើយ ។ អ្នកត្រូវតែព្យាយាមធ្វើអ្វីដែលត្រឹមត្រូវ ហើយចែកចាយដំណឹងល្អជាមួយកូនចៅរបស់ទ្រង់ ដ្បិតមានឱកាសរាប់មិនអស់ដើម្បីចែកចាយវា អ្នកគ្រាន់តែអធិស្ឋានដើម្បីស្វែងរក ហើយប្រើប្រាស់ឱកាសទាំងនោះប៉ុណ្ណោះ ។

ធារី ជី អាខេនសាស ស.រ.អា.

# ចំទៅនឹងគោលដៅ

## ហេតុអ្វីការមិនអភ័យទោសជា **អំពើបាបធ្ងន់ធ្ងរជាង** ការប្រព្រឹត្ត **អាក្រក់** ដាក់អ្នកដទៃទៅទៀត ?

**ព្រះ**អម្ចាស់បានបង្រៀនថា ៖ « អ្នកត្រូវអត់ទោសដល់គ្នាទៅវិញទៅមក ដ្បិតអ្នកណាដែលមិនអត់ទោសដល់បងប្អូនរបស់ខ្លួន ចំពោះការរំលងរបស់គេទេ នោះជាប់ទោសនៅចំពោះព្រះអម្ចាស់ ព្រោះនៅជាប់នឹងអ្នកនោះ គឺជាបាបដ៏ធំជាង ។

« យើងជាព្រះអម្ចាស់នឹងអត់ទោសដល់អ្នកណាដែលយើងនឹងអត់ទោស ប៉ុន្តែរីឯអ្នកវិញ គឺតម្រូវឲ្យអត់ទោសដល់មនុស្សទាំងអស់ » ( គ. និង ស. ៦៤:៩–១០ ) ។

នៅពេលយើងមិនព្រមអភ័យទោស នោះយើងកំពុងដាក់ការវិនិច្ឆ័យដែលមានដែនកំណត់របស់យើងនៅលើការវិនិច្ឆ័យដ៏ល្អឥតខ្ចោះរបស់ព្រះអម្ចាស់ ។ ទ្រង់មានទស្សនៈយ៉ាងល្អឥតខ្ចោះអំពីដួងចិត្តមនុស្ស និង កាលៈទេសៈនានា ហើយការវិនិច្ឆ័យគឺជារបស់ផងទ្រង់តែមួយអង្គឯងគត់ ។ ទីបំផុតទ្រង់នឹងដោះស្រាយឲ្យមានសេចក្ដីយុត្តិធម៌ និង សេចក្ដីមេត្តាករុណាយ៉ាងល្អឥតខ្ចោះសម្រាប់មនុស្សទាំងអស់—ទាំងអ្នកដែលធ្វើបាបអ្នកដទៃ និង អ្នកដែលត្រូវគេធ្វើបាប ។

ក្រៅពីនេះ ដោយតម្រូវឲ្យយើងអភ័យទោស នោះព្រះអម្ចាស់កំពុងជួយពួកយើងឲ្យជ្រើសយកសុភមង្គល មិនមែនទុក្ខសោកឡើយ ឲ្យបោះបង់ គំនុំគុំកួន និង ការថ្នាំងថ្នាក់ចិត្តរបស់យើង ហើយទទួលការព្យាបាលតាមរយៈព្រះគុណរបស់ទ្រង់ ។ បន្ទាប់មកយើងឃើញថា ដូចដែលអែលឌើរ ខេវីន អ័រ ដាន់ខិន ក្នុងពួកចិតសិបនាក់បានរំឭកយើងថា « ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះមិនមែនសម្រាប់តែអ្នកដែលត្រូវប្រែចិត្តឡើយ វាក៏សម្រាប់អស់អ្នកដែលត្រូវអភ័យទោសឲ្យផងដែរ » ( « The Healing Ointment of Forgiveness » *Liahona* ខែឧសភា ឆ្នាំ ២០១៦ ទំព័រ ៣៥ ) ។ ■



## តើសាសនាចក្រមានទស្សនវិស័យបែបណាចំពោះ **ជំងឺធ្លាក់ទឹកចិត្ត** ហើយតើខ្ញុំគប្បីដោះស្រាយជាមួយជំងឺធ្លាក់ទឹកចិត្តដោយរបៀបណា ?

**ម**នុស្សគ្រប់គ្នាមានអារម្មណ៍បាក់ទឹកចិត្តពីមួយគ្រាទៅមួយគ្រា ហើយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ និង ជំនួយពីគ្រួសារ ថ្នាក់ដឹកនាំ និង អ្នកដទៃផ្សេងទៀត អាចជួយយើងឲ្យរកឃើញការលួងលោម អំណរ និង ភាពសុខសាន្តជាថ្មីម្ដងទៀត ។ ប៉ុន្តែថ្នាក់ដឹកនាំសាសនាចក្របានទទួលស្គាល់ថា ជំងឺធ្លាក់ទឹកចិត្តកម្រិតធ្ងន់ធ្ងរ ឬ វិបត្តិធ្លាក់ទឹកចិត្តដ៏ខ្លាំង ( MDD ) គឺជាស្ថានភាពយ៉ាងធ្ងន់ធ្ងរ ដែលអាចរំខានដល់សមត្ថភាពរបស់មនុស្សម្នាក់ក្នុងការធ្វើកិច្ចការបានពេញលេញទាំងស្រុង ។ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានផ្ដល់យោបល់ឲ្យធ្វើកិច្ចការមួយចំនួន ប្រសិនបើអ្នកជួបប្រទះនឹងការធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ ៖

- កុំបោះបង់សេចក្ដីជំនឿលើព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទឡើយ ។
- ធ្វើកិច្ចការនានាដែលយាងព្រះវិញ្ញាណចូលមកក្នុងជីវិតរបស់អ្នក ( អធិស្ឋាន សិក្សាព្រះគម្ពីរ ។ល។ )
- ស្វែងរកពាក្យទូន្មានពីឪពុកម្ដាយ និង ថ្នាក់ដឹកនាំបព្វជិតភាព ។
- ទទួលការប្រសិទ្ធពរបព្វជិតភាព ។
- ទទួលទានសាក្រាម៉ង់រាល់សប្ដាហ៍ ហើយកាន់ខ្ជាប់ទៅនឹងការសន្យានៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។
- រកមើលសញ្ញាសម្គាល់នានារបស់ភាពតានតឹងផ្លូវចិត្ត ដូចជាការនឿយហត់ ហើយបន្ទាប់មកធ្វើការផ្លាស់ប្ដូរ ។
- ប្រសិនបើបញ្ហានោះបន្តនៅជាប់ជាមួយអ្នក សូមនិយាយជាមួយឪពុកម្ដាយ ឬ ថ្នាក់ដឹកនាំបព្វជិតភាព អំពីការស្វែងរកការទូន្មានពីអ្នកមានវិជ្ជាជីវៈស្របច្បាប់ជាមួយនឹងគុណតម្លៃល្អ ។

( សូមមើល « Like a Broken Vessel » *Liahona* ខែវិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៤០–៤២ ) ។ ■

តារាងអានគម្ពីរប្រវត្តិសាសនាចក្រ

# ការស្ដារឡើងវិញ

ឆ្នាំនេះនៅក្នុង *លីអាហូណា* យើងនឹងរៀនអំពីប្រវត្តិសាសនាចក្រ ។ សូមបើកទៅទំព័រ ៦៨ សម្រាប់បញ្ជីខគម្ពីរដែលអ្នក និង គ្រួសារអ្នកអាចអានអំឡុងឆ្នាំនេះ ។ បន្ទាប់ពីអាន សូមពិភាក្សាគ្នាអំពីអ្វីដែលអ្នកបានរៀន បន្ទាប់មកផាត់ពណ៌លើលេខដែលត្រូវគ្នា ។ រូបភាពនីមួយៗនៅក្នុងនេះតំណាងឲ្យផ្នែកមួយនៃសាសនាចក្រដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានស្ដារឡើងវិញ ។



រចនារូបភាពដោយ យ៉ារេឌ បេ៊កស្ត្រេន



## បញ្ជីខគម្ពីរ

ខគម្ពីរភាគច្រើនគឺជាវិវរណៈមកពីព្រះអម្ចាស់ប្រទានដល់យ៉ូសែប ស៊្មីធ ។ សូមផាត់រូបភាពនៅទំព័រទី ៦៦-៦៧ ពេលអ្នកអានវា !

| | |
|---|---|
| ១. យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១០–១៣ | ២៧. គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៩–១០, ១៥–១៩ |
| ២. យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៤–១៧ | ២៨. គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៩–១១ |
| ៣. យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១: ៣០, ៣៣–៣៤ | ២៩. គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៣៣–៣៤ |
| ៤. យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥១–៥៣ | ៣០. គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១៩–២៤, ៤០–៤១ |
| ៥. យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៦–៦៩ | ៣១. គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៧–១៩ |
| ៦. គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧–៣៨ | ៣២. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៥–៦ |
| ៧. គោលលទ្ធិ និង សេចក្ដីសញ្ញា ២:១–២ | ៣៣. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៣, ១០, ១៤ |
| ៨. គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:១–៧ | ៣៤. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៦–៤៧, ៦២ |
| ៩. គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣៤–៣៧ | ៣៥. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧៨–៨០ |
| ១០. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:២–៣, ៩–១០ | ៣៦. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–១២០ |
| ១១. គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥, ៦៩ | ៣៧. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៣–១២៦ |
| ១២. គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:៦–៧ | ៣៨. គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១, ១៨–២១ |
| ១៣. គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣:១ | ៣៩. គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១៥, ២៤ |
| ១៤. គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០–១៣ | ៤០. គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១៥–១៦, ២១ |
| ១៥. គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៥–១៦ | ៤១. គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១១–១២ |
| ១៦. គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៦–១៩, ២៣–២៤ | ៤២. គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:៥–៨ |
| ១៧. គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៧៥–៧៩ | ៤៣. គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៦, ៣២, ៣៦ |
| ១៨. គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១០–១៣ | ៤៤. គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៣៩–៤១ |
| ១៩. គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥–១៨ | ៤៥. គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៦, ៨, ១៣ |
| ២០. គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:២០–២៣ | ៤៦. គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១–១០ |
| ២១. គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:១០–១២, ៣២–៣៣ | ៤៧. គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩:៤, ៦–៧ |
| ២២. គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:២៥–២៨ | ៤៨. គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–៩, ៤៦ |
| ២៣. គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៤០–៤៦ | ៤៩. គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤១–៤៥ |
| ២៤. គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១:១៣, ១៩ | ៥០. គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៧–៩ |
| ២៥. គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៦–២៨ | ៥១. គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២០–២៣ |
| ២៦. គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤២–៤៣ | ៥២. គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:១–៤ |

ចម្លើយមកពីសាវក



**ដោយអែលឌើរ ដាល្លិន អេក អូក**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# តើព្រះវរបិតាសួគ៌ទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ ជានិច្ច ឬ ?










រូបភាពគូរដោយ ជីម ម៉ាដសិន

*ដកស្រង់ចេញពី « Faith in the Lord Jesus Christ »* Ensign *ខែ ឧសភា ឆ្នាំ ១៩៩៤ ទំព័រ ៩៨–១០០ ។*

# ទំព័ររបស់យើង



*ព្រះអម្ចាស់បានបង្កបង្កើតអ្វីៗគ្រប់យ៉ាង សម្រាប់កូនចៅរបស់ព្រះវរបិតាសួគ៌ ។ ខ្ញុំស្រឡាញ់សត្វ និង ធម្មជាតិ ។*

សាំយូអែល អិម អាយុ ៧ ឆ្នាំ ម៉ាឌ្រីឌ ប្រទេសអេស្ប៉ាញ





ដោយអាឡិចសាន់ឌើរ អិម អាយុ ១០ ឆ្នាំ រដ្ឋ ម៉ារីលែន ស.រ.អា.





ដោយ លីសេត អិន អាយុ ៥ ឆ្នាំ ម៉ាឌ្រីឌ ប្រទេសអេស្ប៉ាញ




*ខ្ញុំបានរៀននៅក្នុងការប្រជុំសាក្រាម៉ង់ និង នៅក្នុងថ្នាក់រៀននៅថ្ងៃអាទិត្យថា អ្វីៗទាំងអស់វាមិនសំខាន់ដូចគ្នាឡើយ ។ អ្វីដែលសំខាន់ខ្លាំងបំផុតនោះគឺជាដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និង ការគោរពប្រតិបត្តិតាមព្រះវរបិតាសួគ៌របស់យើង ។ ខ្ញុំស្រឡាញ់ការរៀនសូត្រ ។*

អៀន អេ អាយុ ៥ ឆ្នាំ ម៉ូរេឡូស ប្រទេសម៉ិកស៊ិក



*ពេលខ្ញុំទៅព្រះវិហារបរិសុទ្ធជាមួយគ្រួសារខ្ញុំ ខ្ញុំមានអារម្មណ៍ពីព្រះវិញ្ញាណយ៉ាងខ្លាំង ដោយសារខ្ញុំដឹងថាព្រះអម្ចាស់គង់នៅជាមួយពួកយើង ។ ទ្រង់បានមានបន្ទូលថា « ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ » ( សូមមើល ម៉ាថាយ ១៩:១៤ ) ។*

ហេធើរ អេ អាយុ ១០ ឆ្នាំ ប៉ារ៉ាណា ប្រទេសប្រេស៊ីល

# ព្រះគម្ពីរ នៅលើធ្នើរ



**ដោយអែលឌើរ វ៉លធើរ**
**អែហ្វ ហ្គុងស្សាឡែស្ស**
ក្នុងពួកចិតសិបនាក់

« *ស្វែង គិត អធិស្ឋានគឺជាអ្វីដែលខ្ញុំត្រូវធ្វើ* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ៦៦* ) ។

កាលខ្ញុំអាយុ ១២ ឆ្នាំខ្ញុំបានឮអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ខ្ញុំបានជួបអ្នកផ្សព្វផ្សាយសាសនាអិល. ឌី. អេស.ពីរនាក់នៅលើឡានក្រុង ។ ពួកគេបានសួរ ថាតើពួកគេអាចមកបង្រៀនគ្រួសាររបស់ខ្ញុំឬទេ ។

អ្នកផ្សព្វផ្សាយសាសនាបានទុកព្រះគម្ពីរមរមនមួយក្បាល និង ខិតប័ណ្ណទីបន្ទាល់របស់យ៉ូសែប ស្ម៊ីធ ។ ឪពុកម្ដាយរបស់ខ្ញុំជាមនុស្សល្អណាស់ ។ ប៉ុន្តែពួកលោកមិនបានចូលរួមសាសនាចក្រកាលគ្រានោះទេ ។

ឯកសារទាំងពីរនោះបានបន្តទុកនៅលើធ្នើរសៀវភៅរបស់យើងអស់ពេលជាច្រើនឆ្នាំ ។ បន្ទាប់មក នៅថ្ងៃមួយកាលខ្ញុំអាយុ ១៨ ឆ្នាំ ខ្ញុំបានទៅមើលធ្នើរដាក់សៀវភៅរបស់យើង ដើម្បីរកសៀវភៅល្អៗមកអាន ។ ខ្ញុំបានយកព្រះគម្ពីរមរមន ហើយអានជំពូកទីមួយ ។ កាលខ្ញុំអានវា អារម្មណ៍ពិសេសមួយបានផុសឡើងក្នុងគំនិតខ្ញុំ ។

ខ្ញុំមានបទពិសោធន៍ពិសេសមួយដែលខ្ញុំបានដឹងថា គម្ពីរនេះពិត ។ ព្រះគម្ពីរមរមនជាសារលិខិតពិសេសមួយអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំបានរៀនបន្ថែមទៀតអំពីជីវិតខ្ញុំផ្ទាល់ និង អំពីពរជ័យរបស់ព្រះវរបិតាសួគ៌ ។

ក្រោយមកខ្ញុំបានដឹងថា ទោះបីជាយ៉ូសែប ស្ម៊ីធមានអាយុ ១៤ ឆ្នាំ លោកមានចិត្តក្លាហានអានព្រះគម្ពីរ ហើយទូលសូមដល់ព្រះវរបិតាថាតើព្រះវិហារមួយណាត្រឹមត្រូវ ។

ចាប់តាំងពីពេលនោះមក ខ្ញុំបានធ្វើតាមគំរូរបស់យ៉ូសែប ស្ម៊ីធជានិច្ច ។ ខ្ញុំបានអានព្រះគម្ពីរ ហើយទូលសូមដល់ព្រះវរបិតាសួគ៌សូមជំនួយ និង ការណែនាំ ។ ការអធិស្ឋាន និង ព្រះគម្ពីរមរមន ជាផ្នែកដ៏សំខាន់បំផុតក្នុងជីវិតរបស់ខ្ញុំ ។

នៅពេលប្អូនៗមានបញ្ហា សូមអានព្រះគម្ពីរមរមន ហើយអធិស្ឋាន ។ ប្អូនៗនឹងរៀនបន្ថែមទៀតអំពីដំណឹងល្អ ហើយស្វែងរកចម្លើយដែលប្អូនៗត្រូវការ គឺដូចជាអ្វីដែលខ្ញុំបានធ្វើ ។ ចូរចងចាំពីអារម្មណ៍នោះ នៅពេលប្អូនៗធ្វើកិច្ចការនេះ ។ ■




រចនារូបភាពដោយ រ៉ូប៊ើរ ម៉ូត្សគុស

# តម្លៃរបស់ មិន ជុន



**ដោយ យៃលី ហានសាយើរ**
ផ្អែកទៅលើដំណើររឿងពិត

« *ព្រះយេស៊ូវជាសម្លាញ់យើង ។ . . . កុមារគួរស្រឡាញ់* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ៣៧* ) ។

មិន ជុនបានមើលពពកនៅខាងក្រៅបង្អួច ។ គាត់និយាយថា « វាមើលទៅទំនងជាមានភ្លៀងនៅថ្ងៃស្អែក » ។

លោកតាបានងាកមុខចេញពីការអានកាសែត ហើយសំឡឹងមើលទៅលើមេឃ ហើយងក់ក្បាល ។ វាគឺជាចុងរដូវក្ដៅនៅក្នុងទីក្រុងសេអ៊ូល ប្រទេស កូរ៉េ ហើយរដូវវស្សាបានចាប់ផ្ដើម ។

មិន ជុន បានរៀបចំឆត្រដាក់នៅក្បែរសម្លៀកបំពាក់សម្រាប់ពាក់ថ្ងៃអាទិត្យ ។ « ចៅគិតថា ថ្ងៃស្អែកពួកយើងគួរតែចេញដំណើរពីព្រលឹម » ។

លោកតាបានញញឹម ។ « គំនិតល្អ ។ យើងនឹងត្រូវដើរផ្លូវឆ្ងាយ ប្រសិនបើផ្លូវដែលទាបៗនោះលិចទឹក » ។

« តើលោកតាគិតថាអគារសាសនាចក្រនឹងគ្មានបញ្ហាអ្វីទេមែនទេ ? » មិន ជុន បានសួរ ។ ឆ្នាំមុន នៅបន្ទប់ក្រោមដី បានលិចទឹកអំឡុងរដូវវស្សា ។

លោកតាបាននិយាយថា « មែនហើយ » ។ « ប៉ុន្តែវាមិនពិបាកឡើយដើម្បីអធិស្ឋាននោះ » ។

« ដូច្នោះចៅនឹងអធិស្ឋានសម្រាប់ព្រះវិហារនារាត្រីនេះ ។ ហើយយើងនឹងអាចធ្វើដំណើរទៅព្រះវិហារដោយសុវត្ថិភាព ។ *ចាល យ៉ា យ៉ូ* ( រាត្រីសួស្ដី ) » ។ មិន ជុន បានឱនក្បាល ហើយចូលដេក ។

នៅពេលព្រឹកឡើង ពួកគេបានចេញពីផ្ទះពីព្រឹកព្រលឹម ។ មិន ជុន បានងើយមើលទៅពពកខ្មៅដែលគ្របដណ្ដប់ពេញផ្ទៃមេឃ ។

លោកតាបាននិយាយថា « ចូរមានសេចក្ដីជំនឿចុះ » ។

មិន ជុន បានដើរតាមលោកតាតាមជណ្ដើរតូចដែលមានបង្កាន់ដៃនៅលើកូនភ្នំក្បែរផ្ទះរបស់ពួកគេ ។ ពួកគេបានឈប់សម្រាកនៅលើកំពូលនោះដើម្បីយកកម្លាំង ។ សំណើមដ៏ច្រើននៅក្នុងបរិយាកាសបានធ្វើឲ្យអាវ-សរបស់ពួកគេសើម ។

លោកតាបានលាដៃប៉ះតំណក់ទឹកភ្លៀងដំបូង ។ « តើចៅមានប៉ះទឹកភ្លៀងទេ ? ភ្លៀងចាប់ផ្ដើមធ្លាក់ហើយ » ។





**ចូរបន្តព្យាយាម**

« អ្វីដែលអស្ចារ្យអំពីដំណឹងល្អនោះ គឺថាយើងទទួលបានរង្វាន់ចំពោះ *ការព្យាយាម* ទោះជាយើងពុំបានជោគជ័យជានិច្ចក្តី » ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « **Tomorrow the Lord Will Do Wonders among You** » ***Liahona*** ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ១២៥–១២៦ ។

ពួកគេបានបាំងឆត្រ ។ នៅពេលពួកគេបានឡើងទៅដល់ជណ្ដើរបន្ទាប់ ភ្លៀងបានធ្លាក់កាន់តែខ្លាំង ។ មិន ជុនបានមើលគ្រប់ជំហានដែលដើរកាត់ភ្លៀង ។ « អ៊ូយ ! » គាត់បានស្រែក នៅពេលគាត់រអិលដួល ហើយជង្គង់គាត់ដួលប៉ះដី ។

« តើចៅឈឺឬទេ ? » លោកតាបានសួរ ។ គាត់បានឈ្ងោកមើលស្នាមរហែកនៅលើខោរបស់មិន ជុន ។

មិន ជុន បាននិយាយដោយសំឡេងញ័រៗថា « វាគ្រាន់តែជាស្នាមរលាត់ទេ » ។

លោកតាបាននិយាយថា « យើងអាចដេរខោនេះនៅព្រះវិហារបាន » ។

មិន ជុន និង លោកតាបានបន្តឡើងជណ្ដើរ ហើយបត់ទៅតាមផ្លូវខាងលើ ។

លោកតាបាននិយាយដោយបិតឆត្រវិញថា « ខ្យល់បក់ខ្លាំងណាស់នៅខាងលើនេះ » ។ មិន ជុន ក៏ពិបាកនឹងកាន់ឆត្ររបស់គាត់ដែរ ។ រំពេចនោះ ខ្យល់បានបក់យ៉ាងខ្លាំង ហើយបានធ្វើឲ្យឆត្ររលាត់ឡើង រហែកតាមថ្នេររបស់វា ។ មិន ជុន បានទម្លាក់ស្មាចុះដោយអស់សង្ឃឹម ។



លោកតាបានកាន់ឆត្រឲ្យគាត់ ។ « ចូលមកជ្រកជាមួយតាមក ។ យើងជិតដល់ព្រះវិហារហើយ » ។

មិន ជុន និង លោកតាបានជ្រកក្រោមឆត្រជាមួយគ្នា ប៉ុន្តែពួកគេនៅតែទទឹកភ្លៀងដែលបន្តធ្លាក់ឥតឈប់នោះ ។ នៅពេលពួកគេបានដើរជិតដល់ព្រះវិហារ មិន ជុន បានឮសំឡេងតន្ត្រី ។

« ពួកគេបានចាប់ផ្ដើមប្រជុំហើយ ! » មិន ជុនបានរត់ទៅទ្វារមុខ ។ ក្រោយមកគាត់បានឃើញស្រមោលរបស់គាត់នៅក្នុងកញ្ចក់ ។ សក់គាត់ប្រៃជាកន្ទ្រើងស្រក់ទឹកតក់ៗ ខោរបស់គាត់បានរហែក ហើយស្បែកជើងគាត់ប្រឡាក់ភក់ ។ គាត់បានថយចេញពីទ្វារ ហើយដើរចុះជណ្ដើរវិញ ។

មិន ជុន និយាយដោយស្ទាក់ស្ទើរថា « ចៅ . . . ចៅមិនអាចចូលទៅបានទេ » ។

លោកតាបាននិយាយថា « ចូលទៅមិនអីទេចៅ » ។

« ប៉ុន្តែចៅកខ្វក់ ហើយសើមខ្លួនជោគ ! »

លោកតាបានមើលមុខ មិន ជុន ក្រោយមកបានមើលទៅឧបករណ៍វាស់ទឹកភ្លៀងដែលដាក់ព្យួរជាប់នឹងរបង ។

« វាងាយស្រួលដើម្បីវាស់កម្រិតទឹកភ្លៀង មិន ជុន ប៉ុន្តែតើយើងវាស់វែងខ្លួនរបស់យើងដោយរបៀបណា ? »

មិន ជុន បានព្រិចភ្នែកដាក់លោកតា ។

លោកតាបាននិយាយថា « ចៅឃើញថាស្បែកជើងចៅប្រឡាក់ភក់ ជង្គង់ចៅដួលដាច់រលាត់ សក់ចៅកន្ទ្រើងកន្ទ្រើង ហើយចៅគិតថា ចៅគ្មានតម្លៃសោះឬ » ។ « ប៉ុន្តែព្រះយេស៊ូវគ្រីស្ទមានរបៀបដ៏ប្រសើរដើម្បីផ្ដល់តម្លៃឲ្យមនុស្ស ។ ទ្រង់ជ្រាបដឹងពីដួងចិត្តចៅ ហើយដឹងថាអ្វីដែលចៅកំពុងធ្វើគឺត្រឹមត្រូវ ។ ប្រសិនបើចៅផ្ដល់តម្លៃខ្លួនឯងតាមរបៀបរបស់ទ្រង់នោះ ចៅនឹងឃើញពីតម្លៃដ៏ច្រើនលើសលុប » ។

មិន ជុនបានមើលឧបករណ៍វាស់ទឹកភ្លៀង ។ វាបន្តឡើងទៅៗនៅពេលភ្លៀងបន្តធ្លាក់ ។ គាត់បានគិតពីក្ដីលំបាកយ៉ាងខ្លាំង ដែលគាត់បានពុះពារធ្វើដំណើរមកព្រះវិហារ និង ភាពកក់ក្ដៅ ព្រមទាំងចិត្តរីករាយដែលគាត់បានមាននៅពេលគាត់បានមកដល់ព្រះវិហារ ។ គាត់បានគិតអំពីក្ដីស្រឡាញ់ដ៏ធំធេងរបស់គាត់ចំពោះព្រះអង្គសង្គ្រោះ និង ក្ដីស្រឡាញ់ដ៏ធំធេងរបស់ព្រះអង្គសង្គ្រោះមានចំពោះគាត់ ។

មិន ជុន បានឱបលោកតា ហើយពួកគេទាំងពីរនាក់បានដើរចូលទៅក្នុងព្រះវិហារ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ខូឡូរ៉ាដូ ស.រ.អា. ។*

# សូមកុំភ្លេចអធិស្ឋានឲ្យអ៊ីរីក



**ដោយ ជូលី កូនេសាល ហោង**

ផ្អែកទៅលើដំណើររឿងពិត

« *ចូរដឹងថាគ្រប់គ្នា មានសេរីក្នុងការរើសជីវិតខ្លួនចង់បាន* » ( ទំនុកតម្កើង *លេខ ១៤៩* ) ។

គ្រួសាររបស់ខារីបានលុតជង្គង់នៅក្បែរសាឡុងដើម្បីអធិស្ឋានជាគ្រួសារ ។ អ្នកទាំងអស់គ្នាឱបដៃរបស់ខ្លួនដោយមានគារវភាព ។ លោកប៉ាបានសូមឲ្យ លីវ ជាប្អូនស្រីរបស់ខារីអធិស្ឋាន ។

លោកប៉ាបានរំឭកនាងថា « សូមកុំភ្លេចថ្លែងអំណរគុណព្រះវរបិតាសួគ៌សម្រាប់ពរជ័យ *ជាច្រើន* របស់យើងផងដែរ » ។

ម៉ាក់បានបន្ថែមថា « សូមកុំភ្លេចអធិស្ឋានឲ្យអ៊ីរីកផង » ។ ម៉ាក់តែងរំឭកពួកគេឲ្យអធិស្ឋានសម្រាប់អ៊ីរីកជានិច្ច ។

អ៊ីរីកគឺជាបងប្រុសរបស់ខារី ។ ពីមុនគាត់បានចេញទៅរៀនមហាវិទ្យាល័យ គាត់ និង ខារីគឺជាកល្យាណមិត្តនឹងគ្នា ។ នាងពិតជានឹករឿងរ៉ាវសប្បាយនានាដែលពួកគេធ្លាប់លេងជាមួយគ្នា ។

រចនារូបភាពដោយ មេលីស្សា មែនវីល



ប៉ុន្មានខែក្រោយមក អ៊ីរីកបានប្រាប់ម៉ាក់ និង ប៉ាថា គាត់មិនចង់ក្លាយជាសមាជិកសាសនាចក្រតទៅទៀតឡើយ ។ ខារី និង គ្រួសារនាងមានការភ្ញាក់ផ្អើល ហើយកើតទុក្ខ ។ ពួកគេបានចាប់ផ្ដើមអធិស្ឋានឲ្យអ៊ីរីករៀងរាល់យប់ ។ ជួនកាលពួកគេបានអធិស្ឋានសូមឲ្យគាត់នឹងទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ហើយចង់ត្រឡប់មកកាន់ព្រះវិហារវិញ ។ ប៉ាបានអធិស្ឋានថា សូមឲ្យដួងចិត្តរបស់អ៊ីរីកមានភាពជ្រះស្រឡះដើម្បីសម្រេចចិត្តឲ្យបានល្អ ។ ជារឿយៗ ម៉ាក់បានអធិស្ឋានថា សូមឲ្យមាននរណាម្នាក់ដែលអ៊ីរីកទុកចិត្ត អាចជួយគាត់រកផ្លូវត្រឹមត្រូវ ។ ក្រៅពីការអធិស្ឋានរបស់ពួកគេ ខារីអត់ទ្រាំខឹងមិនបានឡើយ ។ ហេតុអ្វីព្រះវរបិតាសួគ៌ពុំនាំអ៊ីរីកត្រឡប់មកព្រះវិហារវិញ ?

ទីបំផុតនៅពេល លីវ បានបើកមាត់គាត់អធិស្ឋាន ខារីអត់ទ្រាំនឹងទប់ពាក្យសម្ដីរបស់នាងពុំបានទៀតឡើយ ។ នាងបានរបូតមាត់និយាយថា « ហេតុអ្វីព្រះវរបិតាសួគ៌ពុំឆ្លើយតបការអធិស្ឋានរបស់យើង ? »



អ្នកគ្រប់គ្នាបានមើលមុខខារីដោយក្ដីភ្ញាក់ផ្អើល ប៉ុន្តែនាងអន់ចិត្តយ៉ាងខ្លាំងដោយការខ្វល់ខ្វាយពីរឿងនោះ ។ គ្មាននរណានិយាយអ្វីឡើយអស់មួយសន្ទុះ ។

ប៉ាបាននិយាយថា « ខារី ពេលកូនមកពីសាលារៀនថ្ងៃនេះ តើកូនបានទុកកាបូបស្ពាយរបស់កូនត្រឹមត្រូវឬទេ ? »

« ប៉ាថាម៉េច ? » ខារីបានសួរដោយងឿងឆ្ងល់ ។ តើកាបូបស្ពាយរបស់នាងពាក់ព័ន្ធអ្វីដែរនឹងរឿងនេះ ? នាងបានក្រឡេកមើលទៅទ្វារមុខ ហើយបានឃើញកាបូបស្ពាយរបស់ខ្លួន ទម្លាក់ចោលក្បែរជញ្ជាំង ដោយមិនព្យួរជាប់ជញ្ជាំងក្បែរកាបូបរបស់លីវឡើយ ។ « អត់ទេ . . . កូនសូមទោស » ។

« តើម៉ាក់ពុំបានរំឭកកូនឲ្យព្យួរវាទេឬអី ? »

ខារីបានឆ្លើយ « ចាស » ។ នាងបានឈ្ងោកមុខចុះ ។

« តើជារឿយៗ ម៉ាក់ពុំបានរំឭកកូនឲ្យព្យួរកាបូបស្ពាយរបស់កូនទេឬអី ? »

ខារីបានឆ្លើយខ្សាវៗថា « ចាស » ។ នាងនៅតែពុំដឹងថាតើរឿងនេះវាពាក់ព័ន្ធនឹងរឿងផ្សេងទៀតដោយរបៀបណានោះទេ ។ តើប៉ាពុំបានចាត់ទុកសំណួររបស់នាងជាសំណួរសំខាន់ទេឬអី ?



« ប៉ាដឹងថានៅពេលយើងអធិស្ឋានឲ្យអ៊ីរីក ព្រះវរបិតាសួគ៌ *ពិតជា* ឆ្លើយតបការអធិស្ឋានរបស់យើង—គ្រប់ពេល ។ បញ្ហានោះគឺថា អ៊ីរីកអាចពុំស្ដាប់នរណាឡើយនៅពេលនេះ ។ អ៊ីរីកត្រូវរើសថាតើគាត់ស្ដាប់តាមព្រះវិញ្ញាណបរិសុទ្ធដែរឬអត់ គឺដូចជាកូនជ្រើសរើសស្ដាប់ម្ដាយកូនឲ្យព្យួរកាបូបស្ពាយរបស់កូនឬក៏មិនស្ដាប់ដូច្នោះដែរ ។ ប៉ុន្តែតើកូនគិតថា កូននឹងអើពើជាមួយម៉ាក់កូន *ជានិច្ច* ឬពេលគាត់ សូមឲ្យកូនព្យួរកាបូបស្ពាយរបស់កូននោះ ? »

ខារីបានតបថា « កូនគិតថាអត់ទេ » ។

« ថ្ងៃណាមួយនាងនឹងស្ដាប់តាម ! » ម៉ាក់បាននិយាយដោយមិចភ្នែកដាក់ខារី ។ ខារីបានញញឹម ។

ខារីបានបន្ថែមថា « ដូច្នោះថ្ងៃណាមួយអ៊ីរីកនឹងមានចិត្តស្ដាប់ផងដែរ »

ម៉ាក់បាននិយាយថា « ប្រាកដណាស់ » ។ « ការស្ដាប់ព្រះវិញ្ញាណបរិសុទ្ធ គឺជាជំនាញមួយដែលកូនត្រូវអភិវឌ្ឍ ។ ប្រហែលជាអ៊ីរីកមិនបានរៀនពីជំនាញនោះនៅឡើយទេ » ។ ខារីចាប់ផ្ដើមមានអារម្មណ៍ធូរស្បើយបន្តិច ។

ពួកគេបានឱនក្បាល ខណៈដែលលីវបានអធិស្ឋាន ។ នាងបានអធិស្ឋានសូមឲ្យ អ៊ីរីកនឹងរៀនស្ដាប់ព្រះវិញ្ញាណបរិសុទ្ធ ។ អំឡុងពេលដែលលីវកំពុងអធិស្ឋាន ខារីមានអារម្មណ៍សុខសាន្ត ហើយកក់ក្ដៅ ។ នាងបានដឹងថា ព្រះវរបិតាសួគ៌ទ្រង់កំពុងព្រះសណ្ដាប់ការអធិស្ឋានរបស់ពួកគេ ។ នៅពេលលីវបានថ្លែងអំពីពរជ័យមួយចំនួនដែលគ្រួសាររបស់ពួកគេបានទទួល ខារីបានគិតអំពីពរជ័យមួយទៀតបន្ថែមពីលើនោះ—ឥឡូវនេះនាងបានយល់កាន់តែប្រសើរឡើងអំពីការអធិស្ឋានហើយ !

នៅពេលចប់ការអធិស្ឋាន ខារី បានដឹងថា ព្រះវរបិតាសួគ៌ពុំបំភ្លេចអ៊ីរីកឡើយ ។ នាងក៏បានដឹងដែរថា ទ្រង់នឹងមិនភ្លេចនាងឡើយ ! ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ណាវ៉ាដា ស.រ.អា. ។*

### តើអ្វីគឺជាសិទ្ធិជ្រើសរើស ?

សិទ្ធិជ្រើសរើសគឺជាអំណោយទាន ដែលព្រះវរបិតាសួគ៌បានប្រទានដល់មនុស្សគ្រប់គ្នា ។ វាគឺជាអំណោយទានដើម្បីជ្រើសរើសអ្វីដែលយើងនឹងធ្វើ ។ ព្រះវរបិតាសួគ៌ជួយយើង ប៉ុន្តែទ្រង់ពុំបង្ខំយើងឲ្យធ្វើកិច្ចការណាឡើយ ។ ផ្ទុយទៅវិញ ទ្រង់ទុកឲ្យយើងជ្រើសរើសសម្រាប់ខ្លួនយើង ។

# ព្រះយេស៊ូវស្រឡាញ់ខ្ញុំ

ដោយ គីម វិប រៀង



ពីមុនផែនដីបានបង្កើតឡើង យើងទាំងអស់គ្នាបានរស់នៅឯស្ថានសួគ៌ជាមួយព្រះមាតាបិតាសួគ៌យើង និង បងប្រុសរបស់យើងគឺព្រះយេស៊ូវ ។ យើងមានភាពរីករាយ ហើយយើងស្រឡាញ់គ្នាយ៉ាងខ្លាំង ។

ថ្ងៃមួយព្រះវរបិតាសួគ៌បានប្រាប់ពួកយើងថា ទ្រង់នឹងបង្កើតផែនដីសម្រាប់ឲ្យពួកយើងរស់នៅ ។ ទ្រង់ជ្រាបដឹងថា ជួនកាលយើងនឹងមិនគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ឡើយអំឡុងពេលយើងរស់នៅលើផែនដី ។ យើងត្រូវការព្រះអង្គសង្គ្រោះ ដើម្បីជួយយើងឲ្យត្រឡប់ទៅផ្ទះគឺទៅកាន់ទ្រង់វិញ ។ ព្រះវរបិតាសួគ៌បានជ្រើសរើសយកព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់យើង ។



រចនារូបភាពដោយ អាបរីល ស្តុត

នៅពេលព្រះយេស៊ូវបានយាងមក
លើផែនដី ទ្រង់បានបង្ហាញរបៀប
ត្រឹមត្រូវដល់យើង ដើម្បីរស់នៅ ។
ទ្រង់ជួយមនុស្ស ។ ទ្រង់បាន
បង្រៀនពួកគេ ឲ្យស្រឡាញ់គ្នាទៅ
វិញទៅមក ។





ព្រះយេស៊ូវបានរងទុក្ខនៅក្នុងសួន
គែតសេម៉ានី និង នៅលើឈើ
ឆ្កាង ។ ទ្រង់ធ្វើបែបនេះ ប្រយោជន៍
ឲ្យយើងអាចប្រែចិត្ត ហើយដើម្បី
ឲ្យយើងអាចរស់ឡើងវិញបន្ទាប់ពី
យើងស្លាប់ ។



នៅពេលខ្ញុំរៀនអំពីព្រះយេស៊ូវ ខ្ញុំទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ទ្រង់ដែលមានចំពោះខ្ញុំ ។ ■

# ខ្ញុំជាបុត្ររបស់
# ព្រះមាតាបិតាសួគ៌



រចនារូបភាពដោយ អាបរីល ស្តុត



ដោយប្រធាន ហ្វ ប៊ី ប្រោន
( ឆ្នាំ ១៨៨៣–១៩៧៥ )
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

# រឿងក្តីសម្រាប់ព្យាការីនៅរស់

*នៅក្នុងឆ្នាំ ១៩៣៩ ពីមុនផ្ទុះសង្គ្រាមលោកលើកទី ២ ឡើង បងប្រុសប្រោន ត្រូវបានអញ្ជើញដោយសមាជិកម្នាក់នៃសភាជាន់ទាបប្រទេសអង់គ្លេស ឲ្យធ្វើការវែកញែកស្របច្បាប់មួយអំពីការប្រកាសរបស់បងប្រុសប្រោនដែលថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការី ។ នៅក្នុងសុន្ទរកថាដែលបានថ្លែងនៅក្នុងសាកលវិទ្យាល័យនៅថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៥៥ ដែលមានចំណងជើងថា « The Profile of a Prophet » ប្រធានប្រោនបានពិពណ៌នាអំពីការសន្ទនារបស់ពួកលោក ( សូមមើលគេហទំព័រ speeches.byu.edu )* ។

ខ្ញុំបានចាប់ផ្តើម . . . « លោកនិយាយថាជំនឿដែលខ្ញុំជឿថា ព្រះបានមានបន្ទូលមកកាន់មនុស្សនៅក្នុងជំនាន់នេះគឺជារឿងចម្លែក និង ដែលមិនគួរឲ្យជឿឬ ? »

« ចំពោះខ្ញុំគឺវាបែបនេះមែន » ។

« តើលោកជឿថាព្រះ ធ្លាប់បានមានបន្ទូលមកនរណាម្នាក់ដែរឬទេ ? »

« ប្រាកដណាស់ តាមរយៈព្រះគម្ពីរបរិសុទ្ធ យើងមានភស្តុតាងអំពីរឿងនោះ » ។

« តើទ្រង់បានមានបន្ទូលទៅអ័ដាមដែរឬទេ ? »

« បាទមាន » ។

« ចុះទ្រង់មានបន្ទូលទៅព្យាការី ហេណុក អូណេ អ័ប្រាហាំ ម៉ូសេ យ៉ាកុប យ៉ូសែប និង ព្យាការីផ្សេងទៀតដែរឬទេ ? »

« ខ្ញុំជឿថាទ្រង់បានមានបន្ទូលទៅកាន់ពួកលោក » ។

« តើលោកជឿថា ទំនាក់ទំនងរវាងព្រះ និង មនុស្សបានឈប់ឬ នៅពេលព្រះយេស៊ូវបានបង្ហាញព្រះកាយទ្រង់នៅលើផែនដីនោះ ? »

« ទេ ទំនាក់ទំនងបែបនោះវាឈានដល់ចំណុចខ្ពស់បំផុតរបស់វា នាគ្រានោះ » ។

« តើលោកជឿទេថា បន្ទាប់ពីព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ មានអ្នកច្បាប់ម្នាក់—ដែលយើងស្គាល់ផងដែរថា ជាសុលអ្នកស្រុកតើសុស ជាអ្នកធ្វើត្រសាល—នៅពេលលោកកំពុងធ្វើដំណើរទៅស្រុកដាម៉ាស បាននិយាយជាមួយព្រះយេស៊ូវជាអ្នកស្រុកណាសារ៉ែត ដែលត្រូវបានគេឆ្កាង ដែលបានមានព្រះជន្មរស់ឡើងវិញ ហើយបានយាងឡើងទៅស្ថានសួគ៌វិញដែរទេឬ ? »



« ខ្ញុំជឿ » ។

« តើសុលបានឮសំឡេងនរណា ? »

« នោះជាសំឡេងរបស់ព្រះយេស៊ូវគ្រីស្ទ ដ្បិតទ្រង់បានណែនាំព្រះអង្គទ្រង់ » ។

« នោះខ្ញុំសូមប្រាប់លោកដោយម៉ឺងម៉ាត់ថា វាគឺជាដំណើរការដូចគ្នានៅក្នុងជំនាន់ព្រះគម្ពីរប៊ីប ដែលព្រះមានបន្ទូលមកកាន់មនុស្ស » ។

« ខ្ញុំគិតថា ខ្ញុំនឹងទទួលស្គាល់រឿងនោះ ប៉ុន្តែវាបានឈប់ទៅវិញយ៉ាងលឿន បន្ទាប់ពីសតវត្សរ៍ទីមួយនៃយុគសម័យពួកគ្រិស្តសាសនិក » ។

« តើលោកគិតថា ហេតុអ្វីបានជាវាឈប់ ? »

« ខ្ញុំពុំអាចនិយាយវាបានទេ » ។

« តើលោកគិតថាព្រះ គ្មានបន្ទូលតាំងពីពេលនោះមកឬ ? »

« ខ្ញុំដឹងច្បាស់ថា ទ្រង់ពុំបានមានបន្ទូលឡើយ ? »

« ច្បាស់ជាមានហេតុផលមួយ ។ តើលោកអាចប្រាប់ខ្ញុំពីហេតុផលនោះបានទេ ? »

« ខ្ញុំមិនដឹងទេ » ។

« ខ្ញុំសូមផ្តល់យោបល់សមហេតុផលមួយចំនួនបានទេ ? ប្រហែលជាព្រះពុំមានបន្ទូលទៅកាន់មនុស្សទៀតឡើយ ដោយសារទ្រង់មិនអាចមានព្រះបន្ទូលឡើយ ។ ទ្រង់បានបាត់បង់ព្រះចេស្តានោះ » ។

គាត់បាននិយាយថា « មែនហើយនោះអាចជាពាក្យប្រមាថ » ។

« អញ្ចឹង ប្រសិនបើលោកពុំទទួលស្គាល់រឿងនោះ ប្រហែលជាទ្រង់ពុំមានបន្ទូលទៅកាន់មនុស្សឡើយ ដោយសារទ្រង់ពុំស្រឡាញ់ពួកយើងទៀតឡើយ ហើយទ្រង់ពុំចាប់អារម្មណ៍នឹងកិច្ចការរបស់មនុស្សលោកទៀតទេ » ។

គាត់និយាយថា « អត់ទេ ព្រះស្រឡាញ់មនុស្សទាំងអស់ ហើយទ្រង់ពុំរើសមុខនរណាឡើយ » ។

« ដូច្នោះប្រសិនបើទ្រង់មានព្រះបន្ទូល ហើយប្រសិនបើទ្រង់ស្រឡាញ់ពួកយើង នោះតាមខ្ញុំយល់ចម្លើយផ្សេងទៀតដែលសមហេតុផលនោះគឺថា យើងពុំចាំបាច់ត្រូវការទ្រង់ឡើយ ។ យើងបានរីកចម្រើនយ៉ាងលឿនបែបនេះនៅក្នុងផ្នែកវិទ្យាសាស្ត្រ ហើយយើងត្រូវបានអប់រំបានយ៉ាងល្អថា យើងពុំត្រូវការព្រះទៀតឡើយ » ។

ក្រោយមកគាត់បាននិយាយថា—ហើយសំឡេងរបស់គាត់ញ័រនៅពេលគាត់បានគិតអំពីសង្គ្រាមដែលនឹងកើតឡើង—« លោក ប្រោន គ្មានគ្រាណាមួយនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោក ដែលត្រូវការសំឡេងរបស់ព្រះជាងគ្រាបច្ចុប្បន្ននេះឡើយ ។ ប្រហែលលោកអាចប្រាប់ខ្ញុំពីមូលហេតុដែលទ្រង់ពុំមានព្រះបន្ទូល » ។

ចម្លើយរបស់ខ្ញុំគឺ ៖ « ទ្រង់ *ពិតជា* មានព្រះបន្ទូល ទ្រង់បានមានព្រះបន្ទូល ប៉ុន្តែមនុស្សត្រូវតែមានជំនឿដើម្បីស្តាប់ទ្រង់ » ។ ■

ផ្ទាំងគំនូរដោយ ជេមស៍ ចនសុន




***ការនិមិត្តដំបូង***, ដោយ ចច កូកូ សានតានជីឡូ

*« នៅពេលរស្មីនោះលេចមកមិនយូរប៉ុន្មាន ស្រាប់តែខ្ញុំបានឃើញថា ខ្ញុំបានរួចពីខ្មាំងសត្រូវដែលបានចងខ្ញុំទុក ។ កាលពន្លឺនោះស្ថិតចំលើខ្ញុំ ខ្ញុំបានឃើញតួអង្គពីរដែលមានរស្មី និងសិរីរុងរឿងដែលពុំអាចពិពណ៌នាបានឡើយ ឈរនៅលើអាកាសពីលើខ្ញុំ ។ តួអង្គមួយមានបន្ទូលមកខ្ញុំ ដោយហៅខ្ញុំតាមឈ្មោះ ហើយចង្អុលទៅតួអង្គមួយទៀត ដោយមានព្រះបន្ទូលថា — នេះជាព្រះរាជបុត្រាដ៏ស្ងួនភ្ញារបស់យើង ចូរស្ដាប់តាមទ្រង់ចុះ ! » ( យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:១៧ ) ។*

# មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ



ទំព័រ ៤៤

### គោលការណ៍របស់ពួកព្យាការីអំពី *ភាពស្មោះត្រង់*

តើមានការសម្រេចចិត្តអ្វីខ្លះ ដែលយើងត្រូវធ្វើក្នុងពេលឥឡូវនេះ ដើម្បីបន្តនៅស្មោះត្រង់នាពេលអនាគត ? សូមពិចារណាអំពីគោលការណ៍ទាំង ១០ នេះ ។

## សម្រាប់យុវវ័យ

### បាវចនាម៉្ងូតផលឆ្នាំ ២០១៧

តើចង់ខិតកាន់តែជិតព្រះវរបិតាសួគ៌ ឬ ? សូមសិក្សាបាវចនាម៉្ងូតផលឆ្នាំនេះ ដែលទាក់ទងនឹងការអធិស្ឋាន ។




ទំព័រ ៥០

## សម្រាប់កុមារ

### ការស្ដារឡើងវិញ

សូមសាកល្បងសកម្មភាពនេះ សម្រាប់ជាវិធីដ៏រីករាយមួយ ដើម្បីរៀនអំពីព្រះគម្ពីរ គោលលទ្ធិ និង សេចក្ដីសញ្ញា ។

ទំព័រ ៦៦



CAMBODIAN
4 02144 41258 7

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ